# ព្រឹទ្ធសភា
# SENATE MAGAZINE

## ទស្សនាវដ្ដីខែកុម្ភៈ











លេខ ៣០៤ ឆ្នាំទី២៦ ព.ស.២៥៦៩ គ.ស.២០២៦

Issue 304 Volume 26 B.E.2569 C.E.2026

# មាតិកា


៤


១៣


១៦

## ក្របមុខ

*- សម្តេចតេជោ **ហ៊ុន សែន** និងឯកឧត្តម **ស៊ីយ៉េដ យូសាហ្វ រ៉ាសា ហ្គីឡានី** ប្រធានព្រឹទ្ធសភា នៃសាធារណរដ្ឋអ៊ិស្លាមប៉ាគីស្ថាន។*
*- សម្តេចតេជោ **ហ៊ុន សែន** អញ្ជើញទទួលបដិសណ្ឋារកិច្ចស្វាគមន៍ឯកឧត្តម **តូ ឡឹម** អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម។*
*- សម្តេចតេជោ **ហ៊ុន សែន** អញ្ជើញទទួលបដិសណ្ឋារកិច្ចស្វាគមន៍ឯកឧត្តម **ថងលុន ស៊ីសុលីត** អគ្គលេខាធិការបក្សប្រជាជនបដិវត្តន៍ឡាវ និងជាប្រធានរដ្ឋ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។*
*- ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញថតរូបអនុស្សាវរីយ៍ជាមួយសមាជិក សមាជិកាអង្គបោះឆ្នោត នៅស្រុកក្រូចឆ្មារ។*
*- ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញថតរូបអនុស្សាវរីយ៍ជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ អាជ្ញាធរមូលដ្ឋានក្នុងខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ៕*

**អ្នកគ្រប់គ្រងទូទៅ**
ឯកឧត្តម ឡាយ សំកុល

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**
ឯកឧត្តម ខេង សិទ្ធិគុណ
ឯកឧត្តម ជាម សុផលមករា
ឯកឧត្តម ជួន ណា
លោក ជួន សុខជី
លោក ទេព មករា
លោក កុក វ៉ៃ
លោក សុង សុខភារ័ត្ន

**អ្នកគ្រប់គ្រងផ្ទាល់**
លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**
ការិយាល័យព័ត៌មាន

**ការិកុំព្យូទ័រ**
លោក ជុំ ច័ន្ទរតនា
លោកស្រី សុខ សុជាតា

## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា ( ១-២២ )


- សម្តេចតេជោ **ហ៊ុន សែន** អនុញ្ញាតឱ្យឯកឧត្តមឯកអគ្គរដ្ឋទូតឡាវ ចូលជួបសម្តែងការគួរសម និងជម្រាបលា....... ១
- សម្តេចតេជោ រំលឹកពីតួនាទីរបស់ឥណ្ឌូណេស៊ី ក្នុងការចូលរួមស្វះស្វែងរកសន្តិភាពរបស់កម្ពុជា និងការចូលរួមជំរុញឱ្យមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១ ....... ២
- សម្តេចតេជោ៖ កម្ពុជានិងកូរ៉េខាងត្បូង គួរតែពង្រីកទំនាក់ទំនងពីដៃគូយុទ្ធសាស្ត្រ ឱ្យក្លាយទៅជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ....... ៣
- កម្ពុជានិងប៉ាគីស្ថាន ឯកភាពគ្នាពង្រីកទំនាក់ទំនងរវាងប្រទេសទាំងពីរ ដោយជំរុញការបើកស្ថានទូតកម្ពុជានៅប៉ាគីស្ថាន....... ៤
- សម្តេចតេជោ **ហ៊ុន សែន** ជំរុញឱ្យកម្ពុជា-ឡាវ ពង្រឹងវិស័យការពារជាតិ និងកិច្ចសហប្រតិបត្តិការគ្រប់គ្រងគ្រោះមហន្តរាយតាមបន្ទាត់ព្រំដែន ... ៦
- សម្តេចតេជោ **ហ៊ុន សែន៖** បារាំងបានចូលរួមចំណែកក្នុងការស្វែងរកសន្តិភាពនៅកម្ពុជា ខណៈប្រធានាធិបតីបារាំងជាមិត្តដ៏ជិតស្និទ្ធជាមួយសម្តេច ... ៨
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អញ្ជើញចុះជួបសំណេះសំណាល ផ្សព្វផ្សាយសភាពការណ៍កម្ពុជា និងសមិទ្ធផលនានា ជូនដល់ក្រុមប្រឹក្សាឃុំ មន្ត្រីរាជការ និងប្រជាពលរដ្ឋ នៅខេត្តត្បូងឃ្មុំ ....... ១០
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុញ្ញាតឱ្យប្រធានសភាពាណិជ្ជកម្ម និងឧស្សាហកម្មរបស់ទីក្រុង Incheon ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ... ១២
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុញ្ញាតឱ្យប្រធានក្រុមមិត្តភាពរដ្ឋសភាបារាំង-កម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ....... ១៣
- គណៈកម្មាធិការប្រតិបត្តិនៃសភាប្រើភាសាបារាំងសម្រេចបញ្ចូលរបាយការណ៍ស្តីពី អរិភាពរវាងកម្ពុជានិងថៃ ទៅក្នុងរបាយការណ៍គណៈកម្មការនយោបាយ នៃសភាប្រើភាសាបារាំង....... ១៤
- ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា៖** ព្រឹទ្ធសភានឹងបន្តតាមដាន និងគាំទ្ររាល់យន្តការច្បាប់ដែលបង្កភាពងាយស្រួលដល់ការវិនិយោគ រួមទាំងអាជីវកម្មខ្នាតតូច ....... ១៦
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ជួបសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធក្នុងខណ្ឌចំការមន ខណ្ឌទួលគោក ខណ្ឌឫស្សីកែវ និងខណ្ឌច្បារអំពៅ ....... ១៧
- សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ....... ១៨


## សកម្មភាពគណៈកម្មការនានារបស់ព្រឹទ្ធសភា ( ២៣-៦៥ )


- គណៈកម្មការទី១ព្រឹទ្ធសភា អញ្ជើញចុះស្វែងយល់ការងារពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ខ្លួន នៅខេត្តកែប ខេត្តកំពត និងខេត្តព្រះសីហនុ....... ២៣
- គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា អញ្ជើញចុះឈ្វេងយល់អំពីការអនុវត្តថវិកានៅថ្នាក់ក្រោមជាតិ និងកិច្ចការក្នុងវិស័យជាសមត្ថកិច្ចរបស់ខ្លួន នៅខេត្តត្បូងឃ្មុំ និងខេត្តមណ្ឌលគិរី ....... ២៣
- គណៈប្រតិភូគណៈកម្មការទី៣ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រសួងបរិស្ថាន ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងផែនការ ....... ២៧
- គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា លើកឡើងនូវចំណុចសំខាន់ចំនួន៤ ពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ខ្លួន ជូនដល់អាជ្ញាធរខេត្តកំពត និងខេត្តព្រះសីហនុ ....... ២៩
- គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយរដ្ឋបាលខេត្តនិងមន្ទីរជំនាញពាក់ព័ន្ធ នៅខេត្តកំពង់ស្ពឺ ខេត្តកណ្តាល និងខេត្តតាកែវ....... ៣១
- គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា អញ្ជើញចុះឈ្វេងយល់អំពីការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ខ្លួន នៅក្រសួងនិងក្រុមហ៊ុនឯកជន ចំនួន៣....... ៣៣
- អំណោយមនុស្សធម៌របស់ព្រឹទ្ធសភាកម្ពុជា និងមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ត្រូវបានប្រគល់ជូនរដ្ឋបាលខេត្តសៀមរាប....... ៣៥
- គណៈកម្មការទី១០ព្រឹទ្ធសភា អញ្ជើញចុះឈ្វេងយល់អំពីការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ខ្លួននៅខេត្តស្វាយរៀង ....... ៣៦
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ អញ្ជើញសំណេះសំណាលជាមួយអាជ្ញាធរក្រុង ស្រុក ឃុំ សង្កាត់ទូទាំងខេត្តកណ្តាល....... ៣៨
- ការលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយតម្លាភាព និងគណនេយ្យភាព គឺជាភារកិច្ចស្នូលរបស់រដ្ឋបាលស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់....... ៤០
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ អញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ខេត្តព្រះសីហនុ....... ៤២
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ អញ្ជើញជួបសំណេះសំណាលជាមួយអាជ្ញាធរស្រុកបាទី ខេត្តតាកែវ....... ៤៤
- ក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបប្រជុំជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រីអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ ក្នុងភូមិភាគទី៨....... ៤៦
- ឯកឧត្តម **ម៉ម ប៊ុននាង** ទទួលស្វាគមន៍សាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យវ៉ាន់ដា មកបំពេញទស្សនកិច្ចស្វែងយល់អំពីព្រឹទ្ធសភា....... ៤៨
- កិច្ចប្រជុំគណៈកម្មការទាំង១០ ក្រុមភូមិភាគ និងក្រុមនានានៃព្រឹទ្ធសភា....... ៥០
- ការទទួលពាក្យបណ្តឹង ....... ៥៣
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨....... ៥៤
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ....... ៦២
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស ....... ៦៥


## សកម្មភាពអគ្គលេខាធិការដ្ឋាន ( ៦៦-៧២ )


- ឯកឧត្តម **ឡាយ សំកុល** អញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមករា និងកំណត់ទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២៦....... ៦៦
- ឯកឧត្តម **ឡាយ សំកុល** អញ្ជើញសំណេះសំណាលជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់ប្រទេសបារាំងចុះពិនិត្យព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋដោយមិនយកកម្រៃ នៅសង្កាត់បាក់ខែង ..... ៦៨
- សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ....... ៧០

# សម្តេចតេជោ ហ៊ុន សែន អនុញ្ញាតឱ្យឯកឧត្តមឯកអគ្គរដ្ឋទូតឡាវ ចូលជួបសម្តែងការគួរសម និងជម្រាបលា




*ឯកឧត្តម ប៊ួកែវ ភុំវង្សសាយ និងសម្តេចតេជោ ហ៊ុន សែន*

នាព្រឹកថ្ងៃចន្ទ ទី២៦ ខែមករា ឆ្នាំ២០២៦ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្តម **ប៊ួកែវ ភុំវង្សសាយ** (Buakeo Phumvongsay) ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចូលជួបសម្តែងការគួរសមនិងជម្រាបលា នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា។

នៅក្នុងជំនួបនោះ **សម្តេចតេជោ** បានវាយតម្លៃខ្ពស់ចំពោះបេសកកម្មការទូតរបស់**ឯកឧត្តមឯកអគ្គរដ្ឋទូត** នៅព្រះរាជាណាចក្រកម្ពុជានាពេលកន្លងទៅ ដែលបានធ្វើឱ្យទំនាក់ទំនងរវាងប្រទេសទាំងពីរកាន់តែមានភាពរីកចម្រើនបន្ថែមទៀត។

**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានចាត់ទុកប្រទេសកម្ពុជាគឺជាផ្ទះទី២ ដោយក្នុងពេលបំពេញការងាររយៈពេល៤ឆ្នាំ ឯកឧត្តមមានអនុស្សាវរីយ៍ជាច្រើនជាមួយប្រជាជននិងប្រទេសកម្ពុជា។ ឯកឧត្តមបានលើកឡើងអំពីទំនាក់ទំនងរវាងឡាវនិងកម្ពុជា ដែលត្រូវបានពង្រឹងពង្រីកឥតឈប់ឈរ និងមានភាពរីកចម្រើន ល្អប្រសើរ និងមានការផ្លាស់ប្តូរដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរជាបន្តបន្ទាប់។

**សម្តេចតេជោ** បានសម្តែងនូវក្តីរីករាយ ចំពោះទំនាក់ទំនងដ៏ល្អប្រពៃរវាងកម្ពុជានិងឡាវ ជាពិសេសការផ្លាស់ប្តូរដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ។ **សម្តេចតេជោ** ក៏បានជំរុញប្រទេសទាំងពីរបន្តខិតខំប្រឹងប្រែងពង្រីកទំនាក់ទំនងនិងសហប្រតិបត្តិការលើវិស័យពាណិជ្ជកម្ម វិនិយោគ និងសេដ្ឋកិច្ចបន្ថែមទៀត ព្រោះថានយោបាយនិងសេដ្ឋកិច្ចត្រូវដើរទន្ទឹមគ្នា។

ជាចុងក្រោយ **សម្តេចតេជោ** បានជូនពរ**ឯកឧត្តមឯកអគ្គរដ្ឋទូត** ទទួលបាននូវភាពជោគជ័យជាបន្តបន្ទាប់ទៀត៕

ប្រភព៖ Telegram Channel សម្តេចតេជោ

រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

# សម្តេចតេជោ រំលឹកពីតួនាទីរបស់ឥណ្ឌូណេស៊ី ក្នុងការចូលរួមស្វះស្វែងរកសន្តិភាពរបស់កម្ពុជា និងការចូលរួមជំរុញឱ្យមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១




*ឯកឧត្តមបណ្ឌិត សាន់តូ ដាម៉ូស៊ូម៉ាតូ និងសម្តេចតេជោ ហ៊ុន សែន*



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានរំលឹកអំពីតួនាទីរបស់ឥណ្ឌូណេស៊ី ក្នុងការចូលរួមចំណែកស្វះស្វែងរកសន្តិភាពរបស់កម្ពុជា ជាពិសេស តាំងពីសម័យ**ព្រះបរមរតនកោដ្ឋ** ដោយឥណ្ឌូណេស៊ីបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញឱ្យមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ២៣ តុលា ១៩៩១ ដែលជាផ្នែកដ៏សំខាន់ក្នុងការរុញច្រានកម្ពុជា ឱ្យឈានទៅរកសន្តិភាព។ ទាំងអស់នេះ គឺជាផ្លែផ្កាដែលបានកើតឡើងពីទំនាក់ទំនងរវាងប្រទេសទាំងពីរ។

**សម្តេចតេជោ** បានលើកឡើងបែបនេះ ក្នុងឱកាសអនុញ្ញាតឱ្យឯកឧត្តមបណ្ឌិត **សាន់តូ ដាម៉ូស៊ូម៉ាតូ** (Santo Darmosumarto) ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋឥណ្ឌូណេស៊ីប្រចាំនៅកម្ពុជា ចូលជួបសម្តែងការគួរសមនិងជម្រាបលា នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា នាព្រឹកថ្ងៃចន្ទទី២៦ ខែមករា ឆ្នាំ២០២៦។

**សម្តេចតេជោ** បានវាយតម្លៃខ្ពស់ចំពោះតួនាទីនិងការខិតខំប្រឹងប្រែងរបស់**ឯកឧត្តមឯកអគ្គរដ្ឋទូត** ក្នុងការពូនជ្រំនិងពង្រឹងនូវទំនាក់ទំនងមិត្តភាពរវាងកម្ពុជានិងឥណ្ឌូណេស៊ីឱ្យមានភាពរីកចម្រើន។ **សម្តេច**បានថ្លែងអំណរគុណ**ឯកឧត្តមឯកអគ្គរដ្ឋទូត** ចំពោះការចូលរួមរៀបចំដំណើរទស្សនកិច្ចរបស់**សម្តេច**ទៅកាន់សាធារណរដ្ឋឥណ្ឌូណេស៊ី កាលពីខែឧសភាឆ្នាំ២០២៥កន្លងទៅ ប្រកបដោយជោគជ័យ និងការទទួលស្វាគមន៍យ៉ាងកក់ក្តៅពី**ឯកឧត្តមប្រធានាធិបតីឥណ្ឌូណេស៊ី**។

នៅក្នុងជំនួបនោះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានវាយតម្លៃចំពោះភាពរីកចម្រើននៃកិច្ចសហប្រតិបត្តិការស្ទើរគ្រប់វិស័យរវាងប្រទេសទាំងពីរ។ ឯកឧត្តមបានបញ្ជាក់ថាក្នុងអំឡុងពេលបំពេញបេសកកម្មនៅកម្ពុជា ឯកឧត្តមបានខិតខំប្រឹងប្រែងពង្រឹងទំនាក់ទំនងកម្ពុជានិងឥណ្ឌូណេស៊ីឱ្យកាន់តែរឹងមាំ ជាពិសេសតាមរយៈការផ្លាស់ប្តូរទស្សនកិច្ចរវាងថ្នាក់ដឹកនាំប្រទេសទាំងពីរ។

**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានលើកឡើងអំពីដំណើរទស្សនកិច្ចរបស់**ឯកឧត្តមប្រធានាធិបតីឥណ្ឌូណេស៊ី** មកកាន់ព្រះរាជាណាចក្រកម្ពុជា និងដំណើរទស្សនកិច្ចរបស់**សម្តេចតេជោ** ទៅកាន់ឥណ្ឌូណេស៊ី ដែលជាផ្នែកមួយដ៏សំខាន់ក្នុងការញ៉ាំងឱ្យទំនាក់ទំនងប្រទេសទាំងពីរកាន់តែរីកចម្រើន។

ជាចុងក្រោយ **សម្តេចតេជោ** បានជូនពរ**ឯកឧត្តមឯកអគ្គរដ្ឋទូត** ទទួលបានភាពជោគជ័យក្នុងភារកិច្ចបន្តទៀត ហើយសង្ឃឹមថា ឯកឧត្តមនឹងវិលត្រឡប់មកកាន់ព្រះរាជា-ណាចក្រកម្ពុជា នាពេលណាមួយខាងមុខនេះ៕

ប្រភព៖ Telegram Channel សម្តេចតេជោ

រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន

# សម្តេចតេជោ៖ កម្ពុជានិងកូរ៉េខាងត្បូង គួរតែពង្រីកទំនាក់ទំនងពីដៃគូយុទ្ធសាស្ត្រ ឱ្យក្លាយទៅជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ



*ឯកឧត្តម Kim Changyong និងសម្តេចតេជោ ហ៊ុន សែន*



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

ក្នុងឱកាសអនុញ្ញាតឱ្យឯកឧត្តម Kim Changyong ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាព នៃសាធារណរដ្ឋកូរ៉េ ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២៩ ខែមករា ឆ្នាំ២០២៦ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានកត់សម្គាល់ថា នៅឆ្នាំ២០២៧ គឺជាខួប៣០ឆ្នាំ នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ។ ភាគីទាំងពីរគួរពង្រីកទំនាក់ទំនងពី«ដៃគូយុទ្ធសាស្ត្រ»ឱ្យក្លាយទៅជា «ដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ»ដោយសារតែទំនាក់ទំនងទ្វេភាគីនាពេលបច្ចុប្បន្ន មានការរីកចម្រើនស្ទើរគ្រប់វិស័យរួចទៅហើយ។

**សម្តេចតេជោ** បានគូសបញ្ជាក់ថា ទំនាក់ទំនងប្រទេសទាំងពីរ គឺ**សម្តេច**បានខិតខំប្រឹងប្រែងពូនជ្រំចាប់តាំងពីឆ្នាំ១៩៩៦មក។ **សម្តេច**មានជំនឿថា ភាគីទាំងពីរនឹងសហការគ្នារៀបចំព្រឹត្តិការណ៍អបអរសាទរខួប៣០ឆ្នាំដ៏មានអត្ថន័យ។

**សម្តេចតេជោ** បានសម្តែងនូវការអបអរសាទរចំពោះឯកឧត្តម Kim Changyong ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងបានចាត់ទុកវត្តមានរបស់ឯកឧត្តមនៅកម្ពុជា គឺជាការបង្ហាញយ៉ាងច្បាស់ថា សាធារណរដ្ឋកូរ៉េបានផ្តល់តម្លៃយ៉ាងខ្ពស់ចំពោះទំនាក់ទំនងរវាងកម្ពុជានិងសាធារណរដ្ឋកូរ៉េ។

ក្នុងឱកាសនោះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានគូសបញ្ជាក់ថា ក្រោមការដឹកនាំរបស់**សម្តេចតេជោ** នាពេលកន្លងទៅហូតមកដល់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** ទំនាក់ទំនងកម្ពុជានិងសាធារណរដ្ឋកូរ៉េ មានការរីកចម្រើនជាលំដាប់ រហូតដល់ក្លាយជាដៃគូយុទ្ធសាស្ត្រជាមួយគ្នា។ ឯកឧត្តម បានចាត់ទុក **សម្តេចតេជោ** គឺជាតួអង្គដ៏សំខាន់ក្នុងការពូនជ្រំនិងជាស្ថាបនិកនៃការបង្កើតនិងពង្រឹងទំនាក់ទំនងរវាងកម្ពុជា និងសាធារណរដ្ឋកូរ៉េ។ ឯកឧត្តម បានប្តេជ្ញាថា នឹងខិតខំប្រឹងប្រែងក្នុងការពង្រីកទំនាក់ទំនងរវាងប្រទេសទាំងពីរឱ្យកាន់តែរីកចម្រើនបន្ថែមទៀត។

**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានរំពឹងថា ប្រទេសទាំងពីរនឹងអាចដំឡើងកម្រិតពីទំនាក់ទំនងដៃគូយុទ្ធសាស្ត្រ ទៅជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ហើយឯកឧត្តមនឹងខិតខំប្រឹងប្រែងធ្វើកិច្ចការងារទាំងអស់នោះ។

ជាចុងក្រោយ **សម្តេចតេជោ** បានជូនពរ**ឯកឧត្តមឯកអគ្គរដ្ឋទូត** ទទួលបាននូវភាពជោគជ័យជាបន្តបន្ទាប់៕

ប្រភព៖ Telegram Channel សម្តេចតេជោ

រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន

# កម្ពុជានិងប៉ាគីស្ថាន ឯកភាពគ្នាពង្រីកទំនាក់ទំនងរវាងប្រទេសទាំងពីរ ដោយជំរុញការបើកស្ថានទូតកម្ពុជានៅប៉ាគីស្ថាន



*សម្តេចតេជោ ហ៊ុន សែន អញ្ជើញទទួលបដិសណ្ឋារកិច្ចស្វាគមន៍ ឯកឧត្តមប្រធានព្រឹទ្ធសភាប៉ាគីស្ថាន*

នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា នារសៀលថ្ងៃចន្ទ ទី២ ខែកុម្ភៈ ឆ្នាំ២០២៦ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **ស៊ីយ៉េដ យូសាហ្វ រ៉ាសា ហ្គីឡានី** (Syed Yusuf Raza Gillani) ប្រធានព្រឹទ្ធសភា នៃសាធារណរដ្ឋអ៊ិស្លាមប៉ាគីស្ថាន បានឯកភាពគ្នាក្នុងការជំរុញនិងពង្រឹងទំនាក់ទំនងរវាងប្រទេសទាំងពីរឱ្យកាន់តែរីកចម្រើនបន្ថែមទៀត។ ក្នុងនោះ **សម្តេចតេជោ** បានគាំទ្រឱ្យរាជរដ្ឋាភិបាលកម្ពុជា ពិចារណាបើកស្ថានទូតជាផ្លូវការនៅសាធារណរដ្ឋអ៊ិស្លាមប៉ាគីស្ថាន ដើម្បីជំរុញការពង្រឹងទំនាក់ទំនងទ្វេភាគី។

ការឯកភាពគ្នានេះ ធ្វើឡើងក្នុងឱកាសដែល សម្តេចតេជោ **ហ៊ុន សែន** ទទួលជួបទ្វេភាគីជាមួយ**ឯកឧត្តមប្រធានព្រឹទ្ធសភាប៉ាគីស្ថាន** ក្នុងអំឡុងពេលដែល**ឯកឧត្តមប្រធានព្រឹទ្ធសភាប៉ាគីស្ថាន** អញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី២ ដល់ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៦។

នៅក្នុងជំនួបនោះ **សម្តេចតេជោ** បានស្វាគមន៍ដោយក្តីរីករាយចំពោះវត្តមាន **ឯកឧត្តមប្រធានព្រឹទ្ធសភាប៉ាគីស្ថាន** ដែលអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា និងបានចាត់ទុកវត្តមានរបស់**ឯកឧត្តមប្រធានព្រឹទ្ធសភាប៉ាគីស្ថាន** ជាផ្នែកដ៏សំខាន់ក្នុងការជំរុញនិងការពង្រឹងទំនាក់ទំនងរវាងប្រទេសទាំងពីរ ទាំងក្នុងក្របខ័ណ្ឌស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័ននីតិប្រតិបត្តិ។ ជាមួយគ្នានេះ **សម្តេចតេជោ** បានអបអរសាទរ ចំពោះភាពជោគជ័យរបស់សាធារណរដ្ឋអ៊ិស្លាមប៉ាគីស្ថាន ក្នុងការរៀបចំសន្និសីទប្រធានសភា នៃអន្តរសភាកាលពីខែវិច្ឆិកា



*សម្តេចតេជោ ហ៊ុន សែន ជួបពិភាក្សាការងារទ្វេភាគីជាមួយឯកឧត្តមប្រធានព្រឹទ្ធសភាប៉ាគីស្ថាន*

# សម្តេចតេជោ ហ៊ុន សែន ជំរុញឱ្យកម្ពុជា-ឡាវ ពង្រឹងវិស័យការពារជាតិ និងកិច្ចសហប្រតិបត្តិការគ្រប់គ្រងគ្រោះមហន្តរាយតាមបន្ទាត់ព្រំដែន




*ឯកឧត្តមឧត្តមសេនីយ៍ឯក សាយចៃ គុមម៉ាស៊ីត និងសម្តេចតេជោ ហ៊ុន សែន*

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានជំរុញឱ្យកងទ័ពកម្ពុជា-ឡាវ ពង្រីកការចែករំលែកបទពិសោធលើវិស័យការពារជាតិនិងការបណ្តុះបណ្តាលធនធានមនុស្សឱ្យកាន់តែផុលផុស។ ការលើកឡើងបែបនេះក្នុងឱកាសដែល **សម្តេចតេជោ** អនុញ្ញាតឱ្យឯកឧត្តមឧត្តមសេនីយ៍ឯក **សាយចៃ គុមម៉ាស៊ីត** (Saichay Kommasith) អនុរដ្ឋមន្ត្រីក្រសួងការពារប្រទេសនិងជាប្រធានអគ្គសេនាធិការកងទ័ពប្រជាជនឡាវ ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារនៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា នាព្រឹកថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៦។

**សម្តេចតេជោ** បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅនិងចាត់ទុកដំណើរទស្សនកិច្ចរបស់ឯកឧត្តមឧត្តមសេនីយ៍ឯក **សាយចៃ គុមម៉ាស៊ីត** មកកាន់កម្ពុជាជាចលករដ៏សំខាន់ក្នុងការជំរុញទំនាក់ទំនងនិងសហប្រតិបត្តិការរវាងកងទ័ព នៃប្រទេសទាំងពីរកាន់តែស៊ីជម្រៅ។

**សម្តេចតេជោ** បានរំលេចថា កាលពីពេលថ្មីៗថ្នាក់ដឹកនាំកំពូលរបស់ឡាវ ដូចជា ឯកឧត្តម **ថងលុន ស៊ីសុលីត** អគ្គលេខាធិការបក្សប្រជាជនបដិវត្តន៍ឡាវ និងជាប្រធានរដ្ឋ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បានមកបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅកម្ពុជា ដែលបានឆ្លុះបញ្ចាំងពីទំនាក់ទំនងដ៏ល្អរវាងកម្ពុជា-ឡាវ នាពេល



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសមនិងពិភាក្សាការងារ*

បច្ចុប្បន្ន។

នៅក្នុងជំនួបនោះ ឯកឧត្តមឧត្តមសេនីយ៍ឯក **សាយថៃ គុមម៉ាស៊ីត** បានថ្លែងអំណរគុណចំពោះ **សម្តេចតេជោ** ដែលបានអនុញ្ញាតឱ្យឯកឧត្តមនិងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម។ ឯកឧត្តមបានលើកឡើងអំពីទំនាក់ទំនងដ៏ល្អនាពេលបច្ចុប្បន្នរបស់ប្រទេសទាំងពីរ និងសង្កត់ធ្ងន់លើទំនាក់ទំនងនៃវិស័យការពារជាតិ និងកងទ័ពនៃប្រទេសទាំងពីរ ដោយឯកឧត្តមបានប្តេជ្ញានៅចំពោះមុខ **សម្តេចតេជោ** នឹងខិតខំប្រឹងប្រែងពូនជ្រំទំនាក់ទំនងរវាងកងទ័ពនៃប្រទេសទាំងពីរឱ្យកាន់តែរីកចម្រើនបន្តទៀត។ ស្របជាមួយគ្នានោះ ឯកឧត្តមក៏បានវាយតម្លៃខ្ពស់ចំពោះសហប្រតិបត្តិការនៅតាមបន្ទាត់ព្រំដែន ដែលជាព្រំដែនសន្តិភាព កិច្ចសហប្រតិបត្តិការ ហើយមានសុខសុវត្ថិភាពល្អជាមួយគ្នា តាមរយៈសហប្រតិបត្តិការល្អរវាងកងទ័ពនិងអាជ្ញាធរនៃប្រទេសទាំងពីរ។

បន្ថែមពីនេះ **ឯកឧត្តមឧត្តមសេនីយ៍ឯក** ក៏បានរាយការណ៍ជូន**សម្តេចតេជោ** អំពីសកម្មភាពនិងជំនួបជាមួយ**ឯកឧត្តមអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទកម្ពុជា**និង**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិកម្ពុជា** ក្នុងពេលដែលឯកឧត្តមបានបំពេញទស្សនកិច្ចនៅកម្ពុជា ដែលជាកត្តាដ៏សំខាន់ក្នុងការដាក់ចេញនូវផែនការពង្រីកទំនាក់ទំនងទ្វេភាគីក្នុងក្របខ័ណ្ឌកងទ័ពកម្ពុជា-ឡាវ។

ជាការឆ្លើយតប **សម្តេចតេជោ** បានសម្តែងការពេញចិត្តចំពោះលទ្ធផលរបស់ឯកឧត្តម **សាយថៃ គុមម៉ាស៊ីត** ដែលបានបំពេញបេសកកម្ម និងបានជំរុញបន្ថែមការចែករំលែកបទពិសោធ និងការបណ្តុះបណ្តាលធនធានមនុស្សឱ្យកាន់តែផុលផុស តាមរយៈការផ្តល់អាហារូបករណ៍ក្នុងវិស័យការពារជាតិ ដើម្បីជាផ្នែកមួយក្នុងការបង្កើនមូលធនមនុស្សក្នុងវិស័យការពារជាតិឱ្យកាន់តែរីកចម្រើន។

**សម្តេចតេជោ** បានបង្ហាញក្តីរីករាយដែលបានឃើញនូវសហប្រតិបត្តិការដ៏ល្អនៅតាមព្រំដែន ហើយ**សម្តេច**សង្ឃឹមនិងជំរុញបន្ថែមឱ្យអាជ្ញាធរនិងកងទ័ពនៃប្រទេសទាំងពីរធ្វើការជាមួយគ្នាឱ្យបានល្អ ដើម្បីរក្សាសន្តិភាព សន្តិសុខនៅតាមព្រំដែនឱ្យកាន់តែល្អ។ **សម្តេច**បានផ្តល់យោបល់ឱ្យសហប្រតិបត្តិការនៅតាមព្រំដែន មិនត្រឹមតែនៅក្នុងក្របខ័ណ្ឌប្រពៃណី ដែលមានការបង្ក្រាបបទល្មើសឧក្រិដ្ឋកម្មឆ្លងដែននោះទេ គឺចង់ឃើញឱ្យមានសហប្រតិ-បត្តិការគ្រប់គ្រងគ្រោះមហន្តរាយដូចជាទឹកជំនន់ឬភ្លើងឆេះព្រៃជាដើម ក្នុងគោលដៅឱ្យមានសហប្រតិបត្តិការគ្រប់ទម្រង់និងស៊ីជម្រៅ។

ជាចុងក្រោយ **សម្តេចតេជោ** បានជូនពរចំពោះឯកឧត្តម និងប្រតិភូឱ្យទទួលបានជោគជ័យនៅក្នុងឱកាសបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា៕

ប្រភព៖ Telegram Channel សម្តេចតេជោ

រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសមនិងពិភាក្សាការងារ*

# សម្តេចតេជោ ហ៊ុន សែន៖ បារាំងបានចូលរួមចំណែកក្នុងការស្វែងរកសន្តិភាព នៅកម្ពុជា ខណៈប្រធានាធិបតីបារាំងជាមិត្តដ៏ជិតស្និទ្ធជាមួយសម្តេច

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានគូសបញ្ជាក់អំពីតួនាទីរបស់បារាំងដែលបានចូលរួមចំណែកក្នុងការស្វែងរកសន្តិភាពនៅកម្ពុជា ជាពិសេសចាប់តាំងពីជំនួប **សីហនុ-ហ៊ុនសែន** កាលពីថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៨៧ នៅ Fère-en-Tardenois ដែលជាចំណុចចាប់ផ្តើមនៃការស្វែងរកកិច្ចចរចាសន្តិភាពទីក្រុងប៉ារីស ខណៈ **សម្តេចតេជោ**និងឯកឧត្តម **អេម៉ានូអែល ម៉ាក្រុង** ប្រធានាធិបតីបារាំង គឺជាមិត្តដ៏ជិតស្និទ្ធជាមួយគ្នា ដែលតែងតែប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក។ **សម្តេចតេជោ** បានចាត់ទុកបារាំង គឺជាមិត្តចាស់ចងភ្ជាប់ទៅដោយចំណងប្រវត្តិសាស្ត្រដ៏យូរអង្វែងជាមួយគ្នា ហើយជាមិត្តមួយដែលតែងតែសហប្រតិបត្តិការជាមួយគ្នាយ៉ាងស៊ីជម្រៅ។

ការគូសបញ្ជាក់នេះ ត្រូវបានលើកឡើងក្នុងឱកាសដែល**សម្តេចតេជោ** អនុញ្ញាតឱ្យគណៈប្រតិភូក្រុមមិត្តភាពរដ្ឋសភាបារាំង-កម្ពុជា ដឹកនាំដោយ ឯកឧត្តម Thomas Lam ប្រធានក្រុម ចូលជួបសម្តែងការគួរសម នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា នាព្រឹកថ្ងៃពុធ ទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦។






*ឯកឧត្តម Thomas Lam និងសម្តេចតេជោ ហ៊ុន សែន*

**សម្តេចតេជោ** បានស្វាគមន៍និងចាត់ទុកដំណើរទស្សនកិច្ចរបស់ឯកឧត្តម Thomas Lamនិងគណៈប្រតិភូ



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសមនិងពិភាក្សាការងារ*

ជាផ្នែកដ៏សំខាន់នៃការធ្វើឱ្យទំនាក់ទំនងនិងសហប្រតិបត្តិការរវាងកម្ពុជានិងបារាំងកាន់តែរីកចម្រើន ជាពិសេសទំនាក់ទំនងរវាងស្ថាប័ននីតិប្បញ្ញត្តិនៃប្រទេសទាំងពីរកាន់តែល្អប្រសើរឡើងថែមទៀត។

ក្នុងឱកាសនោះ ឯកឧត្តម Thomas Lam បានសម្តែងនូវអំណរគុណ និងកោតសរសើរចំពោះការដឹកនាំរបស់ **សម្តេចតេជោ** ក្នុងការនាំប្រទេសកម្ពុជាឱ្យមានសន្តិភាព និងសេដ្ឋកិច្ចរីកចម្រើននៅពេល**សម្តេច** ជានាយករដ្ឋមន្ត្រី ព្រមទាំងបន្តរីកចម្រើនដល់សព្វថ្ងៃ ក្រោមការដឹកនាំរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** ជានាយករដ្ឋមន្ត្រី។ ឯកឧត្តមបានមានប្រសាសន៍ថា កន្លងទៅបារាំងក៏បានចូលរួមចំណែកក្នុងការស្វះស្វែងរកសន្តិភាពនៅកម្ពុជា ជាពិសេសតាមរយៈកិច្ចព្រមព្រៀងទីក្រុងប៉ារីស ២៣ តុលា ឆ្នាំ១៩៩១។ ឯកឧត្តមក៏បានលើកឡើងថា ដំណើរទស្សនកិច្ចរបស់ឯកឧត្តមនាពេលនេះ ជាផ្នែកមួយនៃការចូលរួមត្រៀមរៀបចំនៃកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី ដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះនៅចុងឆ្នាំនេះនិងការត្រៀមទទួលឯកឧត្តមប្រធានាធិបតីបារាំងនៅពេលខាងមុខផងដែរ។

**សម្តេចតេជោ** បានអរគុណចំពោះការសរសើររបស់ឯកឧត្តម Thomas Lam ហើយបានលើកឡើងថា ទស្សនកិច្ចរបស់ប្រធានាធិបតីបារាំងនាពេលខាងមុខ ជាជំហានសំខាន់ក្នុងការពង្រឹងនិងពង្រីកទំនាក់ទំនងកម្ពុជា-បារាំងបន្ថែមទៀត។ **សម្តេច**ក៏បានរំលឹកពីការចូលរួមរបស់បារាំងក្នុងការអភិវឌ្ឍកម្ពុជា រួមទាំងការប្រើប្រាស់ភាសាបារាំង និងគម្រោងអភិវឌ្ឍន៍នានា។ ជាមួយនេះ **សម្តេច**បានជំរុញឱ្យភាគីទាំងពីរបន្តសហប្រតិបត្តិការជាមួយគ្នាបន្ថែមទៀតលើផ្នែកពាណិជ្ជកម្ម សេដ្ឋកិច្ច និងវិនិយោគ ព្រមទាំងលើកទឹកចិត្តឱ្យអ្នកវិនិយោគបារាំងមកវិនិយោគនៅកម្ពុជាបន្ថែមទៀត។

ឯកឧត្តម Thomas Lam បានសម្តែងនូវការពេញចិត្តចំពោះការលើកឡើងរបស់សម្តេចតេជោ អំពីទំនាក់ទំនងរវាងកម្ពុជានិងបារាំង និងបានបញ្ជាក់ថា ឯកឧត្តមនិងគណៈប្រតិភូនឹងខិតខំជួយសម្របសម្រួលការរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះនាពេលខាងមុខ ព្រមទាំងបានឯកភាពឱ្យប្រទេសទាំងពីរជំរុញបន្ថែមទៀតលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការវិនិយោគ។

ជាចុងក្រោយ**សម្តេចតេជោ**បានជូនពរឯកឧត្តម Thomas Lam និងគណៈប្រតិភូ ឱ្យបំពេញទស្សនកិច្ចនៅកម្ពុជាប្រកបដោយជោគជ័យ៕

ប្រភព៖ Telegram Channel សម្តេចតេជោ

រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសមនិងពិភាក្សាការងារ*

# ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញចុះជួបសំណេះសំណាល ផ្សព្វផ្សាយសភាពការណ៍កម្ពុជា និងសមិទ្ធផលនានា ជូនដល់ក្រុមប្រឹក្សាឃុំ មន្ត្រីរាជការ និងប្រជាពលរដ្ឋ នៅខេត្តត្បូងឃ្មុំ





*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ ស្រុកអូររាំងឪ*

នាថ្ងៃទី៩ និងថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៦ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ (ខេត្តកំពង់ចាមនិងខេត្តត្បូងឃ្មុំ) ដឹកនាំដោយឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភានិងជាប្រធានក្រុម បានអញ្ជើញចុះជួបសំណេះសំណាលជាបន្តបន្ទាប់ជាមួយក្រុមប្រឹក្សាឃុំ មន្ត្រីរាជការ និងប្រជាពលរដ្ឋ សរុបចំនួន ៧៥៤នាក់ នៅក្នុងក្រុង និងស្រុកទាំង៧ នៅក្នុងខេត្តត្បូងឃ្មុំ រួមមាន ក្រុងសួង ស្រុកមេមត់ ស្រុកពញាក្រែក ស្រុកអូររាំងឪ ស្រុកត្បូងឃ្មុំ ស្រុកតំបែរ និងស្រុកក្រូចឆ្មារ។

នៅគ្រប់ពិធីសំណេះសំណាល **ឯកឧត្តមប្រធានក្រុមភូមិភាគទី២** បានជម្រាបជូនៈ ប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានិង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** អំពីកិច្ចដំណើរការការងារព្រឹទ្ធសភា ការទទួលយក និងលទ្ធផលដំណោះស្រាយសំណូមពររបស់អង្គបោះឆ្នោត និងអំពីសភាពការណ៍នៅតាមបណ្តោយព្រំប្រទល់កម្ពុជា-ថៃ ដែលបាននិងកំពុងកើតមានរហូតមកដល់ពេលបច្ចុប្បន្ន។

ឯកឧត្តមបានរំឭកពីប្រវត្តិសាស្ត្រនៃទំនាក់ទំនងរវាងកម្ពុជា-ថៃ និងមូលហេតុដែលបង្កឱ្យមានឧប្បត្តិហេតុនៅតាមព្រំប្រទល់ ដោយសង្កត់ធ្ងន់លើការមិនគោរពតាមស្មារតីឯកសារគតិយុត្តដែលប្រទេសទាំងពីរបានឯកភាពគ្នា ជាពិសេសសន្ធិសញ្ញាឆ្នាំ១៩០៤និងអនុសញ្ញាឆ្នាំ១៩០៧ ដែលមានភ្ជាប់ផែនទីឧបសម្ព័ន្ធ ធម្មនុញ្ញអង្គការសហប្រជាជាតិ ធម្មនុញ្ញអាស៊ាន និងច្បាប់អន្តរជាតិ ដោយភាគីថៃ និងសកម្មភាពឈ្លានពានយ៉ាងគឃ្លើនព្រៃផ្សៃលើបូរណភាពទឹកដីកម្ពុជា បើទោះជាមានការព្រមព្រៀងគ្នាលើការឈប់បាញ់និងលើគោលការណ៍មួយចំនួន ដើម្បីបន្ធូរបន្ថយភាពតានតឹងសំដៅរិះរកដំណោះស្រាយវិបត្តិដោយសន្តិវិធីយ៉ាងណាក៏ដោយ។ ជាមួយគ្នានោះ ឯកឧត្តមក៏បានរំលេចអំពីល្បិចកលដ៏ខ្មៅងងឹតរបស់ប្រទេសថៃ ក្នុងការបង្កអស្ថិរភាពនៅតាមបណ្តោយព្រំប្រទល់រវាងប្រទេសទាំងពីរ និងសុច្ឆន្ទៈរបស់កម្ពុជាក្នុងការរិះរកដំណោះស្រាយតាមរយៈការចរចាដោយសន្តិវិធី ជៀសវាងការប្រើកម្លាំង ដើម្បីសុខុមាលភាព និងសន្តិភាពសម្រាប់ប្រជាជនទាំងពីរ(កម្ពុជា-ថៃ)។

**ឯកឧត្តមប្រធានក្រុមភូមិភាគទី២** បានសម្តែងនូវមោទនភាពជាតិខ្ពស់ចំពោះការរួបរួមសាមគ្គី ឯកភាពជាតិជាធ្លុងមួយរបស់បងប្អូនប្រជាពលរដ្ឋគ្រប់និន្នាការនយោបាយ គ្រប់ស្រទាប់វណ្ណៈ ទាំងក្នុងនិងក្រៅប្រទេស ជាពិសេសបងប្អូនប្រជាពលរដ្ឋទាំងអស់នៅក្នុងខេត្តត្បូងឃ្មុំ ដែលបានផ្តល់នូវការគាំទ្រទាំងកម្លាំងកាយ ចិត្ត និងសម្ភារៈ ដល់




*លោកជំទាវបណ្ឌិត អ៊ុក ម៉ាលី ឡើងមានយោបល់ក្នុងអង្គពិធី*

វីរយុទ្ធជននៅសមរភូមិនិងបងប្អូនប្រជាជនភៀសសឹក ព្រមទាំងបានអំពាវនាវដល់បងប្អូនបន្តរួបរួមសាមគ្គី ឯកភាពជាតិជាធ្លុងមួយ និងមានជំនឿជឿជាក់លើការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ** ប្រធានព្រឹទ្ធសភា និងសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីកម្ពុជាក្នុងការចាត់វិធានការការពារបូរណភាពទឹកដី សុខសន្តិភាព និងការអភិវឌ្ឍប្រទេសជាតិ។

**ឯកឧត្តមប្រធានក្រុមភូមិភាគទី២** បានផ្តាំផ្ញើដល់អាជ្ញាធរ និងបងប្អូនប្រជាពលរដ្ឋទាំងអស់នៅមូលដ្ឋាន ឱ្យមានការប្រុងប្រយ័ត្នខ្ពស់ចំពោះរោហារសាស្ត្រអុជអាលបំបែកបំបាក់សង្គមជាតិរបស់ជនអគតិមួយចំនួន ជាពិសេសសកម្មភាពរបស់ជនក្បត់តជំនាន់ ព្រមទាំងពង្រឹងមហាសាមគ្គីជាតិកាន់តែរឹងមាំថែមទៀត នៅក្នុងកាលៈទេសៈដែលប្រទេសជាតិមាតុភូមិកំពុងប្រឈមនឹងហានិភ័យនៃអំពើឈ្លានពានរបស់ប្រទេសថៃ។

ឯកឧត្តមបានគូសបញ្ជាក់ថា «កម្ពុជាជាប្រទេសដែលស្រឡាញ់សន្តិភាព ចង់រស់នៅប្រកបដោយសន្តិសហវិជ្ជមានជាមួយបណ្តាប្រទេសទាំងអស់នៅក្នុងពិភពលោក។ ក៏ប៉ុន្តែសូមកុំយល់ច្រឡំថា ការស្រឡាញ់សន្តិភាពរបស់កម្ពុជាមិនមានន័យថា ជាការបោះបង់សិទ្ធិអធិបតេយ្យក្នុងការការពារបូរណភាពដែនដីរបស់ខ្លួននោះទេ»។

ជាទីបញ្ចប់ **ឯកឧត្តមប្រធានក្រុមភូមិភាគទី២** បានចែកជូនសម្ភារៈ និងថវិកាមួយចំនួនដល់សមាជិក សមាជិកាអង្គបោះឆ្នោត និងមន្ត្រីរាជការ ដែលមានវត្តមាននៅក្នុងកិច្ចជំនួបទាំងអស់ ព្រមទាំងបានយកថ្នាំពេទ្យមួយចំនួនចែកជូនដល់គ្រប់មន្ទីរពេទ្យបង្អែកស្រុកទាំង៦ នៅក្នុងខេត្តត្បូងឃ្មុំផងដែរ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*ឯកឧត្តម ស៊ាក ឡេង ឡើងមានយោបល់ក្នុងអង្គពិធី*





*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញចែកសម្ភារៈនិងថវិកាមួយចំនួនជូនដល់សមាជិក សមាជិកាអង្គបោះឆ្នោត នៅស្រុកពញាក្រែក នៅស្រុកតំបែរ*





*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញប្រគល់ថ្នាំពេទ្យ និងថតរូបអនុស្សាវរីយ៍ជាមួយក្រុមប្រឹក្សាឃុំ និងមន្ត្រីរាជការ នៅស្រុកក្រូចឆ្មារ*

# ឯកឧត្តម អ៊ុច បូរិទ្ធ អនុញ្ញាតឱ្យប្រធានសភាពាណិជ្ជកម្ម និងឧស្សាហកម្មរបស់ ទីក្រុង Incheon ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ

នៅព្រឹកថ្ងៃចន្ទ ទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអនុញ្ញាតឱ្យ ឯកឧត្តម **ផាក ជូ បុង** (Park Joo Bong) ប្រធានសភាពាណិជ្ជកម្មនិងឧស្សាហកម្មរបស់ទីក្រុងIncheonនិងជាអគ្គនាយកក្រុមហ៊ុន Daejoo KC Groupនិងជាទីប្រឹក្សា**ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា។

នៅក្នុងឱកាសនោះ **ឯកឧត្តមអនុប្រធានទី១** បានជម្រាបអំពីគោលនយោបាយសន្តិភាពនិងអភិវឌ្ឍន៍របស់កម្ពុជានិងបានអរគុណ ឯកឧត្តម **ផាក ជូ បុង** ដែលបាននិងកំពុងខិតខំកៀរគរវិនិយោគិននៃសាធារណរដ្ឋកូរ៉េ មកវិនិយោគនៅកម្ពុជា ដែលជាការរួមចំណែកដ៏សំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជានិងការពង្រឹងពង្រីកចំណងមិត្តភាពនិងសហប្រតិបត្តិការរវាងប្រទេស និងប្រជាជនទាំងពីរ (កម្ពុជានិងសាធារណរដ្ឋកូរ៉េ)។

នៅក្នុងជំនួបនោះ ឯកឧត្តម **ផាក ជូ បុង** បានបញ្ជាក់ថា ទន្ទឹមនឹងការខិតខំពង្រីកការវិនិយោគរវាងប្រទេសទាំងពីរ ឯកឧត្តមក៏បានខិតខំផ្សព្វផ្សាយនៅសាធារណរដ្ឋកូរ៉េពីសភាពការណ៍ពិត សក្តានុពលសេដ្ឋកិច្ច និងការរីកចម្រើនរបស់កម្ពុជា។ ជាក់ស្តែង នៅក្នុងដំណើរទស្សនកិច្ចលើកនេះ ឯកឧត្តមបានអញ្ជើញ លោកស្រី **គិម មី អាអ៊ី** (Kim Mi Ae) អគ្គនាយកទូរទស្សន៍ OBS Gyeongin ដែលជាស្ថានីយទូរទស្សន៍ដ៏ធំមួយនៅកូរ៉េ មកជាមួយផងដែរ។ ឯកឧត្តម **ផាក ជូ បុង** បានបន្ថែមថា តាមរយៈស្ថានីយទូរទស្សន៍នេះ ឯកឧត្តមសង្ឃឹមថា វិស័យទេសចរណ៍ក៏ដូចជាសហប្រតិបត្តិការពាណិជ្ជកម្ម សេដ្ឋកិច្ច រវាងប្រទេសទាំងពីរ កាន់តែរីកចម្រើនថែមទៀតជាក់ជាពុំខាន។

ឯកឧត្តម **ផាក ជូ បុង** ក៏បានជូនព័ត៌មានផងដែរថា នៅក្នុងខែមីនា ឆ្នាំ២០២៦ លោកនឹងដឹកនាំគណៈប្រតិភូវិនិយោគិនមកកម្ពុជា រួមជាមួយនឹងអ្នកសារព័ត៌មាននិងថ្នាក់ដឹកនាំស្ថានីយទូរទស្សន៍ធំៗចំនួនបី មកបំពេញទស្សនកិច្ចនៅកម្ពុជាម្តងទៀត។ ឯកឧត្តមក៏កំពុងសហការរៀបចំដំណើរទស្សនកិច្ចគណៈប្រតិភូសភាពាណិជ្ជកម្មនិងវិនិយោគកម្ពុជាដឹកនាំដោយ ឯកឧត្តម **ស៊ុន ចាន់ថុល** ទៅសាធារណរដ្ឋកូរ៉េ ដើម្បីចូលរួមពិធីបង្ហាញផ្លូវវិនិយោគ (Investment Road Show) នៅសាធារណរដ្ឋកូរ៉េផងដែរ៕





*ឯកឧត្តម ផាក ជូ បុង និងឯកឧត្តម អ៊ុច បូរិទ្ធ*



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសមនិងពិភាក្សាការងារ*

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តម អ៊ុច បូររិទ្ធ អនុញ្ញាតឱ្យប្រធានក្រុមមិត្តភាពរដ្ឋសភាបារាំង-កម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ



ឯកឧត្តម តូម៉ាស់ ឡាំ និងឯកឧត្តម អ៊ុច បូររិទ្ធ



ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសមនិងពិភាក្សាការងារ

នាព្រឹកថ្ងៃអង្គារ ទី២៤ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ ព្រឹទ្ធសភា ប្រធានក្រុមមិត្តភាពកម្ពុជា-បារាំង ប្រធានក្រុមសភាជាតិកម្ពុជា នៃសភាប្រើភាសាបារាំង (APF )និងជាអនុប្រធានសភាប្រើភាសាបារាំង (APF) បានអនុញ្ញាតឱ្យ ឯកឧត្តម **តូម៉ាស់ ឡាំ** (Thomas LAM) តំណាងរាស្ត្រ នៃរដ្ឋសភាបារាំង និងជាប្រធានក្រុមមិត្តភាពរដ្ឋសភាបារាំង-កម្ពុជា ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា។

ក្នុងឱកាសនោះ **ឯកឧត្តមអនុប្រធានទី១** បានជម្រាបជូនអំពីសភាពការណ៍ជុំវិញការឈ្លានពានរបស់ថៃមកលើបូរណភាពទឹកដីកម្ពុជានិងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការរួមរស់ដោយសន្តិសហវិជ្ជមានជាមួយបណ្តាប្រទេសទាំងអស់ក្នុងពិភពលោក និងសុឆន្ទៈរបស់កម្ពុជាក្នុងការដោះស្រាយរាល់វិវាទដោយសន្តិវិធី ដោយផ្អែកលើឯកសារគតិយុត្តដែលទទួលស្គាល់ដោយទ្វេភាគី និងជាអន្តរជាតិ។ នៅក្នុងស្មារតីនេះ ឯកឧត្តមបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមមិត្តភាពសភាបារាំង-កម្ពុជានិងរដ្ឋាភិបាលបារាំង ដែលបានផ្តល់ការគាំទ្រដល់រាល់ការខិតខំប្រឹងប្រែងរបស់កម្ពុជាដោយផ្អែកលើច្បាប់ធម្មនុញ្ញអង្គការសហប្រជាជាតិនិងធម្មនុញ្ញអាស៊ាន ដើម្បីឈានទៅដល់ដំណោះស្រាយមួយប្រកបដោយចីរភាព។

នៅក្នុងស្មារតីពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការរវាងសភានិយាយភាសាបារាំង យោងតាមការសម្រេចដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ព្រឹទ្ធសភាកម្ពុជានឹងទទួលរៀបចំធ្វើសិក្ខាសាលានិងកិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំងចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២៦ នៅខេត្តសៀមរាប និងកិច្ចប្រជុំកំពូលអង្គការហ្វ្រង់កូហ្វូនីលើកទី២០ នាខែវិច្ឆិកា ឆ្នាំ២០២៦។

នៅក្នុងជំនួបនោះ ឯកឧត្តម **តូម៉ាស់ ឡាំ** បានថ្លែងអំណរគុណ**ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** ដែលបានចំណាយពេលសម្រាប់ជំនួបនេះ ដ្បិតរយៈពេលខ្លីក៏ពិតមែន ប៉ុន្តែមានសារៈសំខាន់សម្រាប់កិច្ចខិតខំបន្តពង្រឹងនិងពង្រីកចំណងមិត្តភាពរវាងសភាបារាំងនិងព្រឹទ្ធសភាកម្ពុជា ក៏ដូចជារវាងប្រទេសទាំងពីរឱ្យកាន់តែរឹងមាំបន្ថែមទៀត។ ទន្ទឹមនឹងនេះ ឯកឧត្តមឯកភាពឱ្យមានការផ្លាស់ប្តូរទស្សនកិច្ចរវាងស្ថាប័ននីតិប្បញ្ញត្តិទាំងពីរជាទៀងទាត់ ដែលជាឱកាសដ៏មានសារៈសំខាន់ក្នុងការផ្លាស់ប្តូរមតិយោបល់ជុំវិញបញ្ហាក្នុងតំបន់និងពិភពលោក ដែលជាក្តីកង្វល់និងជាផលប្រយោជន៍របស់ប្រទេសទាំងពីរ។ ឯកឧត្តមបានបន្ថែមថា នៅក្នុងកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ នៅកម្ពុជានាពេលខាងមុខ សភានិងរដ្ឋាភិបាលបារាំង នឹងចូលរួមពិភាក្សា និងលើកឡើងនូវការផ្តួចផ្តើមគំនិតជំរុញសហប្រតិបត្តិការសេដ្ឋកិច្ច នយោបាយនិងវប្បធម៌និងលើកកម្ពស់សន្តិភាព ស្ថិរភាព នៅក្នុងតំបន់ និងពិភពលោក៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន

# គណៈកម្មាធិការប្រតិបត្តិនៃសភាប្រើភាសាបារាំងសម្រេចបញ្ចូលរបាយការណ៍ ស្តីពី អរិភាពរវាងកម្ពុជានិងថៃ ទៅក្នុងរបាយការណ៍គណៈកម្មការនយោបាយ នៃសភាប្រើភាសាបារាំង




*ឯកឧត្តម អ៊ុច បូរិទ្ធ ចូលរួមកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ នៃសភាប្រើភាសាបារាំង (APF)*

គណៈកម្មាធិការប្រតិបត្តិនៃសភាប្រើភាសាបារាំង បានស្វាគមន៍និងបង្ហាញនូវសាមគ្គីភាពចំពោះបទអន្តរាគមន៍របស់ **ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** និងបានសម្រេចបញ្ចូលរបាយការណ៍ស្តីពី អរិភាពរវាងកម្ពុជានិងថៃ ទៅក្នុងរបាយការណ៍គណៈកម្មការនយោបាយ នៃសភាប្រើភាសាបារាំង (APF) ដែលត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័ររបស់ APF ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៦។

ការសម្រេចនេះធ្វើឡើង បន្ទាប់ពីឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា, ប្រធានក្រុមសភាជាតិកម្ពុជា នៃសភាប្រើភាសាបារាំង (APF) និងជាអនុប្រធានសភាប្រើភាសាបារាំង ថ្លែងបទអន្តរាគមន៍ស្តីពី សភាពការណ៍វិវត្តនៃជម្លោះព្រំដែនកម្ពុជា-ថៃ និងទង្វើបំពានច្បាប់អន្តរជាតិរបស់រដ្ឋាភិបាលក្រុងបាងកក ជាពិសេសយោធាថៃ ដែលបានឈ្លានពានកម្ពុជាយ៉ាងគឃ្លើន មិនគោរពច្បាប់អន្តរជាតិ នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិនៃសភាប្រើភាសាបារាំង (APF) នៅសភាប្រទេសម៉ុងតេណេហ្គ្រោ កាលពីថ្ងៃទី៣០ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៦ ក្រោមអធិបតីភាពឯកឧត្តម **ហ៊ីឡារីយ៉ុង អេតុង** (Hilarion ETONG) ប្រធានសភាប្រើភាសាបារាំង។

នៅក្នុងបទអន្តរាគមន៍ចំពោះមុខអង្គប្រជុំ ក្នុងរបៀបវារៈស្តីពី «ការពិនិត្យពិច័យលើស្ថានភាពនយោបាយដ៏ស្មុគស្មាញក្នុងតំបន់ប្រើប្រាស់ភាសាបារាំង» ឯកឧត្តម **អ៊ុច បូរិទ្ធ** បានជម្រាបអំពីសភាពការណ៍វិវត្តនៃជម្លោះព្រំដែនកម្ពុជា-ថៃ ដែលមានខ្លឹមសារសង្ខេបសំខាន់ៗដូចតទៅនេះ៖

**ស្ថានការណ៍នៅតាមបណ្តោយព្រំដែន រវាងព្រះរាជាណាចក្រកម្ពុជានិងព្រះរាជាណាចក្រថៃ បានធ្លាក់ចុះដុនដាបយ៉ាងខ្លាំង។ ការវិវត្តនេះកាន់តែគួរឱ្យព្រួយបារម្ភ ដោយសារតែគោលការណ៍និងលិខិតុបករណ៍អន្តរជាតិដែលមានស្រាប់ បង្កើតឡើងក្នុងគោលបំណងបង្ការការរីករាលដាលនៃជម្លោះ មិនត្រូវបានគោរពឱ្យបានពេញលេញ ឬអនុវត្តឱ្យមានប្រសិទ្ធភាពនោះទេ។**

ក្នុងកម្រិតតំបន់និងអន្តរជាតិ ធម្មនុញ្ញអាស៊ាននិងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ បានចែងយ៉ាងច្បាស់អំពីការដោះស្រាយវិវាទដោយសន្តិវិធី និងការគោរពអធិបតេយ្យភាព។ ក្នុងកម្រិតទ្វេភាគី សន្ធិសញ្ញាឆ្នាំ១៩០៤ អនុសញ្ញាឆ្នាំ១៩០៧ ព្រមទាំងផែនទីឧបសម្ព័ន្ធភ្ជាប់ជាមួយឯកសារអស់ទាំងនេះ បង្កើតបានជាបណ្តុំឧបករណ៍គតិយុត្តដែលមានអានុភាពខាងច្បាប់បង្ខំឱ្យអនុវត្ត ដែលត្រូវបានទទួលស្គាល់ទាំងក្នុងកម្រិតទ្វេភាគីនិងកម្រិតអន្តរជាតិ ហើយដែលបានកំណត់យ៉ាងច្បាស់លាស់អំពីការកំណត់ព្រំដែនរវាងប្រទេសទាំងពីរ។

លើសពីនេះ យន្តការរួមត្រូវបានបង្កើតឡើង ដើម្បីគ្រប់គ្រងភាពតានតឹងនៅលើទីតាំងផ្ទាល់រួមមាន៖ គណៈកម្មាធិការព្រំដែនទូទៅ (GBC) ដែលផ្តោតលើការសម្រប-

សម្រួលនិងបង្ការឧប្បត្តិហេតុនានា និងគណៈកម្មការចម្រុះព្រំដែន (JBC) ទទួលបន្ទុកទិដ្ឋភាពបច្ចេកទេសនៃការបោះបង្គោលព្រំដែន។ ជាមួយគ្នានេះ ក៏មានអនុស្សរណៈនៃការយោគយល់គ្នា (MoU) ដែលត្រូវបានចុះហត្ថលេខារវាងប្រទេសទាំងពីរ ដោយមានបញ្ជាក់ពីនីតិវិធីនៃកិច្ចសហ-ប្រតិបត្តិការ ការពិគ្រោះយោបល់ និងការគ្រប់គ្រងស្ថានភាពរសើបនៅក្នុងតំបន់ព្រំដែន។

ទោះបីជាមានយន្តការទាំងនេះក៏ដោយ ក៏ឧប្បត្តិហេតុនានានៅតែបន្តកើតមានជាញឹកញាប់ ហើយហានិភ័យនៃការរីករាលដាលជម្លោះនៅតែមានកម្រិតខ្ពស់។ មូលហេតុគឺដោយសារការមិនគោរពរបស់ភាគីថៃ ចំពោះឯកសារគតិយុត្តដែលបានរៀបរាប់ខាងលើ ព្រមទាំងការព្យាយាមជាឯកតោភាគីក្នុងការផ្លាស់ប្ដូរស្ថានភាពដើម (Status Quo) នៃដែនដី ដោយផ្អែកលើផែនទីដែលរៀបចំឡើងជាឯកតោភាគីដោយភាគីថៃ ដែលគ្មានមូលដ្ឋានច្បាប់ព្រមព្រៀងគ្នា ឬការទទួលស្គាល់ជាអន្តរជាតិនោះឡើយ។ ការងាកចេញពីក្របខ័ណ្ឌនេះ បានឈានដល់កម្រិតគ្រោះថ្នាក់បំផុត ក្នុងអំឡុងពេលនៃប្រតិបត្តិការយោធា ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី៧ ដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ហើយកាន់តែធ្ងន់ធ្ងរថែមទៀត បន្ទាប់ពីការចូលជាធរមាននៃបទឈប់បាញ់ ដែលត្រូវបានអនុម័តក្នុងកិច្ចប្រជុំវិសាមញ្ញនៃគណៈកម្មាធិការព្រំដែនទូទៅ (GBC) កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥។

ដោយមិនគោរពតាមកិច្ចព្រមព្រៀងនេះ កងទ័ពថៃបានបន្តលុកលុយចូលក្នុងទឹកដីកម្ពុជារហូតដល់សាងសង់ឧបសគ្គផ្សេងៗ រួមមាន ខ្សែលួសបន្លា និងទូកុងតឺន័រ រាំងការចូលទៅកាន់លំនៅឋានរបស់ប្រជាពលរដ្ឋស៊ីវិលនិងធ្វើឱ្យការជម្លៀសប្រជាជនជាច្រើននៅតែបន្តអូសបន្លាយ។ អ្វីដែលកាន់តែធ្ងន់ធ្ងរជាងនេះ គឺអំពើអស់ទាំងនេះបានភ្ជាប់មកជាមួយនឹងវត្តមាននិងការគ្រប់គ្រងត្រួតត្រាជាបន្តបន្ទាប់នូវតំបន់មួយចំនួនដែលស្ថិតនៅក្នុងទឹកដីកម្ពុជាយ៉ាងច្បាស់ ដែលនេះបង្កើតឱ្យមានជាការកាន់កាប់ដោយខុសច្បាប់ ព្រមទាំងសកម្មភាពបំផ្លិចបំផ្លាញលំនៅឋាន និងហេដ្ឋា-រចនាសម្ព័ន្ធស៊ីវិល។

**ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានបន្ថែមថា៖ លើសពីសោកនាដកម្មមនុស្សជាតិ ព្រលឹងវប្បធម៌កម្ពុជា ក៏ទទួលរងផលប៉ះពាល់ផងដែរ។ ប្រទេសជាតិយើងខ្ញុំមានការឈឺចាប់យ៉ាងខ្លាំង ចំពោះការបំផ្លិចបំផ្លាញដល់ទីតាំងនិងរូបសំណាកបេតិកភណ្ឌនានា។ រូបសំណាកព្រះវិស្ណុ និងបុរាណដ្ឋានជាច្រើន រួមទាំងប្រាសាទព្រះវិហារ ដែលជានិមិត្តរូបសកលនៃសន្តិភាព និងទេពកោសល្យរបស់មនុស្សជាតិដែលត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូ ត្រូវបានរងការខូចខាតជាដំណំ។

ការខូចខាតទាំងនេះមិនត្រឹមតែជាការបាត់បង់ក្នុងកម្រិតជាតិប៉ុណ្ណោះទេ ប៉ុន្តែជាការបង្ករបួសស្នាមដល់កេរ-ដំណែលរួមរបស់មនុស្សជាតិផងដែរ។ ការវាយប្រហារលើបេតិកភណ្ឌវប្បធម៌ គឺជាការធ្វើឱ្យរង្គោះរង្គើដល់ការចងចាំជាច្រើនសតវត្ស អត្តសញ្ញាណនៃប្រជាជាតិមួយ និងជាទ្រព្យសម្បត្តិដែលយើងមានកាតព្វកិច្ចរួមគ្នាក្នុងការផ្ទេរទៅឱ្យអ្នកជំនាន់ក្រោយ។

**ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានសង្កត់ធ្ងន់ថា សកម្មភាពបែបនេះ គឺជាទង្វើផ្ទុយនឹងគោលការណ៍មូលដ្ឋានដែលមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ជាពិសេសគោលការណ៍សមភាពអធិបតេយ្យរបស់រដ្ឋទាំងអស់ ការគោរពបូរណភាពទឹកដី និងការមិនប្រើប្រាស់ ឬគំរាមកំហែងដោយកម្លាំង។ ហេតុដូច្នេះ សំណួរដ៏សំខាន់មួយត្រូវបានចោទសួរឡើងថា៖ តើយើងកំពុងមើលឃើញនូវការកើតមានឡើងនូវអ្វីដែលហៅថា «សណ្ដាប់ធ្នាប់ថ្មី» ដែលច្បាប់កំណត់ដោយអ្នកខ្លាំង ឬការកើតឡើងវិញនៃនយោបាយបង្ខំឱ្យទទួលយកស្ថានភាពដែលបានបង្កើតរួច ដែលជាសំណល់ដ៏សោកសៅនៃបទបញ្ជាផ្អែកលើ «ការបង្ខិតបង្ខំ ជាជាងផ្អែកលើច្បាប់» ?

ជាមួយគ្នានេះ ឯកឧត្តមបានអំពាវនាវចំពោះសភាប្រើភាសាបារាំង តាមរយៈការទូតសភា ចូលរួមចំណែកដល់ការថែរក្សាសន្តិភាពនិងស្ថិរភាពក្នុងតំបន់ និងបានអះអាងថា ព្រះរាជាណាចក្រកម្ពុជាសូមបញ្ជាក់សាជាថ្មី នៅចំពោះមុខសភាប្រើភាសាបារាំងនូវគោលការណ៍គ្រឹះ៖ មិនប្រើប្រាស់កម្លាំងទ័ព ការគោរពអធិបតេយ្យនិងបូរណភាពទឹកដីនៃរដ្ឋនានា ជំរុញឱ្យមានការគោរពបទឈប់បាញ់ ក៏ដូចជាការលើកកម្ពស់ការប្រើប្រាស់យន្តការដែលមានស្រាប់ ប្រកបដោយសន្តិវិធីនិងការសន្ទនានៅក្នុងស្មារតីទទួលខុសត្រូវភាពអត់ធ្មត់និងកិច្ចសហប្រតិបត្តិការ៕

ប្រភព៖ ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

# ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា៖ ព្រឹទ្ធសភានឹងបន្តតាមដាន និងគាំទ្ររាល់យន្តការច្បាប់ ដែលបង្កភាពងាយស្រួលដល់ការវិនិយោគ រួមទាំងអាជីវកម្មខ្នាតតូច




*ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អនុប្រធានទី២ព្រឹទ្ធសភា ជួបពិភាក្សាជាមួយថ្នាក់ដឹកនាំសួនឧស្សាហកម្ម Samanea*

នារសៀលថ្ងៃពុធ ទី២៨ ខែមករា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញចុះទស្សនកិច្ចសិក្សាស្វែងយល់ពីខ្សែច្រវាក់ផលិតកម្មនិងបច្ចេកវិទ្យាឧស្សាហកម្ម នៅសួនឧស្សាហកម្ម Samanea។

ដំណើរទស្សនកិច្ចនោះ មានគោលបំណងពង្រឹងសហប្រតិបត្តិការរវាងស្ថាប័ននីតិប្បញ្ញត្តិនិងវិស័យឯកជន ក៏ដូចជាការពិនិត្យមើលវឌ្ឍនភាពនៃវិស័យឧស្សាហកម្មក្នុងស្រុកដែលកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចជាតិ។

ក្នុងឱកាសនោះ **ឯកឧត្តមបណ្ឌិត** ក៏បានលើកឡើងពីការយកចិត្តទុកដាក់ និងចក្ខុវិស័យរបស់ **សម្តេចតេជោ** ប្រធានព្រឹទ្ធសភានិងជាអតីតនាយករដ្ឋមន្ត្រី តែងតែផ្តល់អាទិភាពខ្ពស់លើការធ្វើទំនើបកម្មឧស្សាហកម្ម និងការរុញច្រានកម្ពុជាឱ្យចាកចេញពីប្រទេសឧស្សាហកម្ម ដែលប្រើប្រាស់កម្លាំងពលកម្មច្រើន ទៅជាប្រទេសឧស្សាហកម្មដែលប្រើប្រាស់ជំនាញនិងបច្ចេកវិទ្យា។

តំណាងសួនឧស្សាហកម្ម Samanea បានបញ្ជាក់ថា វត្តមានរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភានៅពេលនោះ គឺជាកិត្តិយសដ៏ខ្ពង់ខ្ពស់និងជាការលើកទឹកចិត្តយ៉ាងខ្លាំងដល់វិនិយោគិនក្នុងស្រុក ឱ្យបន្តខិតខំពង្រីកសមត្ថភាពផលិតកម្ម ដើម្បីចូលរួមចំណែកសម្រេចឱ្យបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

ជាចុងក្រោយ **ឯកឧត្តមបណ្ឌិត** បានកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់ក្រុមហ៊ុន ដែលបាននាំមកនូវបច្ចេកវិទ្យាថ្មីៗនិងការបង្កើតការងារជូនដល់ពលរដ្ឋ។ **ឯកឧត្តមបណ្ឌិត** បានសង្កត់ធ្ងន់ថា ព្រឹទ្ធសភានឹងបន្តតាមដាន និងគាំទ្ររាល់យន្តការច្បាប់ទាំងឡាយណាដែលបង្កភាពងាយស្រួលដល់ការវិនិយោគ ដើម្បីធានាបាននូវការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាបន្ន៕

ខ្លឹមសារ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន




*ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អញ្ជើញទស្សនកិច្ចខ្សែច្រវាក់ផលិតកម្ម និងថតរូបអនុស្សាវរីយ៍*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ជួបសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធ ក្នុងខណ្ឌចំការមន ខណ្ឌទួលគោក ខណ្ឌឫស្សីកែវ និងខណ្ឌច្បារអំពៅ




*ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អញ្ជើញសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ និងអាជ្ញាធរមូលដ្ឋាន*

ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ (រាជធានីភ្នំពេញ) ដឹកនាំដោយ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភានិងជាប្រធានក្រុម បានទទួលជួបសំណេះសំណាលជាបន្តបន្ទាប់ជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធ មកពីសង្កាត់ទាំង៥ក្នុងខណ្ឌចំការមនចំនួន៧៥នាក់ សង្កាត់ទាំង១០ក្នុងខណ្ឌទួលគោកចំនួន៩៩នាក់ សង្កាត់ទាំង៧ក្នុងខណ្ឌឫស្សីកែវចំនួន៦៤នាក់ និងមកពីសង្កាត់ទាំង៨ក្នុងខណ្ឌច្បារអំពៅចំនួន៨០នាក់ នារសៀលថ្ងៃទី២៩ ខែមករា ថ្ងៃទី១២ ទី១៩ និងថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៦ នៅវិមានព្រឹទ្ធសភា។

នៅគ្រប់ពិធីសំណេះសំណាល **ឯកឧត្តមប្រធានក្រុមភូមិភាគទី១** បានផ្តល់យោបល់ថា គ្រប់មូលដ្ឋានក្នុងរាជធានីភ្នំពេញ បន្តជំរុញនិងបង្កភាពងាយស្រួលដល់វិស័យទេសចរណ៍ អាជីវកម្មខ្នាតតូច និងគាំទ្រអ្នកវិនិយោគនៅក្នុងមូលដ្ឋានរបស់ខ្លួន ជាមួយនឹងការពង្រឹងសណ្តាប់ធ្នាប់សាធារណៈ ថែរក្សាសោភណភាពតាមដងផ្លូវ ដែលកិច្ចការអាទិភាពចំពោះមុខ គឺការរៀបចំសណ្តាប់ធ្នាប់ក្រុង និងគ្រប់គ្រងយ៉ាងណាកុំឱ្យមានការឆបោកតាមអនឡាញ។ ឯកឧត្តមបានបញ្ជាក់ផងដែរថា កត្តាសាមគ្គីភាពផ្ទៃក្នុងដ៏រឹងមាំរបស់ជាតិ សុខសន្តិភាព ការទាក់ទាញទេសចរ និងវិនិយោគិន គឺជាអាទិភាពនៃវឌ្ឍនភាពរបស់ជាតិ និងប្រជាជនយើងដែលប្រាថ្នាចង់បាន។

នៅចុងបញ្ចប់កម្មវិធី **ឯកឧត្តមបណ្ឌិត** បានផ្តាំផ្ញើដល់សមាជិកក្រុមប្រឹក្សាសង្កាត់ និងអ្នកចូលរួមត្រូវបន្តយកចិត្តទុកដាក់តាមដាននិងអនុវត្តនូវការសន្យា ដែលសមាជិកក្រុមប្រឹក្សាសង្កាត់បានសន្យានាអំឡុងពេលបោះឆ្នោតកន្លងទៅ៕

ប្រភព៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា

រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន



*ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អញ្ជើញថតរូបអនុស្សាវរីយ៍ជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ អាជ្ញាធរមូលដ្ឋាន ក្នុងខណ្ឌចំការមន*

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាយប់ថ្ងៃចន្ទ ទី២ ខែកុម្ភៈ ឆ្នាំ២០២៦ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានរៀបចំពិធីលៀងសាយភោជន៍ជូនជាកិត្តិយសដល់គណៈប្រតិភូព្រឹទ្ធសភាប៉ាគីស្ថាន ដឹកនាំដោយឯកឧត្តម **ស៊ីយ៉េដ យូសាហ្វ រ៉ាសា ហ្គីឡានី** (Syed Yusuf Raza Gillani) ប្រធានព្រឹទ្ធសភា នៃសាធារណរដ្ឋអ៊ិស្លាមប៉ាគីស្ថាន នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា។





❈នាព្រឹកថ្ងៃពុធ ទី៤ ខែកុម្ភៈ ឆ្នាំ២០២៦ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទទួលទានអាហារពេលព្រឹក ជាមួយឯកឧត្តម **ស៊ីយ៉េដ យូសាហ្វ រ៉ាសា ហ្គីឡានី** (Syed Yusuf Raza Gillani) ប្រធានព្រឹទ្ធសភា នៃសាធារណរដ្ឋអ៊ិស្លាមប៉ាគីស្ថាន នៅសណ្ឋាគារ ក្នុងរាជធានីភ្នំពេញ។

❈នាព្រឹកថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៦ ក្នុងព្រះបរមនាមព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទទួលបដិសណ្ឋារកិច្ចស្វាគមន៍ផ្លូវរដ្ឋនិងជំនួបសវនាការជាមួយឯកឧត្តម **តូ ឡឹម** អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម នៅព្រះបរមរាជវាំង។





❈នាល្ងាចថ្ងៃសុក្រ ទី៦ ខែកុម្ភៈ ឆ្នាំ២០២៦ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជានិងឯកឧត្តម **តូ ឡឹម** អគ្គលេខាធិការ នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបញ្ចុះបឋមសិលាសាងសង់សាលាមិត្តភាពកម្ពុជា-វៀតណាម នៅខណ្ឌដង្កោ រាជធានីភ្នំពេញ។

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាយប់ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៦ ក្នុងព្រះបរមនាម ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានរៀបចំពិធីលៀងសាយភោជន៍ជាផ្លូវរដ្ឋ ជូនឯកឧត្តម **តូ ឡឹម** អគ្គលេខាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា។





❈នាព្រឹកថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៦ នៅព្រះបរមរាជវាំង ក្នុងព្រះបរមនាមព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទទួលបដិសណ្ឋារកិច្ចស្វាគមន៍ឯកឧត្តម **ថងលុន ស៊ីសុលីត** អគ្គលេខាធិការបក្សប្រជាជនបដិវត្តន៍ឡាវ និងជាប្រធានរដ្ឋ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

❈នាថ្ងៃសៅរ៍ ទី៧ ខែកុម្ភៈ ឆ្នាំ២០២៦ ក្នុងព្រះបរមនាម ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានរៀបចំពិធីលៀងសាយភោជន៍ជាផ្លូវរដ្ឋ ជូនឯកឧត្តមបណ្ឌិត **ថងលុន ស៊ីសុលីត** អគ្គលេខាធិការ បក្សប្រជាជនបដិវត្តន៍ឡាវ និងជាប្រធានរដ្ឋ នៃសាធារណរដ្ឋ ប្រជាធិបតេយ្យប្រជាមានិតឡាវ នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា។





❈នាថ្ងៃសុក្រ ទី៣០ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ប្រធានក្រុមសភាជាតិកម្ពុជា នៃសភាប្រើភាសាបារាំង (APF)និងជាអនុប្រធាន APF បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា ចូលជួបពិភាក្សាការងារជាមួយ លោកជំទាវ Zdenka POPOVIC អនុប្រធានសភាម៉ុងតេណេហ្គ្រោ នៅការិយាល័យរបស់លោកជំទាវ ក្នុងសភានៃប្រទេសម៉ុងតេណេហ្គ្រោ។

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាថ្ងៃសៅរ៍ ទី៣១ ខែមករា ឆ្នាំ២០២៦ នៅសភាទីក្រុងប៉ូតហ្គោរីកា ប្រទេសម៉ុងតេណេហ្គ្រោ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ប្រធានក្រុមសភាជាតិកម្ពុជា នៃសភាប្រើភាសាបារាំង (APF)និងជាអនុប្រធាន APF បានអញ្ជើញជួបពិភាក្សាការងារជាមួយ ឯកឧត្តម **ហ៊ីឡារីយ៉ុង អេតុង** (Hilarion ETONG) ប្រធានសភាប្រើភាសាបារាំង និងជាអនុប្រធានទី១ នៃរដ្ឋសភាកាមេរូន។





❈នារសៀលថ្ងៃចន្ទ ទី២ ខែកុម្ភៈ ឆ្នាំ២០២៦ នៅអាកាសយានដ្ឋានអន្តរជាតិតេជោ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា ធ្វើមាតុភូមិនិវត្តន៍ បន្ទាប់ពីអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យនិងតាមដានប្រជាធិបតេយ្យ និងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិនៃសភាប្រើភាសាបារាំង (APF) នៅទីក្រុងប៉ូដហ្គោរីកា នៃសាធារណរដ្ឋម៉ុងតេណេហ្គ្រោ។

❈នាព្រឹកថ្ងៃសុក្រ ទី៦ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភានិងជាប្រធានក្រុមសភាជាតិកម្ពុជា នៃសភាប្រើភាសាបារាំង បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង ដែលនឹងប្រព្រឹត្តទៅនៅដើមខែឧសភា ឆ្នាំ២០២៦ នៅព្រះរាជាណាចក្រកម្ពុជា នាសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។






❈នាថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញសួរសុខទុក្ខ និងផ្តល់ជូនអំណោយជា អង្ករ មី ថ្នាំពេទ្យ ភេសជ្ជៈប៉ូវកម្លាំង និងថវិកាមួយចំនួន ដល់វីរកងទ័ពលោក **ធុល ធីម** អាយុ៥៥ឆ្នាំ ជាព្រឹន្ទបាលទោ មកពីកងអនុសេនាធំលេខ៣ វរសេនាតូចលេខ២១១ ប្រាសាទតាមាន់ធំ កំពុងសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យបង្អែកស្រុកបាជាយ ខេត្តកំពង់ចាម។

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នារសៀលថ្ងៃសុក្រ ទី២០ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញដឹកនាំកិច្ចប្រជុំត្រៀមរៀបចំសន្និសីទប្រធានសភា នៃអន្តរសភា (Inter-Parliamentary Speaker's Conference-ISC) លើកទី២ ដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ នៅបន្ទប់ប្រជុំឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា។





❈នារសៀលថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញធ្វើបាឋកថា ស្តីពី «ឱកាសនៃការកែច្នៃអាហារ» ដល់សាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅសាកល-វិទ្យាល័យភូមិន្ទភ្នំពេញ។

❈នារសៀលថ្ងៃទី២៧ ខែមករានិងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់ខុទ្ទកាល័យអនុប្រធានទី២ព្រឹទ្ធសភា ប្រចាំខែមករា និងលើកទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២៦ នៅបន្ទប់ប្រជុំខុទ្ទកាល័យអនុប្រធានទី២ព្រឹទ្ធសភា។





❈នាព្រឹកថ្ងៃទី២ និងយប់ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញទទួលបដិសណ្ឋារកិច្ចស្វាគមន៍និងជូនដំណើរនិវត្តន៍ ឯកឧត្តម **ស៊ីយ៉េដ យូសាហ្វ រ៉ាសា ហ្គីឡានី** ប្រធានព្រឹទ្ធសភា នៃសាធារណរដ្ឋអ៊ិស្លាមប៉ាគីស្ថាន នៅអាកាសយានដ្ឋានអន្តរជាតិតេជោ។

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នារសៀលថ្ងៃចន្ទ ទី២ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ ខឡ្យនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំប្រចាំខែជាមួយប្រធានគណៈកម្មការទាំង១០ ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ប្រធានក្រុមសមាជិកា និងប្រធានគណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា នៅបន្ទប់ប្រជុំខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា។





❈នារសៀលថ្ងៃអង្គារ ទី៣ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ ខឡ្យនា** អនុប្រធានទី២ព្រឹទ្ធសភានិងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ (រាជធានីភ្នំពេញ) បានអញ្ជើញដឹកនាំកិច្ចប្រជុំជាមួយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។

❈នាព្រឹកថ្ងៃសុក្រ ទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ ខឡ្យនា** អនុប្រធានទី២ព្រឹទ្ធសភានិងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ (រាជធានីភ្នំពេញ) បានអញ្ជើញចូលរួមពិធីបុណ្យគម្រប់៧ថ្ងៃ ឯកឧត្តម **គ្រួច ផាន** អតីតប្រធានក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ នៅខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។





❈នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ ខឡ្យនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញសួរ-សុខទុក្ខឯកឧត្តមបណ្ឌិត **អ៊ុំ រម្យណី** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងជាអតីតនាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) ដែលកំពុងសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យកាល់ម៉ែត។

# គណៈកម្មការទី១ព្រឹទ្ធសភា អញ្ជើញចុះស្វែងយល់ការងារពាក់ព័ន្ធនឹងវិស័យ ជាសមត្ថកិច្ចរបស់ខ្លួន នៅខេត្តកែប ខេត្តកំពត និងខេត្តព្រះសីហនុ





*គណៈប្រតិភូគណៈកម្មការទី១ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារនិងសំណេះសំណាលជាមួយរដ្ឋបាលខេត្តកែប និងរដ្ឋបាលខេត្តកំពត*

ក្នុងអំឡុងពេលនៃចន្លោះសម័យប្រជុំលើកទី៤និងលើកទី៥ ព្រឹទ្ធសភា នីតិកាលទី៥ គណៈប្រតិភូគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹងនិងអង្កេត និងអធិការកិច្ចនៃព្រឹទ្ធសភា (គណៈកម្មការទី១) ដឹកនាំដោយ ឯកឧត្តម **ឌី ច័ន្ទ្រផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា អមដំណើរដោយតំណាងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន បានអញ្ជើញចុះឈ្វេងយល់ការងារពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តកែប ខេត្តកំពត និងខេត្តព្រះសីហនុ ពីថ្ងៃទី៩ ដល់ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦។

ក្នុងដំណើរបំពេញបេសកកម្មនៅលើទឹកដីខេត្តទាំង៣ គណៈប្រតិភូគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារនិងសំណេះសំណាលជាបន្តបន្ទាប់ ជាមួយរដ្ឋបាលខេត្ត ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលក្រុងកែប, ស្រុកដំណាក់ចង្អើរ ខេត្តកែប, ក្រុងកំពត ក្រុងបូកគោ ខេត្តកំពត និងក្រុង ស្រុក ក្នុងខេត្តព្រះសីហនុ ព្រមទាំងជួបជាមួយមន្ត្រីពន្ធនាគារខេត្ត ដើម្បីស្វែងយល់អំពីស្ថានភាពអ្នកជាប់ឃុំ (ពិរុទ្ធជននិងទណ្ឌិត) និងបញ្ហាប្រឈម ការលំបាក និងសំណូមពររបស់ពន្ធនាគារខេត្ត។

ក្នុងជំនួបនីមួយៗ ឯកឧត្តម **ឌី ច័ន្ទ្រផល** ប្រធានគណៈប្រតិភូ បាននាំនូវបណ្តាំផ្ញើសួរសុខទុក្ខ ប្រកបដោយសេចក្តីនឹករលឹកពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនអាជ្ញាធរគ្រប់ជាន់ថ្នាក់និងប្រជាពលរដ្ឋ ព្រមទាំងបានជម្រាបអំពីគោលបំណងនៃដំណើរបំពេញបេសកកម្មរបស់គណៈកម្មការ និងតួនាទី ភារកិច្ចរបស់គណៈកម្មការនិងព្រឹទ្ធសភាព្រមទាំងអាទិភាពចម្បងរបស់ព្រឹទ្ធសភា នីតិកាលទី៥ គឺការលើកកម្ពស់ការទូតសភានិងការចុះប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមភូមិភាគ និងមូលដ្ឋានរបស់ខ្លួន។

យោងតាមរបាយការណ៍និងការមើលឃើញជាក់ស្តែង **ឯកឧត្តមប្រធាន** បានវាយតម្លៃខ្ពស់ចំពោះការរីកចម្រើន





*គណៈប្រតិភូគណៈកម្មការទី១ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារនិងសំណេះសំណាលជាមួយរដ្ឋបាលខេត្តព្រះសីហនុ*





*គណៈប្រតិភូគណៈកម្មការទី១ព្រឹទ្ធសភា អញ្ជើញជួបជាមួយមន្ត្រីពន្ធនាគារខេត្តកំពត និងខេត្តព្រះសីហនុ ដើម្បីស្វែងយល់អំពីស្ថានភាពអ្នកជាប់ឃុំ*

យ៉ាងឆាប់រហ័ស ដែលឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់ក្នុងការបំពេញការងាររបស់រដ្ឋបាលខេត្ត សម្រេចបានលទ្ធផលរីកចម្រើនលើគ្រប់វិស័យ ទាំងការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងមានភ្ញៀវទេសចរក្នុងនិងក្រៅស្រុកមកលេងច្រើនជាងគេ។ ជាមួយគ្នានោះ អាជ្ញាធរខេត្តបានចាត់ចែងនិងដោះស្រាយទទួលបានលទ្ធផលយ៉ាងល្អប្រសើរ ក្នុងការអនុវត្តសិទ្ធិមនុស្ស ការអនុវត្តច្បាប់ និងការដោះស្រាយពាក្យបណ្តឹង។

ទន្ទឹមនឹងនេះ **ឯកឧត្តមប្រធាន** ក៏បានកោតសរសើរ និងថ្លែងអំណរគុណចំពោះរដ្ឋបាលខេត្តទាំងបី ដែលបានជួយគាំទ្រនិងឧបត្ថម្ភទាំងសមរភូមិមុខ និងប្រជាជនភៀសសឹក ព្រមទាំងបង្កឱកាសឱ្យពួកគាត់បានទទួលការងារធ្វើថែមទៀត។ ឯកឧត្តមបានលើកឡើងពីប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ **ហ៊ុន សែន** ចាត់ទុកយុទ្ធសាស្ត្រ «ស្ងាត់តែមិនស្ងៀម» គឺជាយុទ្ធសាស្ត្រដ៏ត្រឹមត្រូវក្នុងការដោះស្រាយបញ្ហាព្រំដែនជាមួយថៃ។ សង្គ្រាមឈ្លានពានរបស់ថៃមកលើទឹកដីកម្ពុជា មិនត្រឹមតែជាសង្គ្រាមប្រដាប់អាវុធប៉ុណ្ណោះទេ តែជាសង្គ្រាមចិត្តសាស្ត្រ សង្គ្រាមការទូត និងសង្គ្រាមបច្ចេកវិទ្យាផងដែរ ដែលទាមទារឱ្យអាជ្ញាធរ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋទាំងអស់ បន្តរក្សាស្មារតីសាមគ្គីជាតិតែមួយ ជាពិសេសជឿជាក់លើយន្តការដឹកនាំរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា។

**ឯកឧត្តមប្រធាន** បានលើកទឹកចិត្តដល់អាជ្ញាធរគ្រប់ជាន់ថ្នាក់ ត្រូវរួមគ្នាដោះស្រាយរាល់បញ្ហាប្រឈមនិងឧបសគ្គទាំងឡាយដែលបាននិងកំពុងកើតមាន ដើម្បីឱ្យខេត្តនិងមូលដ្ឋានមានការអភិវឌ្ឍកាន់តែល្អប្រសើរជាងនេះថែមទៀត។ ដោយឡែក បញ្ហាប្រឈមនិងសំណូមពរដែលបានលើកឡើងគណៈកម្មការទី១ព្រឹទ្ធសភា បានផ្តល់អនុសាសន៍ និងទទួលនាំយកបញ្ហាទាំងឡាយក្នុងកម្រិតដែនសមត្ថកិច្ច



*ឯកឧត្តម ង៉ី ច័ន្ទផល អញ្ជើញជួបអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ*



*ឯកឧត្តម ង៉ី ច័ន្ទផល ប្រគេនបច្ច័យព្រះសង្ឃ នៅវត្តគិរីដែលសារកោះរ៉ុង*

របស់ថ្នាក់ជាតិទៅគោរពជម្រាបជូនដល់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីរិះរកវិធីសាស្ត្រដោះស្រាយ។

បន្ទាប់ពីជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តរួចមកគណៈប្រតិភូបានអញ្ជើញស្វែងយល់អំពី សក្តានុពលប្រតិបត្តិការ វឌ្ឍនភាព និងការអភិវឌ្ឍ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ព្រមទាំងអញ្ជើញនាំយកបច្ច័យប្រគេនព្រះសង្ឃគង់នៅវត្តគិរីដែលសារកោះរ៉ុងនិងចុះពិនិត្យមើលតំបន់អេកូទេសចរណ៍ ព្រៃកោងកាង និងការអភិវឌ្ឍសហគមន៍នៅក្រុងកោះរ៉ុង ខេត្តព្រះសីហនុ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា អញ្ជើញចុះឈ្វេងយល់អំពីការអនុវត្តថវិកានៅថ្នាក់ក្រោមជាតិ និងកិច្ចការក្នុងវិស័យជាសមត្ថកិច្ចរបស់ខ្លួន នៅខេត្តត្បូងឃ្មុំ និងខេត្តមណ្ឌលគិរី



*គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយរដ្ឋបាលខេត្តត្បូងឃ្មុំ*

គណៈប្រតិភូគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា (គណៈកម្មការទី២) ដឹកនាំដោយ ឯកឧត្តម **យស ផានីត្ថា** ប្រធានគណៈកម្មការ បានអញ្ជើញចុះឈ្វេងយល់វិស័យជាសមត្ថកិច្ចរបស់ខ្លួន ដោយផ្តោតលើការអនុវត្តថវិកានៅថ្នាក់ក្រោមជាតិ ការប្រមូលចំណូលទិដ្ឋភាពសេដ្ឋកិច្ច វឌ្ឍនភាពការងារ បញ្ហាប្រឈម និងសំណូមពរនានា ដែលខេត្តកំពុងជួបប្រទះ នៅខេត្តត្បូងឃ្មុំ និងខេត្តមណ្ឌលគិរី ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦។



*គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយអង្គភាពប្រចាំច្រកទ្វារអន្តរជាតិត្រពាំងផ្លុង*

ក្នុងឱកាសចុះបំពេញការងារនៅខេត្តត្បូងឃ្មុំនិងខេត្តមណ្ឌលគិរី **គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា** បានអញ្ជើញជួបពិភាក្សាការងារជាមួយរដ្ឋបាលខេត្តត្បូងឃ្មុំ ដឹកនាំដោយ ឯកឧត្តម **ឡុង ឆាម** ប្រធានក្រុមប្រឹក្សាខេត្ត និងឯកឧត្តម **ប៉ែន កុសល្យ** អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ អញ្ជើញទស្សនកិច្ចនិងពិភាក្សាការងារជាមួយអង្គភាពប្រចាំច្រកទ្វារអន្តរជាតិត្រពាំងផ្លុង ខេត្តត្បូងឃ្មុំ និងអញ្ជើញជួបពិភាក្សាការងារជាមួយរដ្ឋបាលខេត្តមណ្ឌលគិរី ដឹកនាំដោយ ឯកឧត្តម **ម៉ែន ខ៊ុយ** ប្រធានក្រុមប្រឹក្សាខេត្ត ឯកឧត្តម **ថង សាវុន** អភិបាលនៃគណៈអភិបាលខេត្ត ព្រមទាំងបំពេញទស្សនកិច្ចកសិដ្ឋានដាំបន្លែស្តង់ដាជប៉ុន (យ៉ាម៉ាតុហ្វ្រីន) និងនៅតំបន់អាជីវកម្មរ៉ែមាសអូរខ្វាវរបស់ក្រុមហ៊ុនរ៉ូនែសង់មីនើរ៉ល (ខេមបូឌា) លីមីធីត ដែលស្ថិតក្នុងខេត្តមណ្ឌលគិរី។

នៅគ្រប់ជំនួប **ឯកឧត្តមប្រធានគណៈកម្មការទី២ព្រឹទ្ធសភា** បាននាំនូវបណ្តាំសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនដល់ថ្នាក់ដឹកនាំខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ជាន់ថ្នាក់ និងប្រជាពលរដ្ឋក្នុងខេត្តទាំងពីរ និងបានជម្រាបជូនអំពីរចនាសម្ព័ន្ធគ្រប់គ្រង និងដឹកនាំសំខាន់ៗរបស់ព្រឹទ្ធសភា រួមមាន៖ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា គណៈកម្មការជំនាញទាំង១០ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ក្រុមសមាជិកាព្រឹទ្ធសភា និងក្រុមមិត្តភាពទ្វេភាគី និងពហុភាគី។ល។ ឯកឧត្តមបានជម្រាបជូនអង្គប្រជុំបន្ថែមថា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់និងប្រកបដោយគតិបណ្ឌិតឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា បានកំណត់នូវអាទិភាពសំខាន់ៗចំនួន២ ក្នុងនីតិកាលទី៥នេះ គឺទី១-ការទូតសភា និងទី២-គណនេយ្យភាពជាមួយក្រុមប្រឹក្សាឃុំសង្កាត់ បន្ថែមលើមុខងារស្នូលទាំង៣របស់ព្រឹទ្ធសភា គឺមុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង។



គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារនិងថតរូបអនុស្សាវរីយ៍ជាមួយរដ្ឋបាលខេត្តមណ្ឌលគិរី

ក្នុងគ្រប់ជំនួបទាំងអស់នោះ **ឯកឧត្តមអភិបាលខេត្ត**បានស្វាគមន៍យ៉ាងកក់ក្ដៅចំពោះគណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភានិងបានធ្វើសេចក្ដីរាយការណ៍អំពីលក្ខណៈភូមិសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធ សក្ដានុពលផ្នែកកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងទេសចរណ៍ ជាពិសេសការអនុវត្តថវិកាសមិទ្ធកម្មរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុការអនុវត្តថវិកានៅថ្នាក់ក្រោមជាតិ ការប្រមូលចំណូលផ្សេងៗក្នុងខេត្តនីមួយៗ។

បន្ទាប់ពីបានស្ដាប់សេចក្ដីរាយការណ៍និងពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក **ឯកឧត្តមប្រធាន**បានវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំខេត្ត និងមន្ទីរជំនាញពាក់ព័ន្ធ ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តក្នុងការបំពេញការងារស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនិងបានបម្រើប្រជាពលរដ្ឋយ៉ាងល្អ ប្រកបដោយការយកចិត្តទុកដាក់ខ្ពស់។ ទន្ទឹមនឹងនោះ ឯកឧត្តមក៏បានលើកទឹកចិត្តដល់រដ្ឋបាលខេត្តនិងមន្ទីរពាក់ព័ន្ធ សូមបន្តយកចិត្តទុកដាក់ការអនុវត្តការងារបន្តទៀត ដើម្បីឱ្យខេត្តកាន់តែមានការរីកចម្រើន និងអភិវឌ្ឍន៍បានយ៉ាងឆាប់រហ័ស។ ចំណែកបញ្ហាប្រឈមដែលខេត្តនិងមន្ទីរបានលើកឡើង **គណៈកម្មការទី២ព្រឹទ្ធសភា**នឹងនាំយកបញ្ហាប្រឈមទាំងនោះ មកជម្រាបជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីលើកជាអនុសាសន៍ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធដោះស្រាយ។

ក្រៅពីនេះ **គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា**ក៏បានអញ្ជើញជួបសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាឃុំ ស្រុក ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ នៅសាលាស្រុកអូររាំង ខេត្តមណ្ឌលគិរីផងដែរ។

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា អញ្ជើញទស្សនកិច្ចកសិដ្ឋានដាំបន្លែស្តង់ដាជប៉ុន



គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា អញ្ជើញទស្សនកិច្ចនៅតំបន់អាជីវកម្មរ៉ែមាសអូរខ្វាវរបស់ក្រុមហ៊ុន រ៉ែនេសង់មីនើរ៉ល (ខេមបូឌា) លីមីធីត

# គណៈប្រតិភូគណៈកម្មការទី៣ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយ ថ្នាក់ដឹកនាំក្រសួងបរិស្ថាន ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងផែនការ



*គណៈប្រតិភូគណៈកម្មការទី៣ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយឯកឧត្តម អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន*

នាព្រឹកថ្ងៃទី៩ ថ្ងៃទី២៣ និងថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៦ គណៈប្រតិភូគណៈកម្មការ ផែនការ វិនិយោគ កសិកម្ម រុក្ខាប្រមាញ់ នេសាទ អភិវឌ្ឍន៍ ជនបទ បរិស្ថាន ធនធានទឹក និងឧតុនិយម (គណៈកម្មការ ទី៣) ដឹកនាំដោយ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធាន គណៈកម្មការ បានអញ្ជើញជួបពិភាក្សាការងារជាបន្តបន្ទាប់ ជាមួយឯកឧត្តម **អ៊ាង សុផល្លែត** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឯកឧត្តម **ឆាយ ឫទ្ធិសែន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និង ឯកឧត្តម **ប៊ិន ត្រាឈៃ** រដ្ឋមន្ត្រីក្រសួងផែនការ ដើម្បី



*គណៈប្រតិភូគណៈកម្មការទី៣ព្រឹទ្ធសភា អញ្ជើញថតរូបអនុស្សាវរីយ៍ ជាមួយថ្នាក់ដឹកនាំក្រសួងបរិស្ថាន*



*គណៈប្រតិភូគណៈកម្មការទី៣ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារនិងប្រគល់វត្ថុអនុស្សាវរីយ៍ជូនថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ*





*គណៈប្រតិភូគណៈកម្មការទី៣ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយឯកឧត្តម ប៊ិន ត្រឈៃ រដ្ឋមន្ត្រីក្រសួងផែនការ*

ឈ្វេងយល់ពីវឌ្ឍនភាពការងារ បញ្ហាប្រឈម និងចក្ខុវិស័យរបស់ក្រសួង នៅទីស្តីការក្រសួង។

នៅគ្រប់ជំនួប **ឯកឧត្តមបណ្ឌិត** បានជម្រាបជូនអំពីមុខងារសំខាន់ៗរបស់ព្រឹទ្ធសភា និងគណៈកម្មការនានារបស់ព្រឹទ្ធសភា ដែលជាយន្តការស្នូលជួយទ្រទ្រង់ដល់ដំណើរការអនុវត្តមុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារផ្តល់ព័ត៌មានរបស់ព្រឹទ្ធសភា។ **ឯកឧត្តមបណ្ឌិត** បានគូសបញ្ជាក់ថា ការសិក្សាឈ្វេងយល់និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការទាំង១០ដែលត្រូវទទួលរ៉ាប់រង គឺជាវិធីសាស្ត្រដ៏មានអត្ថប្រយោជន៍បំផុត និងឆ្លើយតបបានយ៉ាងត្រឹមត្រូវទៅនឹងមុខងារទាំង៣ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។

ក្នុងជំនួបពិភាក្សានោះ **ឯកឧត្តមរដ្ឋមន្ត្រី** បានជម្រាបអំពីវឌ្ឍនភាពការងារដែលក្រសួងសម្រេចបាន ចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួង, អាទិភាពគោលនយោបាយ និងសកម្មភាពការងារសំខាន់ៗនៅក្នុងឆ្នាំ២០២៦ និងរចនាសម្ព័ន្ធកម្មវិធីរបស់ក្រសួង។

បន្ទាប់ពីបានស្តាប់សេចក្តីរាយការណ៍លម្អិតរបស់ **ឯកឧត្តមរដ្ឋមន្ត្រី** រួចមក ឯកឧត្តម លោកជំទាវ សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា បានលើកឡើងនូវសំណួរមួយចំនួន និងបានសម្តែងនូវការគាំទ្រ ព្រមទាំងបានកោតសរសើរចំពោះ **ឯកឧត្តមរដ្ឋមន្ត្រី** និងសហការីទាំងអស់ ដែលបានខិតខំបំពេញតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួន ដោយសម្រេចបានសមិទ្ធផលយ៉ាងច្រើនគួរឱ្យកត់សម្គាល់។



*ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី អញ្ជើញប្រគល់វត្ថុអនុស្សាវរីយ៍ជូនថ្នាក់ដឹកនាំក្រសួងផែនការ*

ជាចុងបញ្ចប់ **ឯកឧត្តមប្រធានគណៈកម្មការ** បានលើកសរសើរចំពោះការដឹកនាំរបស់**ឯកឧត្តមរដ្ឋមន្ត្រី**និងបានផ្តល់ជាអនុសាសន៍មួយចំនួនដើម្បីជាការចូលរួមចំណែក ក្នុងការអភិវឌ្ឍនៅតំបន់ជនបទឱ្យកាន់តែមានភាពល្អប្រសើរថែមទៀត៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា លើកឡើងនូវចំណុចសំខាន់ចំនួន៤ ពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ខ្លួន ជូនដល់អាជ្ញាធរខេត្តកំពត និងខេត្តព្រះសីហនុ

ឯកឧត្តម **ឈិត សុខុន** ប្រធានគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ នៃព្រឹទ្ធសភា (គណៈកម្មការទី៧) បានលើកឡើងនូវចំណុចសំខាន់ចំនួន៤ចំណុច ជាមួយអាជ្ញាធរខេត្តកំពត និងខេត្តព្រះសីហនុ មានដូចជា៖

១-ការងារអប់រំ៖ បន្តការអភិវឌ្ឍធនធានមនុស្ស តាមរយៈការពង្រឹងគុណវុឌ្ឍិអប់រំ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ បច្ចេកទេស និងភាសាបរទេសឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ប្រកបដោយប្រសិទ្ធភាព គុណភាព សមធម៌ និងបរិយាបន្ន ព្រមទាំងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និងការអប់រំឌីជីថលតាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលតាមសាលារៀន។ បន្តពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងលើកកម្ពស់សុខភាពអនាម័យរបស់សិស្សនៅតាមគ្រឹះស្ថានសិក្សា និងបង្កើនការអប់រំអំពីសុវត្ថិភាពចំណីអាហារ បរិស្ថានសាលារៀនបៃតង សាលារៀនស្អាតគ្មានសំរាម ការប្រើប្រាស់ទឹកស្អាត និងមានអនាម័យ។ លើកទឹកចិត្តកុមារនិងយុវជនឱ្យមានស្មារតីទទួលខុសត្រូវ មានជំនឿលើសមត្ថភាពរបស់ខ្លួន និងប្រកាន់ខ្ជាប់នូវទង្វើវិជ្ជមានក្នុងសង្គម តាមរយៈការបំផុសចលនា «កូនល្អ សិស្សល្អ មិត្តល្អ ពលរដ្ឋល្អ» ព្រមទាំងជំរុញចលនា «យុវជនម្នាក់ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត»។

២-សូមឱ្យមជ្ឈមណ្ឌលសាសនាទាំងអស់ក្នុងខេត្ត បន្តអនុវត្តគោលនយោបាយសុខដុមនីយកម្មសាសនា ក្នុងការប្រែក្លាយជាគំរូល្អលើគ្រប់ទិដ្ឋភាព ទាំងសីលធម៌ គុណធម៌ សុជីវធម៌ អនាម័យ និងបរិស្ថាន។ បន្តផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយ អំពីសក្តានុពលទេសចរណ៍សាសនា តាមរយៈការបង្កើតនិងធ្វើពិពិធកម្មព្រឹត្តិការណ៍ទេសចរណ៍សាសនា។ សាសនាមិនត្រឹមតែជាគ្រឹះនៃជំនឿនិងសីលធម៌សង្គមប៉ុណ្ណោះទេ ប៉ុន្តែជាមូលដ្ឋានស្នូលនៃការថែរក្សាសន្តិភាព និងសុខដុមនីយកម្មក្នុងសង្គម។ បន្តពង្រឹងគុណវុឌ្ឍិវិស័យពុទ្ធិកសិក្សា សាលាធម្មវិន័យ និងលើកកម្ពស់គុណភាពគ្រូនៅគ្រប់កម្រិតទូទាំងខេត្ត ដោយហេតុថាព្រះសង្ឃបានរួមចំណែកក្នុងការថែរក្សាវប្បធម៌ អរិយធម៌ ប្រពៃណី ទំនៀមទម្លាប់ដ៏ថ្លៃថ្លារបស់ជាតិ តាមរយៈការសម្តែងធម្មទេសនា។





*គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារ ជាមួយរដ្ឋបាលខេត្តកំពត*

៣-វិស័យវប្បធម៌ជាដួងព្រលឹងជាតិ ជាអត្តសញ្ញាណជាតិ ជាកិត្យានុភាពជាតិ ដូចនេះត្រូវបន្តលើកតម្កើងកេរ-ដំណែលវប្បធម៌ជាតិ ជំរុញការផ្សព្វផ្សាយអំពីផលិតផល និងសក្តានុពលវប្បធម៌ដែលមានស្រាប់ បូករួមជាមួយយុទ្ធ-សាស្ត្រអភិវឌ្ឍន៍ឧស្សាហកម្មវប្បធម៌និងការច្នៃប្រឌិតថ្មីៗ ឱ្យស្របទៅតាមបរិបទនៃការអភិវឌ្ឍវប្បធម៌។ តាមរយៈ



*គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា អញ្ជើញជួបជាមួយ គណៈគ្រប់គ្រងសាលា នៅខេត្តកំពត*



គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយរដ្ឋបាលខេត្តព្រះសីហនុ

វប្បធម៌ យើងបង្កើតបានសកម្មភាពការងារជាច្រើន ដែលផ្ដល់ប្រយោជន៍ដល់សេដ្ឋកិច្ចសហគមន៍ ក្នុងន័យនេះ ត្រូវបន្តការពារថែរក្សា អភិរក្ស និងអភិវឌ្ឍបេតិកភណ្ឌជាតិ ទាំងរូបី និងអរូបី។ បង្កើនការអប់រំយុវជននិងកុមារឱ្យយល់ដឹងច្បាស់ពីតម្លៃដ៏វិសេសវិសាលនៃវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ខ្មែរ ត្រូវរួមគ្នាថែរក្សា លើកតម្កើង អភិវឌ្ឍន៍វប្បធម៌ជាតិ និងកាត់បន្ថយឥទ្ធិពលវប្បធម៌អវិជ្ជមានពីបរទេស។

៤-វិស័យទេសចរណ៍ ជាមាសបៃតង ហើយបានរួមចំណែកដល់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិ ដូចនេះត្រូវជំរុញការផ្សព្វផ្សាយ និងស្វែងរកទីផ្សារថ្មីៗបន្ថែមទៀតឱ្យកាន់តែមានប្រសិទ្ធភាព ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និងវិស័យឯកជន។ លើកកម្ពស់សេវាកម្មទេសចរណ៍ ដោយធានាបានគុណភាព សុវត្ថិភាព ផាសុកភាព បៃតង ស្អាត វៃឆ្លាត ដើម្បីបង្កើនការពេញចិត្តដល់ភ្ញៀវទេសចរ ព្រមទាំងសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីថែរក្សាសន្តិសុខ សណ្ដាប់ធ្នាប់ អនាម័យ បរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងទូរគមនាគមន៍ នៅតាមបណ្ដារមណីយដ្ឋាននានាឱ្យកាន់តែមានលក្ខណៈទាក់ទាញ។

ការលើកឡើងបែបនេះ ក្នុងឱកាសគណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា ដឹកនាំដោយ ឯកឧត្តម **ឈិត សុខុន** ប្រធានគណៈកម្មការ អញ្ជើញជួបពិភាក្សាការងារជាមួយអាជ្ញាធរនិងមន្ទីរជំនាញពាក់ព័ន្ធ នៅខេត្តកំពត និងខេត្តព្រះសីហនុ នាថ្ងៃទី២៤ និងទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦។



ឯកឧត្តម ឈិត សុខុន អញ្ជើញប្រគល់វត្ថុអនុស្សាវរីយ៍
ជូនថ្នាក់ដឹកនាំខេត្តព្រះសីហនុ



គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា អញ្ជើញជួបជាមួយ
សិស្សានុសិស្ស នៅខេត្តព្រះសីហនុ

ក្រៅពីជួបជាមួយអាជ្ញាធរខេត្ត **គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា** បានអញ្ជើញជួបសំណេះសំណាល ព្រមទាំងឈ្វេងយល់ពីបទពិសោធល្អៗ ក្នុងការបង្រៀន និងរៀនភាសាបរទេស ជាមួយលោកគ្រូ អ្នកគ្រូ គណៈគ្រប់គ្រងសាលា បឋមសិក្សាអង្គជុំ និងសាលាបឋមសិក្សាហ៊ុន សែនមិត្តភាព ព្រមទាំងចូលរួមមតិយោបល់ ដើម្បីរួមចំណែកក្នុងការលើកកម្ពស់ការបង្រៀននិងរៀនភាសាបរទេស ឱ្យកាន់តែមានគុណភាពនិងប្រសិទ្ធភាពខ្ពស់។

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយរដ្ឋបាលខេត្ត និងមន្ទីរជំនាញពាក់ព័ន្ធ នៅខេត្តកំពង់ស្ពឺ ខេត្តកណ្តាល និងខេត្តតាកែវ



*គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយរដ្ឋបាលខេត្តកំពង់ស្ពឺ*

គណៈប្រតិភូគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី នៃព្រឹទ្ធសភា (គណៈកម្មការទី៨) ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការ បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយរដ្ឋបាលខេត្ត និងមន្ទីរជំនាញពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ព្រមទាំងចុះទស្សនកិច្ចឈ្វេងយល់វឌ្ឍនភាពលើវិស័យការងារ សង្គមកិច្ច សុខាភិបាល និងកិច្ចការនារី នៅមូលដ្ឋានខេត្តកំពង់ស្ពឺ ខេត្តកណ្តាល និងខេត្តតាកែវ ពីថ្ងៃទី១៨ ដល់ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៦។

ក្នុងដំណើរបំពេញបេសកកម្មនៅលើទឹកដីខេត្តកំពង់ស្ពឺ ខេត្តកណ្តាល និងខេត្តតាកែវ គណៈប្រតិភូគណៈកម្មការទី៨ ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាបន្តបន្ទាប់ជាមួយរដ្ឋបាលខេត្តកំពង់ស្ពឺ, រោងចក្រ អារ៉ូម៉ា សឹកសេស ហ្គាម៉ិន ឯ.ក, រដ្ឋបាលខេត្តកណ្តាល, រដ្ឋបាលខេត្តតាកែវ ព្រមទាំងទស្សនកិច្ចឈ្វេងយល់អំពីវឌ្ឍនភាពកសិដ្ឋានភ្ញាស់ និងចិញ្ចឹមបង្កង នៅសហគមន៍ទេសចរណ៍ វប្បកម្មធម្មជាតិភ្នំដា ស្រុកអង្គរបូរី ខេត្តតាកែវ។





*គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារ ជាមួយតំណាងរោងចក្រអារ៉ូម៉ា សឹកសេស ហ្គាម៉ិន ឯ.ក*

ក្នុងជំនួបនីមួយៗ **លោកជំទាវប្រធាន** បានមានប្រសាសន៍នាំមកនូវបណ្តាំសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនចំពោះថ្នាក់ដឹកនាំខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ថ្នាក់ និងប្រជាពលរដ្ឋក្នុងខេត្តទាំងបី ប្រកបដោយក្តីនឹករលឹកជាទីបំផុត ព្រមទាំងបានកោតសរសើរចំពោះសមិទ្ធផលដ៏ធំធេងក្នុងការចូលរួមអភិវឌ្ឍន៍ខេត្ត ការថែរក្សាសន្តិភាព ពង្រឹងកិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈធ្វើឱ្យប្រជាពលរដ្ឋ ក្នុងខេត្តទទួលបាននូវភាពកក់ក្តៅ រួមចំណែករក្សាបានស្ថិរភាពនយោបាយដ៏ល្អប្រសើរ។

**លោកជំទាវប្រធាន** បានបញ្ជាក់អំពីគោលបំណងនៃជំនួបគឺ ដើម្បីសិក្សាឈ្វេងយល់ពីវឌ្ឍនភាពការងារ ប្រមូលព័ត៌មានបញ្ហាប្រឈម និងសំណូមពរក្នុងការអនុវត្តច្បាប់ គោលនយោបាយ និងការអនុវត្តជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនិងមូលដ្ឋាន ព្រមទាំងលទ្ធផល នៃកិច្ច-



*គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារ និងថតរូបអនុស្សាវរីយ៍ជាមួយរដ្ឋបាលខេត្តកណ្ដាល*

ប្រតិបត្តិ ការគាំទ្រ និងទិន្នន័យពាក់ព័ន្ធនឹងវិស័យជំនាញ ជាសមត្ថកិច្ចរបស់គណៈកម្មការ ដើម្បីរាយការណ៍ជូន **សម្តេចតេជោ** ប្រធានព្រឹទ្ធសភានិងគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា លើកជាយោបល់ទៅក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចដោះស្រាយ។ លោកជំទាវក៏បានជម្រាបជូនផងដែរអំពីសមិទ្ធផលរបស់ព្រឹទ្ធសភានីតិកាលទី៥ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតខ្ពស់របស់សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដែលបានដាក់ចេញនូវអាទិភាពចម្បងចំនួនពីរ គឺទី១-ការលើកកម្ពស់ការទូតសភា និងទី២-ត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គបោះឆ្នោត ជាពិសេសជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាតំណាងឱ្យប្រជាពលរដ្ឋនៅមូលដ្ឋានបន្ថែមលើមុខងារស្នូលទាំងបីរបស់ព្រឹទ្ធសភា គឺមុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់និងមុខងារតំណាង។

ជាងនេះទៅទៀត លោកជំទាវបានអំពាវនាវដល់អាជ្ញាធរខេត្ត មន្ទីរអង្គភាព និងប្រជាពលរដ្ឋ ត្រូវតស៊ូអត់ធ្មត់ ជឿទុកចិត្តលើថ្នាក់ដឹកនាំរាជរដ្ឋាភិបាលនិងវីរភាពដ៏អង់អាចក្លាហានរបស់វីរកងទ័ពយើងនិងរួមសាមគ្គីគ្នាជាធ្លុងមួយឱ្យបានរឹងមាំនៃមហាគ្រួសារជាតិខ្មែរ ក្នុងកាលៈទេសៈដែលប្រទេសជាតិកំពុងជួបប្រទះនឹងការលំបាក ដោយសារការឈ្លានពានពីប្រទេសថៃ។ ទន្ទឹមនេះ លោកជំទាវក៏បានជំរុញដល់រដ្ឋបាលខេត្តទាំងបី និងមន្ត្រីគ្រប់រូប ត្រូវខិតខំប្រឹងប្រែងឈ្វេងយល់អំពីប្រសិទ្ធភាពការងារនៃការអនុវត្តច្បាប់ និងគោលនយោបាយនានាពាក់ព័ន្ធនឹងវិស័យទាំង៤ ដែលបានអនុវត្តកន្លងមកឱ្យកាន់តែមានប្រសិទ្ធភាព និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ន និងអនាគត និងសូមបង្កើនចំនួនស្ត្រីក្នុងជួររដ្ឋបាលសាធារណៈ ដើម្បីជួយសម្រួលដល់ការអនុវត្តការងារសេវាសង្គមនៅថ្នាក់មូលដ្ឋាន៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





*គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារ ជាមួយរដ្ឋបាលខេត្តតាកែវ*



*គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា អញ្ជើញទស្សនកិច្ច កសិដ្ឋានភ្ញាស់និងចិញ្ចឹមបង្កង នៅខេត្តតាកែវ*

# គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា អញ្ជើញចុះឈ្វេងយល់អំពីការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ខ្លួន នៅក្រសួងនិងក្រុមហ៊ុនឯកជន ចំនួន៣



*គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយឯកឧត្តម ប៉េង ពោធិ៍នា រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន*

នៅថ្ងៃទី១៩ ទី២០ និងទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦ គណៈប្រតិភូគណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃព្រឹទ្ធសភា (គណៈកម្មការទី៩) ដឹកនាំដោយឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការ បានអញ្ជើញជួបពិភាក្សាការងារជាបន្តបន្ទាប់ជាមួយ ឯកឧត្តម **ប៉េង ពោធិ៍នា** រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន, ឯកឧត្តម **សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងបំពេញទស្សនកិច្ចនៅក្រុមហ៊ុន VP.Start Technology Co., Ltd។



*គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយថ្នាក់ដឹកនាំក្រសួងសាធារណការនិងដឹកជញ្ជូន*



*គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយឯកឧត្តម សាយ សំអាល់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*



*ទិដ្ឋភាពក្នុងជំនួបពិភាក្សាការងារ នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*

នៅក្នុងជំនួបនីមួយៗ **ឯកឧត្តមប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា** បាននាំនូវបណ្តាំសួរសុខទុក្ខនិងជូនពរសព្ទសាធុការពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃក្រសួងទាំងពីរនិងជម្រាបជូនអំពីគោលបំណងជួបជាមួយក្រសួង និងទស្សនកិច្ចគឺ ដើម្បីពិនិត្យវឌ្ឍនភាព និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់លិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួង ស្តាប់សេចក្តីរាយការណ៍អំពីវឌ្ឍនភាពដែលក្រសួងសម្រេចបាន បញ្ហាប្រឈម ទិសដៅអភិវឌ្ឍន៍ និងការរំពឹងទុក។

ក្នុងឱកាសនោះ **ឯកឧត្តមរដ្ឋមន្ត្រី** និង**លោកនាយកប្រតិបត្តិនៃក្រុមហ៊ុន** បានជម្រាបជូនគណៈប្រតិភូជ្រាបអំពីសមិទ្ធផលការងារសម្រេចបាន បញ្ហាប្រឈម និងដំណោះស្រាយ ព្រមទាំងបានធ្វើបទបង្ហាញស្តីពីដំណើរការការងារសំខាន់ៗ ព្រមទាំងផែនការការងារចាំបាច់។

បន្ទាប់ពីស្តាប់សេចក្តីរាយការណ៍របស់**ឯកឧត្តមរដ្ឋមន្ត្រី**រួចមក ក្នុងនាមប្រធានគណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា ឯកឧត្តម **អ៊ុំ សារិទ្ធ** ប្រធានគណៈកម្មការបានមានប្រសាសន៍គាំទ្រ និងកោតសរសើរ ព្រមទាំងលើកទឹកចិត្តចំពោះ**ឯកឧត្តមរដ្ឋមន្ត្រី**និងថ្នាក់ដឹកនាំនៃក្រសួងក្រុមហ៊ុន ដើម្បីដឹកនាំវិស័យទាំងអស់ឱ្យកាន់តែរីកចម្រើនបន្ថែមទៀត ជាពិសេសការអនុវត្តលើក្របខ័ណ្ឌគោលនយោបាយ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា អញ្ជើញស្តាប់បទបង្ហាញរបស់ក្រុមហ៊ុន VP.Start Technology Co., Ltd*






*គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា អញ្ជើញទស្សនកិច្ច នៅក្រុមហ៊ុន VP.Start Technology Co., Ltd និងថតរូបអនុស្សាវរីយ៍*

# អំណោយមនុស្សធម៌របស់ព្រឹទ្ធសភាកម្ពុជា និងមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ត្រូវបានប្រគល់ជូនរដ្ឋបាលខេត្តសៀមរាប





*គណៈប្រតិភូគណៈកម្មការទី១០ព្រឹទ្ធសភា អញ្ជើញជួបសំណេះសំណាល និងប្រគល់អំណោយជូនរដ្ឋបាលខេត្តសៀមរាប*

នាថ្ងៃសុក្រ ទី៣០ ខែមករា ឆ្នាំ២០២៦ គណៈប្រតិភូគណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ នៃព្រឹទ្ធសភា (គណៈកម្មការទី១០) ដឹកនាំដោយឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា នាំយកអំណោយមនុស្សធម៌ព្រឹទ្ធសភាកម្ពុជានិងមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ក្នុងទំហំទឹកប្រាក់ប្រមាណជាង១,២លានដុល្លារអាម៉េរិក ប្រគល់ជូនរដ្ឋបាលខេត្តសៀមរាប នៅសាលាខេត្តសៀមរាប។

ក្នុងឱកាសនោះ ឯកឧត្តម **ម៉ម ប៊ុននាង** បាននាំនូវបណ្តាំសួរសុខទុក្ខ ប្រកបដោយសេចក្តីនឹករលឹកពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនដល់ថ្នាក់ដឹកនាំមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ និងប្រជាពលរដ្ឋក្នុងខេត្តសៀមរាបព្រមទាំងជូនចំពោះក្រុមគ្រួសារវីរកងទ័ពនិងជនភៀសសឹកទាំងអស់។

**ឯកឧត្តមប្រធានគណៈប្រតិភូ** បានគូសបញ្ជាក់ថា ព្រឹទ្ធសភានីតិកាលទី៥ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា បានកំណត់អាទិភាពចម្បងចំនួនពីរគឺ ទី១-ត្រូវចុះជាប់ជាមួយប្រជាជននិងអាជ្ញាធរមូលដ្ឋាននិង ទី២-ការលើកកម្ពស់ការងារការទូតសភា។ ឯកឧត្តមក៏បានលើកឡើងអំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលចំពោះការលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋនៅទូទាំងប្រទេសឱ្យបានកាន់តែប្រសើរនិងស្វែងរកដំណោះស្រាយបញ្ហានានា រួមទាំងបញ្ហាព្រំដែនកម្ពុជា-ថៃ ប្រកបដោយយុត្តិធម៌ ត្រឹមត្រូវ យូរអង្វែង ស្របតាមច្បាប់អន្តរជាតិ សន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងដែលមានស្រាប់ និងប្រកាន់ជំហរថា ខ្សែព្រំដែនមិនត្រូវបានផ្លាស់ប្តូរតាមរយៈការប្រើប្រាស់កម្លាំងនោះឡើយ។

អំណោយមនុស្សធម៌ដែលយកមកប្រគល់ជូនដល់រដ្ឋបាលខេត្តសៀមរាបនាឱកាសនោះ គឺសុទ្ធសឹងជាឱសថសម្រាប់ព្យាបាលជំងឺមិនឆ្លង និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ ដែលឆ្លើយតបនឹងសំណើរបស់រដ្ឋបាលខេត្តនាពេលកន្លងទៅ។ អំណោយទាំងអស់នេះ គឺជាសមិទ្ធផលនៃការអនុវត្តការងារជាអាទិភាពទាំងពីររបស់ព្រឹទ្ធសភា នីតិកាលទី៥និងការអនុវត្តអនុស្សរណៈនៃការយោគយល់រវាងគណៈកម្មការទី១០ព្រឹទ្ធសភា ជាមួយមូលនិធិចែករំលែកសង្គ្រោះជីវិតសកល។

ក្នុងឱកាសនោះ ថ្នាក់ដឹកនាំរដ្ឋបាលខេត្តសៀមរាប បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំព្រឹទ្ធសភា គណៈកម្មការទី១០ព្រឹទ្ធសភា និងមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ដែលបានយកចិត្តទុកដាក់ខ្ពស់ដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងខេត្តសៀមរាប។ ថ្នាក់ដឹកនាំខេត្តបានប្តេជ្ញាថា នឹងគ្រប់គ្រង បែងចែកអំណោយទាំងអស់នេះ ឱ្យដល់ដៃអាជ្ញាធរ និងប្រជាពលរដ្ឋក្រីក្រ ជនងាយរងគ្រោះ និងជនភៀសសឹក ប្រកបដោយតម្លាភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងបរិយាបន្ន។ អំណោយមនុស្សធម៌របស់ព្រឹទ្ធសភា និងរបស់មូលនិធិ គឺពិតជាមានសារៈសំខាន់ ហើយត្រូវនឹងតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋនៅមូលដ្ឋានខេត្តសៀមរាប៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# គណៈកម្មការទី១០ព្រឹទ្ធសភា អញ្ជើញចុះឈ្វេងយល់អំពីការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ខ្លួននៅខេត្តស្វាយរៀង



*ឯកឧត្តម ប៉េង ពោធិ៍សា អភិបាលខេត្តស្វាយរៀង (កណ្តាល)*



*ឯកឧត្តម ម៉ម ប៊ុននាង ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា (កណ្តាល)*

នាចន្លោះសម័យប្រជុំលើកទី៤និងលើកទី៥ ព្រឹទ្ធសភា នីតិកាលទី៥ គណៈប្រតិភូគណៈ-កម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ នៃព្រឹទ្ធសភា (គណៈកម្មការទី១០) ដឹកនាំដោយឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការ បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តស្វាយរៀង ដឹកនាំដោយឯកឧត្តម **ប៉េង ពោធិ៍សា** អភិបាលខេត្ត ដើម្បីឈ្វេងយល់អំពីប្រសិទ្ធភាព និងបញ្ហាប្រឈមនានានៃការអនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយនិងការអភិវឌ្ឍមូលដ្ឋាន នៅសាលាខេត្តស្វាយរៀង នារសៀលថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៦។

ក្នុងឱកាសនោះ **ឯកឧត្តមប្រធានគណៈកម្មការទី១០** ព្រឹទ្ធសភា បានមានប្រសាសន៍នាំនូវការផ្តាំផ្ញើសួរសុខទុក្ខប្រកបដោយក្តីនឹករលឹកពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភាជូនចំពោះថ្នាក់ដឹកនាំខេត្ត មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងប្រជាពលរដ្ឋទូទាំងខេត្តស្វាយរៀង ព្រមទាំងបានជម្រាបជូនអំពីការងារជាអាទិភាពនិងការបំពេញមុខងារស្នូលរបស់ព្រឹទ្ធសភានីតិកាលទី៥ ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា តែងយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តការងារជាអាទិភាពនិងការងារស្នូលរបស់ខ្លួនប្រកបដោយបុរេសកម្ម ដើម្បីបុព្វហេតុការពារផលប្រយោជន៍និងកិត្យានុភាពជាតិ ការពារសន្តិភាព ឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី ជាពិសេសក្នុងពេលមានសង្គ្រាមឈ្លានពានរបស់ថៃមកលើកម្ពុជា។ ទន្ទឹមនេះ សមាជិក សមាជិកាព្រឹទ្ធសភា តាមរយៈយន្តការ គណៈកម្មការជំនាញ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំ



*ទិដ្ឋភាពក្នុងជំនួបពិភាក្សាការងារ*

ភូមិភាគទាំង៨និងក្រុមសមាជិកាព្រឹទ្ធសភា តែងបានចុះជួបពិភាក្សាការងារជាមួយក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាព ប្រសិទ្ធភាព និងបញ្ហាប្រឈមនានា ដើម្បីចូលរួមដោះស្រាយឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។

នៅក្នុងជំនួបនោះ ឯកឧត្តម **ម៉េង ពោធិ៍សា** អភិបាលខេត្តស្វាយរៀង បានស្វាគមន៍និងធ្វើសេចក្តីរាយការណ៍អំពីលក្ខណៈភូមិសាស្ត្រ ប្រជាសាស្ត្រ វឌ្ឍនភាពនៃការអភិវឌ្ឍមូលដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សក្តានុពលផ្នែកកសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម សេវាកម្ម សុខាភិបាល និងអប់រំ សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ជាពិសេសលទ្ធផលនៃការអនុវត្តច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ។ ឯកឧត្តមបានគូសបញ្ជាក់ថា រដ្ឋបាលខេត្តស្វាយរៀងបានប្តេជ្ញាចិត្តខ្ពស់ក្នុងការអនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយយ៉ាងសកម្ម ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយគ្រប់រូបភាព គ្រប់វិស័យ និងគ្រប់ជាន់ថ្នាក់ តាមរយៈវិធានការអប់រំ បង្ការទប់ស្កាត់ និងចូលរួមអនុវត្តច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយឱ្យបានម៉ឺងម៉ាត់។ ជាក់ស្តែង មន្ត្រីជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុល ជាក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និងគណៈអភិបាលខេត្ត ក្រុង ស្រុក ចំនួន ៤០១នាក់ នៃចំនួនសរុប៧០០នាក់ បានធ្វើការប្រកាសរួចរាល់មួយរយភាគរយ។ ថ្នាក់ដឹកនាំខេត្ត តែងតែផ្សព្វផ្សាយច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយក្នុងប្រជុំប្រចាំខែ ត្រីមាស ឆមាស និងកិច្ចប្រជុំប្រចាំឆ្នាំ ក៏ដូចជាកម្មវិធីផ្សេងៗនៅតាមមូលដ្ឋានសំដៅផ្តល់សេវានានាជូនប្រជាពលរដ្ឋប្រកបដោយគុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

បន្ទាប់ពីបានស្តាប់សេចក្តីរាយការណ៍របស់**ឯកឧត្តមអភិបាលខេត្ត** និងពិភាក្សាយ៉ាងផុសផុលរួចមក ឯកឧត្តម **ម៉ម ប៊ុននាង** បានវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំខេត្ត និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ដែលបានខិតខំប្រឹងប្រែងបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួនយ៉ាងល្អប្រសើរ រហូតសម្រេចបានសមិទ្ធផលយ៉ាងច្រើនគួរឱ្យកត់សម្គាល់។

**ឯកឧត្តមប្រធាន** បានអំពាវនាវដល់រដ្ឋបាលខេត្តឱ្យបន្តអប់រំច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ ឱ្យបានទូលំទូលាយ ដើម្បីបង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋ ធានាបាននូវសេវាល្អ សមធម៌សង្គម ភាពស្អាតស្អំ និងយុត្តិធម៌ ដើម្បីការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងចីរភាព។ ថ្នាក់ដឹកនាំខេត្ត និងអាជ្ញាធរគ្រប់ជាន់ថ្នាក់ ត្រូវចូលរួមលើកកម្ពស់ស្មារតីប្រយុទ្ធប្រឆាំងអំពើពុករលួយគ្រប់រូបភាព គ្រប់វិស័យ និងគ្រប់ជាន់ថ្នាក់ បន្តលើកកម្ពស់ការអនុវត្ត អភិក្រម ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់ សំដៅចូលរួមពង្រឹងអភិបាលកិច្ចល្អ និងនីតិរដ្ឋនៅក្នុងការដឹកនាំ គ្រប់គ្រងដែលជាមូលដ្ឋានចាំបាច់ក្នុងការអភិវឌ្ឍសង្គមជាតិ និងជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែល្អ ងាយស្រួល និងប្រសើរឡើងជាលំដាប់៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន






*គណៈប្រតិភូគណៈកម្មការទី១០ព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយថ្នាក់ដឹកនាំខេត្តស្វាយរៀង*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ អញ្ជើញសំណេះសំណាលជាមួយ អាជ្ញាធរក្រុង ស្រុក ឃុំ សង្កាត់ទូទាំងខេត្តកណ្ដាល




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ អញ្ជើញជួបពិភាក្សាការងារជាមួយអាជ្ញាធរក្រុងអរិយក្សត្រ ស្រុកល្វាឯម និងស្រុកខ្សាច់កណ្ដាល*

ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ (ខេត្តកណ្ដាល) ដឹកនាំដោយឯកឧត្ដម **ម៉ម ប៊ុននាង** ប្រធានក្រុម បានអញ្ជើញជួបសំណេះសំណាលជាបន្តបន្ទាប់ជាមួយថ្នាក់ដឹកនាំ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និងនាយប៉ុស្ដិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ នៅក្រុងអរិយក្សត្រ ស្រុកល្វាឯម ស្រុកខ្សាច់កណ្ដាល ស្រុកពញាឮ ស្រុកមុខកំពូល ស្រុកអង្គស្នួល ស្រុកកណ្ដាលស្ទឹង ស្រុកកោះធំ ក្រុងសំពៅពូន និងក្រុងតាខ្មៅ ខេត្តកណ្ដាល សរុបចំនួន៩៩៣នាក់ នៅថ្ងៃទី២៧ ខែមករា ថ្ងៃទី៤ ទី១១ ទី២៤ និងថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៦។



*ឯកឧត្ដម ម៉ម ប៊ុននាង ប្រធានក្រុម អញ្ជើញសំណេះសំណាល ជាមួយអាជ្ញាធរស្រុកខ្សាច់កណ្ដាល*

នៅគ្រប់ពិធីសំណេះសំណាល **ឯកឧត្ដមប្រធានក្រុម** បាននាំនូវបណ្ដាំសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភាជូនចំពោះអាជ្ញាធរគ្រប់ជាន់ថ្នាក់និងប្រជាពលរដ្ឋគ្រប់មូលដ្ឋាន និងបានជម្រាបជូនអំពីគោលបំណងនៃពិធីសំណេះសំណាល គឺដើម្បីលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព និងលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ តាមរយៈការធ្វើបទបង្ហាញអំពីតួនាទីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទាក់ទងនឹងវិវាទគ្រួសារ និងផ្សព្វផ្សាយអំពីសមិទ្ធផលការងាររបស់ព្រឹទ្ធសភាក្នុងឆ្នាំ២០២៥ ព្រមទាំងពិភាក្សាឈ្វេងយល់អំពីបញ្ហាប្រឈមសំណូមពរ និងវឌ្ឍនភាពនៅក្នុងមូលដ្ឋាន។

ក្នុងឱកាសនោះ **ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣** បានជម្រាបជូនអំពីការងារសំខាន់ៗរបស់ព្រឹទ្ធសភា




*ឯកឧត្ដម ប្រាក់ ចំរើន អនុប្រធានក្រុម អញ្ជើញមានមតិយោបល់ក្នុងពិធីសំណេះសំណាល*





*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ អញ្ជើញជួបពិភាក្សាការងារជាមួយអាជ្ញាធរស្រុកមុខកំពូល និងស្រុកអង្គស្នួល*

នីតិកាលទី៥ ព្រមទាំងផ្សព្វផ្សាយអំពីសមិទ្ធផលការងារក្នុងឆ្នាំ២០២៥ និងធ្វើបទបង្ហាញអំពីតួនាទីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការជួយសម្របសម្រួលទាក់ទងនឹងវិវាទក្នុងគ្រួសារ ព្រមទាំងជម្រាបជូនអង្គពិធីអំពីយុទ្ធនាការរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងតាមប្រព័ន្ធអនឡាញ និងជំរុញឱ្យអាជ្ញាធរពាក់ព័ន្ធយកចិត្តទុកដាក់ខ្ពស់ចំពោះការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាពឱ្យមានប្រសិទ្ធភាពខ្ពស់។

បន្ទាប់ពីបានពិភាក្សាគ្នារួចមក **ឯកឧត្តមប្រធានក្រុម** បានវាយតម្លៃខ្ពស់ចំពោះអាជ្ញាធរពាក់ព័ន្ធទាំងអស់ ដែលបានខិតខំបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់និងសម្រេចបានសមិទ្ធផលជាច្រើនគួរឱ្យកត់សម្គាល់។ ជាមួយគ្នានោះ ឯកឧត្តមបានអំពាវនាវដល់អង្គពិធីទាំងមូលនិងប្រជាពលរដ្ឋគ្រប់រូប បន្តសាមគ្គីគ្នាដើម្បីក្លាយជាកម្លាំងស្មារតីសាមគ្គីជាតិជាធ្លុងមួយ គាំទ្រដល់វីរកងទ័ព វីរនគរបាលជាតិគ្រប់រូប ដែលកំពុងឈរជើងយ៉ាងអង់អាចក្លាហាន ក្នុងការការពារដែនអធិបតេយ្យភាពនិងបូរណភាពទឹកដីរបស់កម្ពុជា។ ជាពិសេស សូមអំពាវនាវឱ្យកម្លាំងមហាសាមគ្គីភាពនេះ បន្តគាំទ្ររាជរដ្ឋាភិបាលដែលកំពុងប្រយុទ្ធតាមរយៈការទូតប្រឆាំងនឹងការឈ្លានពានរបស់ឃោធាថៃមកលើបូរណភាពទឹកដីកម្ពុជា។ សាមគ្គីរស់ សាមគ្គីឈ្នះ!

ក្នុងឱកាសនោះដែរ **ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣** បាននាំយកអំណោយឧបត្ថម្ភជូនក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ដោយក្នុងម្នាក់ៗទទួលបានអំណោយ១កញ្ចប់របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ និងថវិកាមួយចំនួន៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*លោកជំទាវបណ្ឌិត ចាន់ សុទ្ធាវី អញ្ជើញមានមតិយោបល់ក្នុងពិធីសំណេះសំណាល*



*លោកជំទាវ សួស សារ៉ាម អញ្ជើញមានមតិយោបល់ក្នុងពិធីសំណេះសំណាល*



*គណៈប្រតិភូក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ ថតរូបអនុស្សាវរីយ៍ជាមួយអាជ្ញាធរក្រុងតាខ្មៅ*

# ការលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ប្រកបដោយតម្លាភាព និងគណនេយ្យភាព គឺជាភារកិច្ចស្នូលរបស់ រដ្ឋបាលស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់

ឯកឧត្តម **ម៉ុល លឹម** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ បានលើកឡើងថា ក្នុងនាមជាអ្នកបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋ សូមរដ្ឋបាលស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ បន្តខិតខំលើកកម្ពស់ការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនទៅតាមច្បាប់ បទដ្ឋានគតិយុត្តនានា និងសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ប្រកបដោយការទទួលខុសត្រូវខ្ពស់ ព្រមទាំងលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ប្រកបដោយតម្លាភាព និងគណនេយ្យភាព។



ឯកឧត្តម ម៉ុល លឹម ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤

ការលើកឡើងបែបនេះ ក្នុងឱកាសដែល**ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤** (ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិន) ដឹកនាំដោយ ឯកឧត្តម **ម៉ុល លឹម** ប្រធានក្រុម បានអញ្ជើញជួបសំណេះសំណាលជាបន្តបន្ទាប់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ និងអាជ្ញាធរក្រុងរុនតាឯកតេជោសែន ស្រុកអង្គរធំ ស្រុកវ៉ារិន ខេត្តសៀមរាបចំនួន១៦២នាក់ និងស្រុកមោងឫស្សី ស្រុករុក្ខគិរី ខេត្តបាត់ដំបង ចំនួន១៩៧នាក់ នាព្រឹកថ្ងៃទី២៨ ខែមករា និងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦។

នៅគ្រប់ពិធីសំណេះសំណាល **ឯកឧត្តមប្រធានក្រុមភូមិភាគទី៤** បាននាំនូវបណ្តាំសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនដល់អ្នកចូលរួមក្នុងអង្គពិធី ព្រមទាំងបានគូសបញ្ជាក់អំពីគោលបំណង ដើម្បីឈ្វេងយល់និងផ្តល់ឱកាសជូនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ លើកឡើងអំពីបញ្ហាប្រឈមកង្វល់ តម្រូវការ និងសំណូមពរ ជុំវិញការអនុវត្តតួនាទី និងភារកិច្ចក្នុងការអនុវត្តច្បាប់ ដោយផ្តោតលើការងារស្ថិតិប្រជាពលរដ្ឋ (សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ) ការផ្លាស់ចេញចូល, ការងារអត្រានុកូលដ្ឋាន និងការកែតម្រូវអក្ខរាវិរុទ្ធ ការងារធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ, ការងារមូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់, ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាពទាំង៧





ឯកឧត្តម ម៉ុល លឹម អញ្ជើញជួបសំណេះសំណាលជាមួយអាជ្ញាធរក្រុងរុនតាឯកតេជោសែន ស្រុកអង្គរធំ និងស្រុកវ៉ារិន ខេត្តសៀមរាប




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ អញ្ជើញជួបសំណេះសំណាលជាមួយអាជ្ញាធរស្រុកមោងឫស្សីនិងស្រុករុក្ខគិរី ខេត្តបាត់ដំបង*

ចំណុច។

តាមរយៈការឡើងរាយការណ៍របស់អភិបាលរងខេត្ត អភិបាលស្រុក មតិយោបល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ និងការពិភាក្សាផ្លាស់ប្តូរបទពិសោធគ្នាយ៉ាងផុលផុស **ឯកឧត្តមប្រធានក្រុមភូមិភាគទី៤** បានវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំក្រុង ស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលឃុំ សង្កាត់ ដែលបានខិតខំបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនយ៉ាងល្អប្រសើរ និងបានអរគុណចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលឃុំ សង្កាត់ ដែលលើកឡើងនូវបញ្ហាប្រឈម សំណូមពរ និងចំណុចល្អៗជាច្រើន សម្រាប់ជាគុណប្រយោជន៍ក្នុងការបំពេញការងារឱ្យកាន់តែល្អប្រសើរថែមទៀត។ ចំពោះបញ្ហាប្រឈមនិងសំណូមពរនានា ដែលអាជ្ញាធរក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់បានលើកឡើង



*ឯកឧត្តម សត ណាឌី សមាជិកក្រុម អញ្ជើញមានមតិយោបល់ក្នុងអង្គពិធី*

ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ នឹងរាយការណ៍ជូនថ្នាក់ដឹកនាំព្រឹទ្ធសភានិងគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីលើកជាអនុសាសន៍ជម្រាបដល់ក្រសួងស្ថាប័នពាក់ព័ន្ធធ្វើការដោះស្រាយ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ អញ្ជើញជួបសំណេះសំណាលជាមួយអាជ្ញាធរស្រុកមោងឫស្សីនិងស្រុករុក្ខគិរី ខេត្តបាត់ដំបង*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ អញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ខេត្តព្រះសីហនុ

នាព្រឹកថ្ងៃពុធ ទី១១ ខែកុម្ភៈ ឆ្នាំ២០២៦ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ ដឹកនាំដោយឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានក្រុម និងមានការអញ្ជើញចូលរួមពីគណៈកម្មការទី១និងទី៣ ព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាលជាមួយ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ក្នុងខេត្តព្រះសីហនុ សរុបចំនួន១៥០នាក់។



*ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី សំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល នៅខេត្តព្រះសីហនុ*

ពិធីនេះរៀបចំឡើងដើម្បីផ្សារភ្ជាប់និងរួមប្រាស្រ័យទាក់ទងឱ្យកាន់តែជិតស្និទ្ធជាមួយអង្គបោះឆ្នោតដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នៅមូលដ្ឋាន, ឈ្វេងយល់ពីការអនុវត្តតួនាទីនិងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការអភិវឌ្ឍមូលដ្ឋាន ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព និងការផ្តល់សេវាជូនប្រជាពលរដ្ឋ និងចូលរួមដោះស្រាយ ឬនាំយកយោបល់ បញ្ហាប្រឈម និងសំណូមពរ របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងព្រឹទ្ធសភា។

ក្នុងឱកាសនោះ **ឯកឧត្តមប្រធានក្រុម** បានជម្រាបដល់អង្គពិធីអំពី មុខងារនិងអាទិភាពចម្បងរបស់ព្រឹទ្ធសភានីតិកាលទី៥ ក្នុងការលើកកម្ពស់ការទូតសភានិងការរួមប្រាស្រ័យឱ្យកាន់តែជិតស្និទ្ធជាមួយអង្គបោះឆ្នោត។ **ឯកឧត្តមប្រធានក្រុម** ក៏បានលើកឡើងអំពី ការបន្តអនុវត្តកំណែទម្រង់វិមជ្ឈការ វិសហមជ្ឈការ ដោយបន្តជំរុញការផ្ទេរសិទ្ធិនិងអំណាចទៅថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់គុណភាពជីវិតប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រព្រមទាំងធ្វើទំនើបកម្មសេវាសាធារណៈ ដោយផ្តោតលើការផ្តល់សេវាប្រកបដោយបរិយាបន្ន សមធម៌ និងយុត្តិធម៌ តាមរយៈកម្មវិធីជាតិដំណាក់-កាលទី២ (២០២១-២០៣០) ជាពិសេសចំពោះការបង្ក្រាបបទល្មើស ដូចជា គ្រឿងញៀន ល្បែងស៊ីសង និងការជួញដូរមនុស្ស និងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams) ព្រមទាំងបន្តពង្រឹងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព។

**ឯកឧត្តមប្រធានក្រុម** បានសម្តែងការដឹងគុណចំពោះវីរភាពដឹកនាំប្រកបដោយមនសិការស្នេហាជាតិ និងភាពវាងវៃដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានិងសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី ក្នុងការដឹកនាំ និងគ្រប់គ្រងស្ថានការណ៍របស់ប្រទេសជាតិ ដោយឈរលើគោលការណ៍



*ទិដ្ឋភាពក្រុមប្រឹក្សាឃុំ សង្កាត់ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល ចូលរួមក្នុងអង្គពិធី*







*ទិដ្ឋភាពក្រុមប្រឹក្សាឃុំ សង្កាត់ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល ចូលរួមក្នុងអង្គពិធី និងថតរូបអនុស្សាវរីយ៍*

សាមគ្គីភាពនិងសន្តិភាពនិយម ការពារផលប្រយោជន៍របស់ជាតិ ថែមទាំងខិតខំប្រឹងប្រែងឱ្យសម្រេចបាននូវបទឈប់បាញ់ ជុំវិញជម្លោះព្រំប្រទល់រវាងកម្ពុជា-ថៃ ដែលបានបង្ហាញពីភាពម៉ឺងម៉ាត់ និងស្វះស្វែងក្នុងការស្វែងរកសន្តិភាពរបស់កម្ពុជានៅលើឆាកអន្តរជាតិ។

ក្នុងឱកាសនោះផងដែរ ឯកឧត្តម **ឌី ច័ន្ទផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា ក៏បានចូលរួមមតិយោបល់លើបញ្ហាប្រឈមពាក់ព័ន្ធនឹងការធ្វើបណ្ណកម្មសិទ្ធនិងបញ្ហាដីធ្លី ព្រមទាំងអំពាវនាវដល់អាជ្ញាធរ និងប្រជាពលរដ្ឋ ក្នុងខេត្តព្រះសីហនុទាំងអស់ ជឿជាក់លើប្រមុខរាជរដ្ឋាភិបាលកម្ពុជា ជុំវិញការដោះស្រាយនូវជម្លោះព្រំដែនរវាងកម្ពុជា-ថៃនិងការពន្យល់ បកស្រាយបន្ថែមពី ឯកឧត្តម **ម៉ាង ស៊ីណេត** អភិបាលខេត្តព្រះសីហនុ ចំពោះបញ្ហាប្រឈមនៅក្នុងមូលដ្ឋាន ក៏ដូចជាការដោះស្រាយសំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួនផងដែរ។

តាងនាមក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ ឯកឧត្តមបណ្ឌិត **ម៉ុខ ឫទ្ធី** បានវាយតម្លៃខ្ពស់ចំពោះអាជ្ញាធរពាក់ព័ន្ធ ដែលបានខិតខំបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងសម្រេចបានសមិទ្ធផលជាច្រើនគួរឱ្យកត់សម្គាល់ ព្រមទាំងបានផ្លាស់ប្តូរនូវបទពិសោធល្អៗ និងកិច្ចសហការគាំទ្រគ្នាទៅវិញទៅមក បង្កភាពងាយស្រួលដល់សមាជិក សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ បង្កើនសមត្ថភាពចែករំលែកការអនុវត្តដែលជាបទពិសោធដ៏ប្រសើរកន្លងមកក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាពនិងអភិវឌ្ឍន៍មូលដ្ឋានឱ្យបានកាន់តែល្អប្រសើរឡើង។





*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ អញ្ជើញពិនិត្យការស្ថាបនាផ្លូវ និងទស្សនកិច្ចខ្សែសង្វាក់ផលិតកម្មរោងចក្រផលិតចំណីសត្វ*

មុននឹងបញ្ចប់ ឯកឧត្តមបណ្ឌិត **ម៉ុខ ឫទ្ធី** បានជូនក្រូចលឿងចំនួន១កេស និងសាច់ក្រកអស្ចារ្យ ចំនួន១កញ្ចប់ ក្នុង១នាក់ ដល់សមាជិកចូលរួមទាំងអស់។

សូមជម្រាបថា មុននឹងចាប់ផ្តើមកម្មវិធី សមាជិក សមាជិកានៃអង្គពិធីបានអញ្ជើញពិនិត្យការស្ថាបនាផ្លូវក្រាលកៅស៊ូមួយខ្សែតភ្ជាប់ពីផ្លូវជាតិលេខ៤ ទៅផ្លូវអន្លង់ក្រពើ មានប្រវែង១.៩៧១ម៉ែត្រ ទទឹង៦.៤ម៉ែត្រនិងទស្សនកិច្ចខ្សែច្រវាក់ផលិតកម្មរោងចក្រផលិតចំណីសត្វ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ អញ្ជើញជួបសំណេះសំណាលជាមួយអាជ្ញាធរស្រុកបាទី ខេត្តតាកែវ






*ឯកឧត្តម ឈួន ឆាម (កណ្តាល) សំណេះសំណាលជាមួយអាជ្ញាធរស្រុកបាទី ខេត្តតាកែវ*

នាចន្លោះសម័យប្រជុំលើកទី៤និងទី៥របស់ព្រឹទ្ធសភា ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ (ខេត្តកំពត ខេត្តតាកែវ និងខេត្តកែប) ដឹកនាំដោយឯកឧត្តម **ឈួន ឆាម** ប្រធានស្តីទីក្រុម បានអញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំស្រុក ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ ស្រុកបាទី ខេត្តតាកែវ សរុបចំនួន១៦៦នាក់ នៅសាលាស្រុកបាទី ខេត្តតាកែវ នាព្រឹកថ្ងៃចន្ទ ទី២៦ ខែមករា ឆ្នាំ២០២៦។

ក្នុងឱកាសនោះ អង្គពិធីបានគោរពវិញ្ញាណក្ខន្ធវីរយុទ្ធជននិងដឹងគុណចំពោះពលិកម្មគ្រប់បែបយ៉ាង ដែលមិនអាចកាត់ថ្លៃបានរបស់វីរយុទ្ធជន ក្នុងបុព្វហេតុការពារជាតិមាតុភូមិ និងប្រជាពលរដ្ឋ។ **ឯកឧត្តមប្រធានស្តីទី** បាននាំនូវការផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនចំពោះថ្នាក់ដឹកនាំខេត្ត មន្ត្រីរាជការ កងកម្លាំងនៅមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ប្រជាពលរដ្ឋក្នុងស្រុកបាទី និងក្នុងខេត្តតាកែវទាំងមូលប្រកបដោយក្តីនឹករលឹកបំផុតនិងបានជម្រាបជូនអង្គពិធីអំពីគោលបំណងនៃបេសកកម្មនេះ គឺផ្តោតជាសំខាន់លើបញ្ហាប្រឈម តម្រូវការ និងសំណូមពររបស់មូលដ្ឋាន ក្នុងការរួមចំណែកលើកកម្ពស់ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព






*ឯកឧត្តម អ៊ុន វណ្ណា សមាជិកក្រុម អញ្ជើញមានមតិយោបល់ក្នុងអង្គពិធី*



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ថតរូបអនុស្សាវរីយ៍ ជាមួយអ្នកចូលរួមពិធី*

ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការងារផ្តល់អត្តសញ្ញាណកម្មជូនប្រជាពលរដ្ឋ ការងារលទ្ធកម្ម និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន។

**ឯកឧត្តមប្រធានស្តីទី** បានមានប្រសាសន៍ផ្តាំផ្ញើដល់ថ្នាក់ដឹកនាំស្រុក ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ នៃស្រុកបាទី សូមបន្តយកចិត្តទុកដាក់អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវកិច្ចការថែរក្សាការពារសន្តិភាពក្នុងមូលដ្ឋាន បន្តបម្រើនិងផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព។

បន្ទាប់មកនៅរសៀលថ្ងៃដដែលនោះ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ បានអញ្ជើញចុះជួបសំណេះ-សំណាលជាមួយក្រុមប្រឹក្សាឃុំនិងអាជ្ញាធរក្នុងឃុំលំពង់ស្រុកបាទី ខេត្តតាកែវ ដើម្បីស្តាប់នូវសេចក្តីរាយការណ៍របស់លោកមេឃុំ ជុំវិញការវិវឌ្ឍរីកចម្រើនក្នុងមូលដ្ឋាន ជាពិសេសការកសាងហេដ្ឋារចនាសម្ព័ន្ធនានាក្នុងមូលដ្ឋាន ព្រមទាំងបានចុះទៅពិនិត្យមើលវឌ្ឍនភាពនៃការប្រើប្រាស់ស្រះទឹកមួយកន្លែងក្នុងវត្តស្រះស្រែ ស្ថិតនៅភូមិថ្នស ឃុំលំពង់ ស្រុកបាទី ខេត្តតាកែវ។

គួររំលឹកផងដែរថា ស្រះទឹកវត្តស្រះស្រែ បានជីកកាលពីនីតិកាលទី៣ នៃព្រឹទ្ធសភា ដោយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ដែលមានទំហំ៦០mx៤០mx៤,៧០m និងបានជីករួចរាល់កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ កន្លងទៅ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ អញ្ជើញជួបសំណេះសំណាល ជាមួយក្រុមប្រឹក្សាឃុំលំពង់*





*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ អញ្ជើញចុះពិនិត្យមើលស្រះទឹកវត្តស្រះស្រែ*

# ក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបប្រជុំជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ ក្នុងភូមិភាគទី៨

ក្នុងគោលបំណងពង្រឹងពង្រីកការអនុវត្តមុខងារតំណាងឱ្យមានគុណភាព តម្លាភាព ប្រសិទ្ធភាព និងគណនេយ្យភាព នៅចន្លោះសម័យប្រជុំលើកទី៤និងលើកទី៥ របស់ព្រឹទ្ធសភា ក្រុមសមាជិកាព្រឹទ្ធសភាបានបែងចែកជាពីរក្រុម ដើម្បីចុះជួបប្រជុំជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ ក្នុងភូមិភាគទី៨ ដោយក្រុមទី១ដឹកនាំដោយ លោកជំទាវ **មាន សំអាន** ប្រធានក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញចុះទៅកាន់ខេត្តក្រចេះ រតនគិរី និងខេត្តមណ្ឌលគិរី និងចំណែកក្រុមទី២ ដឹកនាំដោយ លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** អនុប្រធានក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញចុះទៅកាន់ខេត្តកំពង់ធំ ព្រះវិហារ ស្ទឹងត្រែង និងខេត្តមណ្ឌលគិរី កាលពីថ្ងៃទី៩ ដល់ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៦។

នៅតាមកិច្ចប្រជុំនីមួយៗ **ក្រុមសមាជិកាព្រឹទ្ធសភា** បាននាំនូវបណ្តាំសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា និងជម្រាបអំពីគោលបំណងនៃការចុះជួបប្រជុំ ដើម្បីផ្សារភ្ជាប់ និងការរួមប្រាស្រ័យទំនាក់ទំនងឱ្យកាន់តែជិតស្និទ្ធជាមួយអង្គបោះឆ្នោត ដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងឈ្វេងយល់ពីវឌ្ឍនភាពការងារឆ្នាំ២០២៥ តម្រូវការ ការអនុវត្តគោលនយោបាយស្តីពីការលើកកម្ពស់សមភាពយេនឌ័រ ផែនការសកម្មភាពការងារសម្រាប់ឆ្នាំ២០២៦ និងឆ្លុះបញ្ចាំងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឃុំ សង្កាត់ ឆ្នាំ២០២២-២០២៧ ព្រមទាំងបានស្តាប់ផ្ទាល់ពីលោក លោកស្រី ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាអ្នកអនុវត្តផ្ទាល់ជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន។

**ក្រុមសមាជិកាព្រឹទ្ធសភា** បានជម្រាបអំពីសមិទ្ធផលសំខាន់ៗរបស់ព្រឹទ្ធសភា នីតិកាលទី៥ និងអាទិភាពចម្បងចំនួនពីរ គឺទី១-ការលើកកម្ពស់ការទូតសភានិងទី២-ត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គបោះឆ្នោត ជាពិសេសជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាតំណាងឱ្យប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រមទាំងមុខងារស្នូលទាំងបីរបស់ព្រឹទ្ធសភា គឺមុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារ



*លោកជំទាវ មាន សំអាន ក្នុងកិច្ចប្រជុំជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារខេត្តក្រចេះ*



*លោកជំទាវបណ្ឌិត ចាន់ សុទ្ធាវី ក្នុងកិច្ចប្រជុំជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ ក្នុងខេត្តព្រះវិហារ*

តំណាង។

ជាមួយគ្នានោះ **ក្រុមសមាជិកាព្រឹទ្ធសភា**ក៏បានជម្រាបជូនផងដែរអំពីសភាពការណ៍អន្តរជាតិ ដែលបាននិងកំពុងកើតមាននាពេលបច្ចុប្បន្ន ការបោះឆ្នោតនៅប្រទេសថៃ ព្រមទាំងជម្លោះព្រំដែនកម្ពុជា-ថៃ និងបានអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋត្រូវតស៊ូ អត់ធ្មត់ ជឿទុកចិត្តលើថ្នាក់ដឹកនាំរាជរដ្ឋាភិបាលនិងវីរភាពដ៏អង់អាចក្លាហានរបស់វីរកងទ័ពរបស់យើង និងរួមសាមគ្គីគ្នាជាធ្លុងមួយឱ្យបានរឹងមាំ ក្នុងគ្រាដែលប្រទេសជាតិកំពុងជួបប្រទះសង្គ្រាមឈ្លានពានពីថៃ។

ឆ្លងតាមការពិភាក្សានិងផ្លាស់ប្តូរមតិយោបល់យ៉ាងផុលផុស **ក្រុមសមាជិកាព្រឹទ្ធសភា**បានវាយតម្លៃខ្ពស់ចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ ជាពិសេសស្ត្រី ដែលបានលះបង់

ទាំងកម្លាំងកាយចិត្ត ឆន្ទៈ និងស្មារតីបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន និងសូមបន្តបម្រើប្រជាពលរដ្ឋឱ្យបានល្អជាពិសេសធានាឱ្យបាននូវការអនុវត្តភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការលើកកម្ពស់ការផ្តល់សេវាសាធារណៈឱ្យកាន់តែល្អប្រសើរនិងបន្តយកចិត្តទុកដាក់តាមដានអនុវត្តនូវការសន្យានាអំឡុងពេលឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់កន្លងមក ហើយត្រូវចេះលើកផែនការថវិកាអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន។ ចំពោះបញ្ហាប្រឈម និងសំណូមពរនានា ដែលក្រុមប្រឹក្សាឃុំ សង្កាត់បានលើកឡើង ក្រុមសមាជិកាព្រឹទ្ធសភាទទួលយកនិងសម្រិតសម្រាំងយកបញ្ហាប្រឈមនិងសំណូមពរណាដែលជាអាទិភាព ដើម្បីធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងលើកជាអនុសាសន៍ជម្រាបជូនក្រសួង ស្ថាប័នពាក់ព័ន្ធរួមគ្នាដោះស្រាយ។

ក្នុងឱកាសនោះផងដែរ **ក្រុមសមាជិកាព្រឹទ្ធសភា**បានជូននូវដបទឹករក្សាកម្តៅចំនួន១ដប ក្រណាត់កាត់ឯកសណ្ឋានឃុំ សង្កាត់៣ម៉ែត្រ ក្រមា និងថវិកាមួយចំនួន ដល់អាជ្ញាធរពាក់ព័ន្ធ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុក ក្រុង ព្រមទាំងជូនកុំព្យូទ័រយួរដៃចំនួន១គ្រឿង ដល់អ្នកទទួលបន្ទុកកិច្ចការនារី  និងកុមារឃុំសណ្តាន់ ស្រុកសំបូរ ខេត្តក្រចេះ។



ក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញជួបប្រជុំជាមួយថ្នាក់ដឹកនាំខេត្ត ក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រីក្នុងក្រុងស្រុកចំនួន៥ ខេត្តមណ្ឌលគិរី

ក្នុងឱកាសបំពេញការងារនៅខេត្តមណ្ឌលគិរី ក្រុមសមាជិកាព្រឹទ្ធសភា ដឹកនាំដោយ លោកជំទាវ **មាន សំអាន** ប្រធានក្រុម បានអញ្ជើញចុះជួបសំណេះសំណាលជាមួយលោកស្រី **នេត ឆាយា** ចៅសង្កាត់សុខដុមនិងតំណាងសហគមន៍មនុស្សចាស់ ព្រមទាំងនាំយកភួយ ក្រមា ប្រអប់ដាក់អាហារ និងឧបត្ថម្ភថវិកាដល់សហគមន៍មនុស្សចាស់ចំនួន៥០ម៉ឺនរៀល សាលាសង្កាត់ចំនួន២០ម៉ឺនរៀល និងសមាជិកសហគមន៍៤នាក់ ក្នុងម្នាក់១០ម៉ឺនរៀល ព្រមទាំងបានជំរុញរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបន្តផ្តល់ការអន្តរាគមន៍ជំរុញសកម្មភាពបង្កើតសមាគមមនុស្សចាស់បន្ថែមទៀតនៅតាមសហគមន៍មូលដ្ឋាន ស្របតាមផែនការដែលបានកំណត់ ឈរលើស្មារតីសាមគ្គីភាពជួយគ្នាទៅវិញទៅមករវាងមនុស្សវ័យចាស់ទូទៅ។

ទន្ទឹមគ្នានោះ ក្រុមសមាជិកាព្រឹទ្ធសភាដឹកនាំដោយលោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** អនុប្រធានក្រុម បានអញ្ជើញទស្សនកិច្ចសហគមន៍បន្លែធម្មជាតិ នៅសង្កាត់មនោរម្យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ក្នុងគោលបំណងចូលរួមលើកទឹកចិត្តដល់គ្រួសារ នៃសហគមន៍បន្លែធម្មជាតិ និងបន្តអភិវឌ្ឍន៍លើការដាំដុះបន្លែជាសហគមន៍គ្រួសារឱ្យកាន់តែរីកចម្រើនថែមទៀត ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសង្គមជាតិ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





ទិដ្ឋភាពក្នុងកិច្ចប្រជុំពិភាក្សាការងារ

# ឯកឧត្តម ម៉ម ប៊ុននាង ទទួលស្វាគមន៍សាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យវ៉ាន់ដា មកបំពេញទស្សនកិច្ចស្វែងយល់អំពីព្រឹទ្ធសភា

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២៩ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការ


*ឯកឧត្តម ម៉ម ប៊ុននាង ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា*

អង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ នៃព្រឹទ្ធសភា (គណៈកម្មការទី១០) បានអញ្ជើញទទួលស្វាគមន៍សាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យវ៉ាន់ដា ចំនួន១៥០នាក់ មកបំពេញទស្សនកិច្ចស្វែងយល់អំពី ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា។

នាឱកាសនោះ ឯកឧត្តម **ម៉ម ប៊ុននាង** បានធ្វើបទបង្ហាញជូនដល់គណៈប្រតិភូ អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភាកម្ពុជា ចាប់តាំងពីការចាប់បដិសន្ធិ នីតិកាលទី១ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ និងការវិវត្តប្រែប្រួលពីមួយនីតិកាលទៅមួយនីតិកាល រហូតដល់នីតិកាលទី៥។

ឯកឧត្តមបានមានប្រសាសន៍ថា ព្រឹទ្ធសភាមានសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្ដាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ក្នុងនីតិកាលទី៥នេះ ព្រឹទ្ធសភាមានសមាជិកចំនួន៦២រូប ក្នុងនោះ៥៨រូប ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាអសកលពីសំណាក់សមាជិករដ្ឋសភា និងក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង, ២រូបត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និង២រូបទៀត ត្រូវបានជ្រើសតាំងដោយរដ្ឋសភា តាមមតិភាគច្រើនដោយប្រៀប។ អាណត្តិរបស់ព្រឹទ្ធសភាមានរយៈពេល៦ឆ្នាំ។

ឯកឧត្តមបានគូសបញ្ជាក់ថា ព្រឹទ្ធសភា នីតិកាលទី៥ ដឹកនាំដោយ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រធាន, ឯកឧត្តម **អ៊ុច បូររិទ្ធ** ជាអនុប្រធានទី១ និងឯកឧត្តមបណ្ឌិត **ឆន់ ខឡូនា** ជាអនុប្រធានទី២។


*ឯកឧត្តម ម៉ម ប៊ុននាង អញ្ជើញធ្វើបទបង្ហាញ ជូននិស្សិតសាកលវិទ្យាល័យវ៉ាន់ដា*


*លោកស្រី យុន សុវណ្ណនេត្រា និងលោក សុខ សុជាតិ ធ្វើបទបង្ហាញជូននិស្សិតសាកលវិទ្យាល័យវ៉ាន់ដា*



*ទិដ្ឋភាពនិស្សិតសាកលវិទ្យាល័យវ៉ាន់ដា ស្តាប់បទបង្ហាញ*

ព្រឹទ្ធសភាមានគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលជាក្បាលម៉ាស៊ីនមានសមត្ថកិច្ចសម្រេចរាល់សកម្មភាពរបស់យន្តការនានានៃព្រឹទ្ធសភា។ ព្រឹទ្ធសភានៅមានយន្តការផ្សេងទៀត ដូចជាក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨, ក្រុមសមាជិកាព្រឹទ្ធសភា, ក្រុមមិត្តភាពទ្វេភាគី ពហុភាគីជាមួយសភាបរទេស និងអង្គការអន្តរជាតិ។

ក្នុងនាមជាចំណែកមួយនៃអង្គនីតិប្បញ្ញត្តិ ព្រឹទ្ធសភាមានមុខងារចំនួន៣ គឺមុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង។ នៅនីតិកាលទី៥នេះ ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប៉ិនប្រសប់ និងប្រកបដោយគតិបណ្ឌិតរបស់ សម្តេចតេជោ **ហ៊ុន សែន** បានកំណត់អាទិភាពការងារចម្បង២ គឺការរួមប្រាស្រ័យឱ្យកាន់តែជិតស្និទ្ធជាមួយអង្គបោះឆ្នោត និងការងារលើកកម្ពស់ការទូតសភា។

ទន្ទឹមនឹងនេះ **ឯកឧត្តមប្រធាន** ក៏បានអំពាវនាវដល់និស្សិតទាំងអស់ត្រូវជឿទុកចិត្តលើការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ដែលមានសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** ជាប្រមុខដឹកនាំ ប្រទេសជាតិយើងនឹងទទួលបាននូវសុខសន្តិភាពពីការឈ្លានពានរបស់ថៃ។

ក្នុងឱកាសនោះផងដែរ ក៏មានបទបង្ហាញស្តីពី ដំណើរការនីតិកម្មរបស់ព្រឹទ្ធសភា ដោយលោក **សុខ សុជាតិ** ប្រធានក្រុមស្រាវជ្រាវទូទៅ នៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដោយលោកស្រី **យុន សុវណ្ណនេត្រា** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស។

បន្ទាប់ពីស្តាប់ការធ្វើបទបង្ហាញរួចមក សាស្ត្រាចារ្យ និងនិស្សិតទាំងអស់ បានអញ្ជើញទស្សនាសាលប្រជុំព្រឹទ្ធសភា និងអគារប្រវត្តិសាស្ត្រនានា នៅក្នុងបរិវេណវិមានព្រឹទ្ធសភា៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*និស្សិតសាកលវិទ្យាល័យវ៉ាន់ដា អញ្ជើញទស្សនាសាលប្រជុំព្រឹទ្ធសភា និងថតរូបអនុស្សាវរីយ៍*

# កិច្ចប្រជុំគណៈកម្មការទាំង១០ ក្រុមភូមិភាគ និងក្រុមនានានៃព្រឹទ្ធសភា

### ❈គណៈកម្មការទី១ព្រឹទ្ធសភា ជួបភ្ញៀវជាតិ ចំនួន១លើក

នាថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ឱ ច័ន្ទ្រផល**



ប្រធានគណៈកម្មការ បានទទួលជួបជាមួយមន្ត្រី នៃក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីធ្វើបទសម្ភាសអំពី «ប្រវត្តិនៃការបង្កើតប្រព័ន្ធគាំពារសង្គមនៅកម្ពុជា»។

### ❈គណៈកម្មការទី១ព្រឹទ្ធសភា ជួបភ្ញៀវអន្តរជាតិ ចំនួន១លើក



នាថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ឱ ច័ន្ទ្រផល** ប្រធានគណៈកម្មការ បានជួបជាមួយ ឯកឧត្តម **ឯកណាត ដាភាល់** អគ្គលេខាធិការ នៃសន្និសីទប្រធានសភានៃអន្តរសភា (ISC) ដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងការត្រៀមរៀបចំសន្និសីទប្រធានសភា នៃអន្តរសភា (ISC) ដែលត្រៀមរៀបចំនៅក្នុងព្រះរាជាណាចក្រកម្ពុជានាឆ្នាំ២០២៦ នៅសណ្ឋាគារ Hyatt Regency។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី២ព្រឹទ្ធសភា ចំនួន១លើក



នាថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំពិនិត្យពិភាក្សាលើរបាយការណ៍ប្រចាំខែកុម្ភៈ, ការចុះបេសកកម្មរបស់គណៈកម្មការទៅខេត្តត្បូងឃ្មុំនិងមណ្ឌលគិរី (ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៥ ខែកុម្ភៈ) និងស្តាប់បទបង្ហាញរបស់ក្រុមធុរជនន៍ និងកិច្ចការផ្សេងៗ។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៣ព្រឹទ្ធសភា ចំនួន១លើក

នាព្រឹកថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំពិនិត្យពិភាក្សាលើការបូកសរុបលទ្ធផលសកម្មភាពប្រចាំខែមករា និងទិសដៅការងារខែកុម្ភៈឆ្នាំ២០២៦,ការត្រៀមលក្ខណៈជួបពិភាក្សាការងារជាមួយឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងឯកឧត្តមរដ្ឋមន្ត្រីក្រសួងផែនការ ក្នុងគោលបំណងឈ្វេងយល់ពីវឌ្ឍនភាពការងារ បញ្ហាប្រឈមប្រចាំឆ្នាំ២០២៥និងទិសដៅការងាររបស់ក្រសួងប្រចាំឆ្នាំ២០២៦ និងបញ្ហាផ្សេងៗ។

### ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ ចំនួន១លើក



នាព្រឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ម៉ុង ឬទ្ធី** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំពិនិត្យនិងពិភាក្សាអំពី ការរៀបចំពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀននិងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលទាំងអស់ ក្នុងស្រុកព្រៃនប់ ខេត្តព្រះសីហនុ និងបញ្ហាផ្សេងៗ។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៤ព្រឹទ្ធសភា ចំនួន១លើក



នាព្រឹកថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិភាក្សាការងារ អំពីគម្រោងចុះបេសកកម្មរបស់គណៈកម្មការទៅខេត្តក្រចេះ។

### ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ចំនួន១លើក

នាព្រឹកថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំពិនិត្យនិងសម្រេចលើរបាយការណ៍សកម្មភាពប្រចាំខែមករា និង



ទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២៦, សេចក្តីព្រាងគ្រោងចុះសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ នៅខេត្តក្រចេះ និងបញ្ហាផ្សេងៗ។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៥ព្រឹទ្ធសភា ចំនួន២លើក៖

ឯកឧត្តមបណ្ឌិត **ឈីវ យីស៊ាង** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖

-នារសៀលថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦ ពិនិត្យ



ពិភាក្សាលើការបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំខែមករា ឆ្នាំ២០២៦ និងទិសដៅបន្ត, ការបូកសរុបចំណូល-ចំណាយថវិកាប្រចាំខែមករា ឆ្នាំ២០២៦និងបញ្ហាផ្សេងៗ។

-នាព្រឹកថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦ ពិនិត្យពិភាក្សាលើឯកសារបេសកកម្មនិងឯកសារជំនួបជាមួយក្រសួងពាក់ព័ន្ធនាចន្លោះសម័យប្រជុំលើកទី៤និងទី៥និងបញ្ហា



ផ្សេងៗ។

**❈គណៈកម្មការទី៥ព្រឹទ្ធសភា ជួបភ្ញៀវអន្តរជាតិ ចំនួន១លើក**



នាព្រឹកថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឈីវ យីស៊ាង** ប្រធានគណៈកម្មការ បានទទួលជួប និងពិភាក្សាការងារជាមួយ លោកជំទាវ Milena Caridad Zaldivar Piedra ឯកអគ្គរដ្ឋទូតគុយបាប្រចាំព្រះរាជាណាចក្រកម្ពុជា នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៧ព្រឹទ្ធសភា ចំនួន២លើក៖**

-នាថ្ងៃសុក្រ ទី២០ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ឈិត សុខុន** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំពិនិត្យនិងពិភាក្សាលើរបាយការណ៍ ស្ដីពីលទ្ធផលការងាររបស់គណៈកម្មការប្រចាំខែកុម្ភៈនិងទិសដៅការងារខែមីនា ឆ្នាំ២០២៦, ឯកសារសំខាន់ៗមួយចំនួនសម្រាប់ត្រៀមជួប



ពិភាក្សាការងារជាមួយអាជ្ញាធរខេត្តនិងមន្ទីរជំនាញពាក់ព័ន្ធ នៅខេត្តកំពត និងព្រះសីហនុ ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦ និងបញ្ហាផ្សេងៗ។



-នាថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញស្ដាប់បទបង្ហាញរបស់ក្រុមការងារស្រាវជ្រាវ នៃអគ្គនាយកដ្ឋានស្រាវជ្រាវ លើប្រធានបទស្ដីពី ការគាំទ្រមរតកសន្តិភាពនិងស្ថិរភាពនៅកម្ពុជា និងគំនិតផ្ដួចផ្ដើមរបស់ថ្នាក់ជាតិសម្រាប់ភាពមិនចាញ់ (Invincibility) តាមរយៈ Consciousness-Based Approach។



### ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ចំនួន១លើក

នាព្រឹកថ្ងៃចន្ទ ទី២៦ ខែមករា ឆ្នាំ២០២៦ លោកជំទាវ **មាន សំអាន** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការចុះបេសកកម្មទៅខេត្តព្រៃវែងនិង ខេត្តស្វាយរៀង និងបញ្ហាផ្សេងៗ។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៩ព្រឹទ្ធសភា ចំនួន១លើក



នាថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការបានដឹកនាំកិច្ចប្រជុំពិភាក្សាលើការត្រៀមចុះបេសកកម្មរបស់គណៈកម្មការនៅចន្លោះសម័យប្រជុំលើកទី៤និងលើកទី៥ ព្រឹទ្ធសភានីតិកាលទី៥ និងបញ្ហាផ្សេងៗ។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១០ព្រឹទ្ធសភា ចំនួន១លើក

នាថ្ងៃព្រហស្បតិ៍ទី១៩ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ម៉ម ប៊ុនណាង** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំពិនិត្យសម្រេចលើសេចក្តីព្រាងរបាយការណ៍ស្តីពី លទ្ធផលការងារប្រចាំខែកុម្ភៈនិងលើកទិសដៅការងារបន្ត។

### ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ចំនួន១លើក



នាថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ឈួន ឆាម** ប្រធានស្តីទីក្រុម បានដឹកនាំកិច្ចប្រជុំពិនិត្យពិភាក្សាលើរបាយការណ៍សកម្មភាពប្រចាំខែមករានិងទិសដៅខែកុម្ភៈ ឆ្នាំ២០២៦, របាយការណ៍ស្តីពីលទ្ធផលនៃពិធីសំណេះ-សំណាលនៅស្រុកបាទី ខេត្តតាកែវ និងបញ្ហាផ្សេងៗ៕

## ការទទួលពាក្យបណ្តឹង

❈ក្នុងខែកុម្ភៈ ឆ្នាំ២០២៦ គណៈកម្មការទី១ព្រឹទ្ធសភា បានទទួលពាក្យបណ្តឹងចូលចំនួន៤បណ្តឹង បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន៣បណ្តឹង កំពុងពិនិត្យសិក្សាចំនួន១១បណ្តឹង (សល់ពីឆ្នាំ២០២៥ ២បណ្តឹង, ខែមករា ៥បណ្តឹង, ក្នុងខែកុម្ភៈ ៤បណ្តឹង) ធ្វើកំណត់បង្ហាញគោរពរាយការណ៍ជូន**សម្តេចតេជោ** ប្រធានព្រឹទ្ធសភា ពីលទ្ធផលនៃការដោះស្រាយពាក្យបណ្តឹងរបស់គណៈកម្មការចំនួន២បណ្តឹង ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធចំនួន២បណ្តឹង ទទួលឯកសារជូនជ្រាបពីក្រសួងស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការចំនួន៤បណ្តឹង៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្ដាភូមិភាគទាំង៨



❈នាព្រឹកថ្ងៃសុក្រ ទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញនាំយកម៉ាស់ការពារផ្សែងពុលចំនួន២៨កេស តម្រង ម៉ាស់ការពារផ្សែងពុល(ប្រភេទធ្យូង)ចំនួន១០កេស តម្រង ម៉ាស់ការពារផ្សែងពុល(ប្រភេទកប្បាស)ចំនួន២កេស និងស្រូវចំនួន១០បាវ ប្រគល់ជូនរដ្ឋបាលខេត្តព្រះវិហារ ដើម្បីចាត់ចែងប្រគល់ជូនអង្គភាពពាក់ព័ន្ធយកទៅប្រើប្រាស់តាមការចាំបាច់ នៅសាលាខេត្តព្រះវិហារ។

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញ៖



-ប្រជុំពិភាក្សាការងារជាមួយអាជ្ញាធរ និងមន្ត្រីសុរិយោដីស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដើម្បីចូលរួមចំណែកអភិវឌ្ឍលើវិស័យកសិកម្ម កសិ-ឧស្សាហកម្ម ការចិញ្ចឹមសត្វ និងការអភិវឌ្ឍន៍ដីធ្លី នៅក្នុងមូលដ្ឋាន ព្រមទាំងទស្សនកិច្ចនៅក្នុងតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នាព្រឹកថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦។

-ជួបសំណេះសំណាល សួរសុខទុក្ខ និងចុះពិនិត្យមើលកម្មករចាក់បេតុង ព្រមទាំងបាននាំយកអាហារបាយចម្អិនដោយស្វ័យប្រវត្តិ និងផ្លែក្រូច ចែកជូនកម្មករ នៅភូមិស្វាយដង្គុំ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦។



-ជួបសំណេះសំណាលជាមួយសហគ្រិនវ័យក្មេងកម្ពុជា ចំនួន៥៥នាក់ ដែលបានធ្វើទស្សនកិច្ចសិក្សាស្វែងយល់នៅក្នុងតំបន់កសិកម្ម កសិ-ឧស្សាហកម្ម ការដាំដំណាំ និងការចិញ្ចឹមសត្វ នៅឃុំកែវផុស ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៦។



-ចុះពិនិត្យសកម្មភាពក្រុមការងារគ្រឿងចក្រសម្រុកស្ថាបនាគ្រឹះផ្លូវមួយខ្សែតភ្ជាប់ពីផ្លូវភ្លោះ ភូមិសំរោងជើងភ្នំ ប្រវែង៣.៨០០ម៉ែត្រ និងពិនិត្យសកម្មភាពក្រុមការងារសាងសង់រោងចក្រជីធម្មជាតិ នៅភូមិមហាលំពាំងទី១ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៦។

-ជួបសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស សរុបចំនួន១១៧នាក់ មកពីវិទ្យាល័យ ហ៊ុន សែន អូរកុង ស្ថិតក្នុងឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្ដាល ដែលអញ្ជើញមកធ្វើទស្សនកិច្ចស្វែងយល់ពីប្រវ៉ាក់ផលិតកម្មការងារ ដើម្បីជាការតម្រង់ទិសក្នុងការជ្រើសរើសមុខវិជ្ជា និងជំនាញសម្រាប់ថ្នាក់ឧត្តមសិក្សា នៅក្នុងតំបន់រមណីយដ្ឋានអភិវឌ្ឍន៍



កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ឃុំសែនដី ស្រុកសំរោង-ទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៦។



-ឧបត្ថម្ភបាយប្រអប់សាច់ជ្រូក, សាច់គោ និងសាច់មាន់សរុបចំនួន៧៥កេស ជូនលោកជំទាវ **គាត កិច្ច** អនុប្រធានមន្ទីរពេទ្យបង្អែក១៦មករា ខេត្តព្រះវិហារ ដើម្បីចែកជូនដល់វីរកងទ័ព ដែលកំពុងសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ និងបុគ្គលិកពេទ្យ ព្រមទាំងជូនវីរកងទ័ពជួរមុខដែលឈរជើងនៅតំបន់អានសេះ នៅខេត្តព្រះវិហារ នាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៦។

-ជួបសំណេះសំណាល សួរសុខទុក្ខកម្មករ និងចុះពិនិត្យទំនប់ទឹកនៅក្នុងតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ព្រមទាំងបានជីកស្រះទឹកធំៗចំនួន៧ស្រះ ដើម្បីត្រងយកទឹកភ្លៀងដែលហូរធ្លាក់មកពីភ្នំម្រះព្រៅ សម្រាប់ប្រជាពលរដ្ឋប្រើប្រាស់ប្រចាំថ្ងៃ នៅឃុំសែនជ័យ ស្រុកសំរោង-ទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦។



-ទទួលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូក្លឹបអ្នកកាសែតកម្ពុជាមកពី៣៦ស្ថាប័ន ដើម្បីសិក្សាឈ្វេងយល់អំពីដំណើរការអាជីវកម្ម ការផលិតប្រហុក ដាំដំណាំដូងប្រេង រោងចក្រកែច្នៃផ្លែដូងប្រេងស្រស់ រោងចក្រផលិតចំណីសត្វ ចិញ្ចឹមជ្រូក ចិញ្ចឹមត្រី វិទ្យាស្ថានកសិកម្មឧកញ៉ា ម៉ុង ឫទ្ធី នៅក្នុងតំបន់អភិវឌ្ឍន៍ដំណាំកសិកម្ម កសិ-ឧស្សាហកម្ម ការដាំនិងការចិញ្ចឹមសត្វរបស់ក្រុមហ៊ុន ម៉ុង ឫទ្ធី គ្រុប នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៦។

❈នាព្រឹកថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៦ លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីសំណេះសំណាល និងចែករង្វាន់ជ័យលាភីបេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និទ្ទេស A នៅវិទ្យាល័យហ៊ុនសែនសំពៅពូន ខេត្តកណ្ដាល។

❈នាថ្ងៃព្រហស្បតិ៍ ទី១២ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបុណ្យសពលោក **ឈុប ចឹក** មេឃុំបឹងព្រះ នៅឃុំបឹងព្រះ ស្រុកបាភ្នំ ខេត្តព្រៃវែង។

❈នាព្រឹកថ្ងៃចន្ទ ទី១៦ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា និង ឯកឧត្តម **ទឹម ផន** លេខាធិការគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបញ្ចុះបឋមសិលាសាងសង់អគារមន្ទីរពេទ្យសម្រាប់វះកាត់ និងសង្គ្រោះបន្ទាន់ចំនួន២ខ្នង (១ខ្នងនៅមន្ទីរពេទ្យខេត្តព្រៃវែង និង១ខ្នង នៅមន្ទីរពេទ្យបង្អែកស្រុកកំចាយមារ)។



❈នារសៀលថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តម **លេខ ទី** លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភា និង ឯកឧត្តមបណ្ឌិត **អ៊ុក គង់** សមាជិកគណៈកម្មការទី៦

ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបូជាព្រះសព ព្រះឥន្ទមុនី **អ៊ុក មុត** ព្រះរាជាគណៈថ្នាក់ចត្វា ព្រះមេគណ ព្រះឧបជ្ឈា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តបាត់ដំបង។

❈នាថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញជួបជាមួយតំណាងប្រធានរដ្ឋបាលខេត្តកោះកុង និងប្រធានរដ្ឋបាលសាលាដំបូងខេត្តកោះកុង ដើម្បីពិភាក្សាអំពីគម្រោងចុះបេសកកម្មរបស់គណៈកម្មការទី៦ព្រឹទ្ធសភា ។

❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមប្រជុំជាមួយមេភូមិទាំង១៣និងក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីស្តាប់សេចក្តីរាយការណ៍ស្តីពី លទ្ធផលការងារខែមករានិងទិសដៅការងារអាទិភាពសម្រាប់ខែកុម្ភៈ ឆ្នាំ២០២៦ បន្តចាត់វិធានការកាន់តែម៉ឺងម៉ាត់លើការគ្រប់គ្រងជនបរទេស ការប្រយុទ្ធប្រឆាំងល្បែង online និង online scams ការអនុវត្តគម្រោងរៀបចំកែលម្អផ្លូវថ្មើរជើងតាមបណ្តោយមហាវិថីម៉ៅសេទុង (ផ្លូវ២៤៥) ព្រមទាំងចុះជួបសមាជិកក្រុមគ្រួសារកងទ័ពទាំង១២គ្រួសារ និងបានឧបត្ថម្ភថវិកាមួយចំនួនជូនមូលនិធិកតញ្ញូ នាថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៦។



-ចូលរួមពិធីបុណ្យមាឃបូជា ថ្វាយទៀន ធូប ផ្លែឈើ សមាទានសីល និងចតុបច្ច័យប្រគេនព្រះចៅអធិការវត្តនាគវន្ត នៅខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៦។



-ចូលរួមវេទិកាសាធារណៈជាមួយក្រុមប្រឹក្សាសង្កាត់ រដ្ឋបាលសង្កាត់ នគរបាលប៉ុស្តិ៍ មេភូមិទាំង១៣ ប្រជាការពារ និងប្រជាពលរដ្ឋ ដើម្បីស្តាប់សំណូមពរ និងកង្វល់នានារបស់ប្រជាពលរដ្ឋ ពាក់ព័ន្ធការអនុវត្តគោលនយោបាយភូមិ សង្កាត់មានសុវត្ថិភាព បន្តរួមគ្នាសហការអនុវត្តន៍ឱ្យបានម៉ឺងម៉ាត់ក្នុងយុទ្ធនាការប្រឆាំងលុបបំបាត់បទល្មើស online scams ទប់ស្កាត់បញ្ចៀសគ្រោះអគ្គិភ័យ និងការពារសុខសុវត្ថិភាពសណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋនៅមូលដ្ឋាន នៅសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៦។



-ចូលរួមជាមួយក្រុមប្រឹក្សាសង្កាត់ ក្រុមការងារកាកបាទក្រហម និងក្រុមការងារ ស.ស.យ.ក ខណ្ឌទួលគោក ព្រមទាំងជួបសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋ ចាស់ជរាពិការ និងបានឧបត្ថម្ភអង្ករ គ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួន នៅសង្កាត់ផ្សារដេប៉ូទី១ ទី២ និងទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៦។

-ជួបសំណេះសំណាលជាមួយមន្ត្រីការិយាល័យអមគណៈកម្មការទី៧និងមន្ត្រីការិយាល័យជំនួយការអម



ភូមិភាគទី១ ដោយបានឧបត្ថម្ភកង់ចំនួន៤គ្រឿង ដល់កូនមន្ត្រីសម្រាប់ជាមធ្យោបាយធ្វើដំណើរទៅសាលារៀន នាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៦ នៅវិមានព្រឹទ្ធសភា។

❈នាថ្ងៃទី៧និងថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការអនុវត្តការងារប្រចាំឆ្នាំ២០២៥និងទិសដៅការងារឆ្នាំ២០២៦ របស់ឃុំព្រះពន្លា នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។

❈នាថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ជឹម លាង** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភានិងលោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ បូកសរុបការងារប្រចាំឆ្នាំ២០២៥ និងសម្រាប់ទិសដៅអនុវត្តបន្តរបស់ស្រុកជើងព្រៃ ខេត្តកំពង់ចាម។

❈នាថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបុណ្យមាឃបូជា នៅវត្តសីហារតនារាម ស្ថិតក្នុងក្រុងដូនកែវ ខេត្តតាកែវ។



❈នាថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភានិងឯកឧត្តម **អ៊ុន វណ្ណា** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលរួមនមស្ការព្រះរត្នត្រ័យនិងពិធីសែនក្រុងពាលី បញ្ចុះបឋមសិលាសាងសង់ប្រាសាទសិរីវិជ័យ បឹងតាកែវ នៅបរិវេណសួនច្បារមាត់បឹងតាកែវ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ។

❈ឯកឧត្តម **ឆាយ វណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលក្នុងឃុំត្រពាំងផ្លុង ឃុំក្រែក ស្រុកពញាក្រែក និងឃុំទួលស្នួល ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នាថ្ងៃទី២៩-៣០ ខែមករា និងថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៦។



-ចុះសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋអ៊ិស្លាម ព្រមទាំងបាននាំយកអំណោយសារុងសម្រាប់ចែកជូនបងប្អូនប្រជាពលរដ្ឋ នៅភូមិដងកំបិត ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៦។



-ជួបសំណេះសំណាលនិងនាំយកថវិកាឧបត្ថម្ភចែកជូនលោកគ្រូ និងអ្នកគ្រូ នៅភូមិបារ៉ែន ឃុំស្វាយប្រទាល ស្រុកស្អាង

ខេត្តកណ្តាល នាព្រឹកថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៦។



-ចូលរួមពិធីប្រគល់សញ្ញាបត្របញ្ចប់ការសិក្សាផ្នែកតាហ្វីស (Tahfiz) និងបណ្ណសរសើរជូនដល់សិស្សានុសិស្សនៃសាលា «ម៉ាដរ៉ាសាស នូរុលហាហ្វីហ្សោះអង្គរជា» នៅភូមិអង្គរជា ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៦។

-ចុះចែកកញ្ចប់អាហាររ៉ាម៉ាឌន ជូនដល់បុគ្គលិក លោកគ្រូ អ្នកគ្រូ នៃសាលាអ៊ិស្លាមព្រៃកដ៏រ ចំនួន១៧០កញ្ចប់ នៅភូមិព្រៃកដ៏រ ឃុំសេដា ស្រុកតំបែរ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៦។

❋ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈ-កម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមផ្សព្វផ្សាយរបាយការណ៍ស្តីពី សភាពការណ៍ទូទៅ ឆ្នាំ២០២៥និងលើកទិសដៅការងារបន្តឆ្នាំ២០២៦ នៅសាលាខេត្តបន្ទាយមានជ័យ នាថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៦។



-ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងទិសដៅអនុវត្តបន្តឆ្នាំ២០២៦ របស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន នៅសាលាខេត្តបន្ទាយមានជ័យ នាថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៦។

❋នាថ្ងៃអង្គារ ទី២៧ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភា និងឯកឧត្តម **អន ស៊ុំ** សមាជិកព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារបន្តឆ្នាំ២០២៦ របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ នៅសាលាខេត្តបន្ទាយមានជ័យ។

❋លោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញ៖



-ជាអធិបតីក្នុងពិធីបើកការដ្ឋានសាងសង់ផ្លូវក្រាលកៅស៊ូ១ខ្សែ ប្រវែង៤.៣០០ម៉ែត្រ ទទឹង៦ម៉ែត្រ នៅភូមិសំពៅមាស ឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៦។



-ប្រារព្ធពិធីរាប់បាត្រព្រះសង្ឃចំនួន១៥០អង្គ ឆ្លងថ្ងៃបុណ្យមាឃបូជា នៅវត្តឥន្ទ្រីយ៍សំវរៈ (ហៅវត្តកំពង់ធំ) និងប្រគេនចង្ហាន់ ព្រមទាំងបច្ច័យដល់ព្រះសង្ឃនៅវត្តទេពនិម្មិត (ហៅវត្តធម្មយុត្ត) ក្រុងស្ទឹងសែន ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៦។

-ជាគណៈអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវ




ការអគារសហគមន៍ឃុំផាត់សណ្ដាយ នៅឃុំផាត់សណ្ដាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៦។



❈នាថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា បានដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ អញ្ជើញគោរពវិញ្ញាណក្ខន្ធសព លោកវរសេនីយ៍ត្រី **នួច ណារ៉ុង** វីរកងទ័ពឈរជើងនៅសមរភូមិជួរមុខទិសប្រាសាទតាក្របី នៅឃុំជីពោទ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

❈ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី១ ព្រឹទ្ធសភា បានអញ្ជើញ៖



-ជាគណៈអធិបតីក្នុងកម្មវិធីប្រគល់សាណាត ហាឌីស ស៊ូណាន់ ស៊ីតតាស់ (SUNAB SITTAH) ដល់សិស្សបញ្ចប់ការសិក្សារយៈពេល៨ឆ្នាំនិងប្រគល់សញ្ញាបត្រ អាល់គួរអាន (SYAHADAH TAHFIZ) ចំពោះសិស្សដែលបានទន្ទេញចាំមាត់ ព្រមទាំងប្រគល់សញ្ញាបត្រដល់សិស្សជានារីដែលបានបញ្ចប់ការសិក្សារយៈពេល៦ឆ្នាំនិងប្រគល់បណ្ណសរសើរដល់សិស្សពូកែសម្រាប់ឆ្នាំសិក្សា២០២៥ នៅសាលានូរុលហ៊ីឌើយ៉ះ ក្បាលរមាស ភូមិត្រពាំងសង្កែ ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៦។



-ចុះសួរសុខទុក្ខថ្នាក់ដឹកនាំនិងជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិម៉ាក់ប្រាង្គ ឃុំកំពង់ក្រែង ស្រុកទឹកឈូ ខេត្តកំពត នាយប់ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៦។

❈ឯកឧត្តម **គង់ មុនីភា** សមាជិកគណៈកម្មការទី១ ព្រឹទ្ធសភា បានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយបងប្អូនប្រជាពលរដ្ឋ ដើម្បីឈ្វេងយល់បញ្ហាប្រឈម នៅសង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៦។

-ជួបសំណេះសំណាលនិងស្តាប់បញ្ហាប្រឈមរបស់បងប្អូនប្រជាពលរដ្ឋ នៅសង្កាត់ចេក ក្រុងស្វាយរៀង ខេត្តស្វាយរៀង នារសៀលថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៦។

-ជួបសំណេះសំណាលនិងស្តាប់បញ្ហាប្រឈមរបស់បងប្អូនប្រជាពលរដ្ឋ នៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៦។

-ជួបសំណេះសំណាលនិងស្តាប់បញ្ហាប្រឈមរបស់បងប្អូនប្រជាពលរដ្ឋ នៅភូមិអណ្តូងច្រុះ ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម នារសៀលថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៦។

❈ឯកឧត្តម **គង់ មុនីភា** សមាជិកគណៈកម្មការទី១ ព្រឹទ្ធសភា និងឯកឧត្តម **សេខ ម៉ារឌី** សមាជិកគណៈ-កម្មការទី៩ ព្រឹទ្ធសភា បានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយបងប្អូនប្រជាពលរដ្ឋ នៅឃុំរូង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នារសៀលថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៦។

-ជួបសំណេះសំណាលនិងស្តាប់បញ្ហាប្រឈមរបស់

បងប្អូនប្រជាពលរដ្ឋ នៅសង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង នាព្រឹកថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៦។



❋នាព្រឹកថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៦ លោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញប្រគេនទេយ្យទាននិងរៀបចំចង្ហាន់ប្រគេនព្រះសង្ឃនិងដូនជី ចំនួន៥១អង្គ/នាក់ ដែលកំពុងធ្វើវិបស្សនា នៅស្រុកត្រាំកក់ ខេត្តតាកែវ។



❋នាថ្ងៃពុធ ទី២៥ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភានិងលោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខឯកឧត្តម **ស្នួន លន់** អតីតសមាជិកព្រឹទ្ធសភា នីតិកាលទី៤ នៅខេត្តសៀមរាប។

❋ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥និងលើកទិសដៅការងារឆ្នាំ២០២៦ របស់រដ្ឋបាលខេត្តសៀមរាបនៅសាលាខេត្តសៀមរាប នាថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦។

-ជួបសំណេះសំណាលនិងពិភាក្សាការងារជាមួយលោកប្រធានក្រុមប្រឹក្សាស្រុក លោកអភិបាលស្រុក លោកមេឃុំ ស្មៀនឃុំ នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ ដើម្បីឈ្វេងយល់អំពីការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព

និងអភិវឌ្ឍន៍មូលដ្ឋាន នៅឃុំនគរភាស ស្រុកអង្គរជុំ ខេត្តសៀមរាប នាថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦។



❋នាថ្ងៃទី២៦-២៨ ខែមករា ឆ្នាំ២០២៦ លោកជំទាវ **ចឹក ហេង** សមាជិកាគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល នៃឃុំតាវែងលើ ឃុំតាវែង-ក្រោម ឃុំប៉ុង ឃុំហាត់ប៉ក់ ឃុំទឹងចាក់ ឃុំលុងឃុង ឃុំកិះចុង និងឃុំឡាមិញ ដើម្បីផ្សារភ្ជាប់ និងរួមប្រាស្រ័យទំនាក់ទំនងឱ្យកាន់តែជិតស្និទ្ធជាមួយអង្គបោះឆ្នោតនៅមូលដ្ឋាន ព្រមទាំងដើម្បីឈ្វេងយល់អំពីបញ្ហាប្រឈម សំណូមពរ និងការអនុវត្តតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ នៅខេត្តរតនគិរី។



❋នាព្រឹកថ្ងៃអង្គារ ទី២៧ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញពិនិត្យមើលវឌ្ឍនភាពនៃការកសាងសាលាបុណ្យមួយខ្នង និងជួយស្ថាបនាផ្លូវមួយខ្សែប្រវែង៣៥០ម៉ែត្រ ដោយចាក់ដីក្រហមចំនួន៤០ឡាន និងជូនអំពូលសូឡាដាក់បំភ្លឺតាមដងផ្លូវចូលមកសាលាបុណ្យចំនួន១០ដើម នៅភូមិស្នាកណ្តាល ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

❋នាព្រឹកថ្ងៃសុក្រ ទី២ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភានិងឯកឧត្តម **អ៊ឹង ឈាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីកាត់ឬសសីមាព្រះវិហារ និងកាត់ខ្សែបូសម្ពោធឆ្លងសមិទ្ធផលនានា នៅវត្តព្រះធាតុ-



ធ្វេង ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។

❋លោកជំទាវ **ម៉ុំ សណ្ដាប់** សមាជិកាគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមកិច្ចប្រជុំក្រុមការងារជួយគាំទ្រស្ត្រីរាជធានីភ្នំពេញ ក្រោមអធិបតីភាពលោកជំទាវ **ឡោក ខេង** ប្រធានគណៈ-កម្មការទី៨រដ្ឋសភា នៅសង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ នារសៀលថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៦។



-ចុះសួរសុខទុក្ខអ៊ុំស្រី **ម៉ៅ សាម៉ន** ម្ដាយបង្កើតលោកស្រី **ខិល សុខគូលាប** ប្រធានបណ្ដាញនារីសង្កាត់ទន្លេបាសាក់ ដែលកំពុងសម្រាកព្យាបាល នៅមន្ទីរពេទ្យព្រះកេតុមាលា នាព្រឹកថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៦។

❋ឯកឧត្តម **អ៊ឹង លាងហ្វ៊** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកុម្ភៈ និងទិសដៅការងារបន្តឆ្នាំ២០២៦ នៅសាលាស្រុកជលគីរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៦។



-ចូលរួមពិធីសំណេះសំណាលជាមួយប្រជាកសិករនិងចុះពិនិត្យការដាំដំណាំសហគមន៍កសិកម្ម នៅសហគមន៍កសិកម្មទឹកហូតមានជ័យក្ដីសង្ឃឹម នៅភូមិត្រពាំងក្រពើ ឃុំទឹកហូត ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៦។

❋នាថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុន ចណ្ណា** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចុះពិនិត្យទីតាំងនិងជួបពិគ្រោះយោបល់ជាមួយលោក **ព្រុំ វ៉ាត** ប្រធានសហគមន៍ភ្ញាស់និងចិញ្ចឹមបង្កង នៅឃុំព្រៃកផ្ដោល ស្រុកអង្គរបូរី ខេត្តតាកែវ។

❋ឯកឧត្តម **សេង ម៉ារឌី** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមសិក្ខាសាលាស្ដីពី ការចែករំលែកចំណេះដឹងព័ត៌មាននិងការទប់ស្កាត់ព័ត៌មានក្លែងក្លាយ នៅសង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦។

-ជួបសំណេះសំណាលនិងសួរសុខទុក្ខជាមួយសមាជិកក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ព្រមទាំងប្រជាពលរដ្ឋ នៅភូមិរូង ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នារសៀលថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៦។

❋លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញ៖

-ជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយនិវត្តជនមកពីបណ្ដាស្ថាប័ន និងអង្គភាពនានាក្នុងខេត្តសៀមរាប សរុបចំនួន២.០០០នាក់ នៅក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៦។

-នាំយកទេយ្យទាននិងបច្ច័យមួយចំនួនប្រគេនព្រះសង្ឃ នៅវត្តព្រះឥន្ទកោសីយ៍ វត្តព្រះឥន្ទកោសារ វត្តគោកធ្លក និងវត្តស្វាយធំ នៅខេត្តសៀមរាប នាថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៦។

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ





❈នាព្រឹកថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៦ សមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៨រូប បានអញ្ជើញចូលរួមពិធីបុណ្យមាឃ-បូជា នៅព្រះមហាសក្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យ ( ឧត្តុង្គ ) ស្រុកពញាឮ ខេត្តកណ្តាល។

❈ពីថ្ងៃទី២-៤ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ខី ច័ន្ទ្រផល**



ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញអមដំណើរ ឯកឧត្តម **ស៊ីយ៉េដ យូសាហ្វ រ៉ាសា ហ្គីឡានី** ប្រធានព្រឹទ្ធសភា នៃសាធារណរដ្ឋអ៊ិស្លាមប៉ាគីស្ថាន អញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធ «ព្រះបរមរតនកោដ្ឋ» និងបុព្វ-ការីជន នៅវិមានឯករាជ្យ, ចូលក្រាបបង្គំគាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា, ចូលជួបសម្តែងការគួរសមជាមួយសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

❈នាព្រឹកថ្ងៃចន្ទ ទី១៩ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **យស ផានីត្ថា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញប្រគល់ធុងទឹកចំនួន៧០០ធុង ( ចំណុះ២៥លីត្រ ) និងថ្នាំលាបការពាររមាស់ ចំនួន១.០០០ប្រអប់ និងថវិការបស់លោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** ឧបត្ថម្ភជូនអង្គភាពការពារព្រំដែនជួរមុខ នៅបន្ទប់ប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា។



❈នាល្ងាចថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តមបណ្ឌិត **ឈីវ យីស៊ាង** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា និងឯកឧត្តមបណ្ឌិត **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួមអបអរសាទរពិធីចម្រើនព្រះជន្មគម្រប់៦៦ព្រះវស្សា របស់ព្រះករុណាព្រះចៅអធិរាជជប៉ុន **ណារូហ៊ីតូ** (NARUHITO) និងមិត្តភាពដ៏យូរអង្វែងរវាងជប៉ុននិងកម្ពុជា នៅស្ថានទូតជប៉ុនប្រចាំកម្ពុជា រាជធានីភ្នំពេញ។

❈នាល្ងាចថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត

**ឈឹម យីស៊ាង** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីទទួលទានភោជនាហារពេលល្ងាច ដើម្បីអបអរសាទរ «ទិវាជាតិអូស្ត្រាលី ឆ្នាំ២០២៦» នៅស្ថានទូតអូស្ត្រាលី ។

❈លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមពិធីបិទសន្និបាតបូកសរុបការងារសុខាភិបាល លើកទី៤៥ ឆ្នាំ២០២៥និងលើកទិសដៅបន្តរបស់ក្រសួងសុខាភិបាល នារសៀលថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៦។



-ជាគណៈអធិបតីក្នុងពិធីប្រកាសទទួលស្គាល់សមាស-ភាពគណៈកម្មការសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្តតាកែវ នៅសាលាខេត្តតាកែវ នាព្រឹក ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៦។

❈នារសៀលថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦ លោកជំទាវ **មាន សំអាន** ប្រធាន ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធាន និងលោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបួងសួងសុំសេចក្ដីសុខ សេចក្ដីចម្រើន ជូនដល់ប្រជាពលរដ្ឋនៃព្រះរាជាណាចក្រ



កម្ពុជា នៅកន្លែងសក្ការបូជាលោកតា រាជ ក្នុងប្រាសាទអង្គរវត្ត ខេត្តសៀមរាប។



❈នារសៀលថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៦ លោកជំទាវ **មាន សំអាន** ប្រធាន ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធាន លោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ **ចឹក ហេង** សមាជិកាគណៈ-កម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីបុណ្យសាមគ្គី និងរាប់បាត្រព្រះសង្ឃចំនួន១២៣អង្គ ដើម្បីឧទ្ទិសអនិសង្សបុណ្យជូនវីរកងទ័ពដែលបានពលីជីវិតក្នុងបុព្វហេតុការពារបូរណភាពទឹកដីពីការឈ្លានពានរបស់ថៃ និងបុព្វបុរសដូនតាខ្មែរ នៅបរិវេណប្រាសាទអង្គរវត្ត ខេត្តសៀមរាប។



❀នាព្រឹកថ្ងៃសុក្រ ទី៣០ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ឈួន នាម** អនុប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០២៥និងលើកទិសដៅការងារឆ្នាំ២០២៦ នៅទីស្តីការក្រសួងបរិស្ថាន។



❀នាថ្ងៃអង្គារ ទី១០ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភានិងឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំត្រៀមចូលរួមមហាសន្និបាតនិងកិច្ចប្រជុំនានារបស់អាយប៉ា (AIPA) នៅវិមានរដ្ឋសភា។

❀ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បាន៖



-អនុញ្ញាតឱ្យក្រុមការងារនិពន្ធរៀបរៀងសៀវភៅ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ចូលជួបសម្តែងការគួរសម និងប្រគល់សៀវភៅយុវជន និងមាគ៌ានៃស្វ័យាភិវឌ្ឍន៍តាមទស្សនវិស័យព្រះពុទ្ធសាសនា ព្រមទាំងបានចូលរួមថវិកាឧបត្ថម្ភគាំទ្រដល់វីរកងទ័ពជួរមុខនិងជនភៀសសឹក តាមរយៈមូលនិធិអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នាថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៦។



-ជួបពិភាក្សាការងារជាមួយឯកឧត្តម Florian TILLY នាយកប្រតិបត្តិអន្តរជាតិ នៃមូលនិធិមហាឫស្សី ដើម្បីសន្តិភាពពិភពលោកប្រចាំកម្ពុជា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា នាថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៦។

❀នារសៀលថ្ងៃអង្គារ ទី៦ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ម៉ែន-ស៊ីផាន់** ប្រធានស្តីទីគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥និងលើកទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន នៅទីស្តីការក្រសួង។

❀សម្តេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បាន៖

-យាងជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត បានយាងជាព្រះរាជធិបតីក្នុងពិធីបុណ្យមាឃបូជា នៅព្រះបរមរាជវាំង នាថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៦។

-យាងនាំយកនូវព្រះរាជអំណោយដ៏ថ្លៃថ្លា ជាគោយន្តចំនួន២គ្រឿង របស់សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ សព្វព្រះរាជហឫទ័យព្រះរាជទានដល់កូនចៅវីរកងទ័ពឈរជើងជួរមុខ ដើម្បីដោះស្រាយកិច្ចការប្រចាំថ្ងៃ នៅទីបញ្ជាការកងពលតូចអន្តរាគមន៍លេខ៩ ខេត្តព្រះវិហារ នាថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៦។

-យាងដង្ហែព្រះរាជដំណើរ សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ព្រះរាជានុញ្ញាតជូន ឯកឧត្តម **តូ ឡឹម**



អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម ចូលក្រាបថ្វាយបង្គំគាល់ នៅព្រះបរមរាជវាំង នាថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៦។



-យាងដង្ហែព្រះរាជដំណើរ សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ព្រះអង្គសព្វព្រះរាជហឫទ័យធ្វើព្រះរាជទស្សនកិច្ចនៅស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦។

-សព្វព្រះហឫទ័យអនុញ្ញាតជូនឯកឧត្តម Santo Darmosumarto ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាព នៃសាធារណរដ្ឋឥណ្ឌូណេស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ចូលថ្វាយបង្គំលា ក្នុងឱកាសបញ្ចប់បេសកកម្មការទូតនៅកម្ពុជា នៅព្រះរាជដំណាក់វិមានឯករាជ្យ នារសៀលថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៦។

-សព្វព្រះហឫទ័យទទួលជួប និងលៀងភោជនាហារថ្ងៃត្រង់ជូនដំណើរលោកជំទាវ Teo Lay Cheng ឯកអគ្គរដ្ឋទូត



វិសាមញ្ញនិងពេញសមត្ថភាព នៃប្រទេសសិង្ហបុរី ប្រចាំព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសបញ្ចប់បេសកកម្មការទូតនៅកម្ពុជា នាថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៦៕

## សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

❈ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិនិងមហាសន្និបាតលើកទី១៦ នៃសភាតំបន់អាស៊ី (APA) នៅទីក្រុងម៉ាណាម៉ា ប្រទេសបារ៉ែន។

❈ចាប់ពីថ្ងៃទី២៧ ខែមករា ដល់ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យនិងតាមដានប្រជាធិបតេយ្យ នៃសភាប្រើភាសា



បារាំង (APF) នៅទីក្រុងប៉ូដហ្គោរីកា (Podgorica) សាធារណរដ្ឋម៉ុងតេណេហ្គ្រោ (Monténégro)៕

# ឯកឧត្តម ឡាយ សំកុល អញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារ ប្រចាំខែមករា និងកំណត់ទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២៦




*ឯកឧត្តម អោក ប៉ូ* *ឯកឧត្តម ខេង សិទ្ធិគុណ* *ឯកឧត្តម ឡាយ សំកុល* *ឯកឧត្តម ឡោក ឆាយ* *ឯកឧត្តម ឌី បញ្ញា*

នាព្រឹកថ្ងៃព្រហស្បតិ៍ ១០រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩ ត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៦ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមករានិងកំណត់ទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២៦ ក្រោមអធិបតីភាពឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអង្គភាពចាប់ពីប្រធាននាយកដ្ឋានឡើង។

មានប្រសាសន៍ក្នុងឱកាសនោះ **ឯកឧត្តមអគ្គលេខាធិការ** បានលើកឡើងថា តាមរយៈការសាងសង់វិមានសាមគ្គីភាព ព្រឹទ្ធសភាបានក្លាយជាមជ្ឈមណ្ឌលជាតិដ៏សំខាន់មួយក្នុងការរៀបចំព្រឹត្តិការណ៍ធំៗរបស់ជាតិ ព្រមទាំងបានទទួលការកោតសរសើរ និងមានមោទនភាពចំពោះក្រុមការងារពាក់ព័ន្ធទាំងអស់ ដែលបានផ្តល់សេវាជូនថ្នាក់ដឹកនាំព្រឹទ្ធសភាបានទាន់ពេលវេលា រួមមានការរៀបចំពិធីក្រុងពាលីនិងសូត្រមន្តចម្រើនព្រះបរិត្តឡើងវិមានសាមគ្គីភាពនៃព្រឹទ្ធសភា ការរៀបចំទទួលបដិសណ្ឋារកិច្ច**ឯកឧត្តមប្រធានព្រឹទ្ធសភាប៉ាគីស្ថាន** និងគណៈប្រតិភូអញ្ជើញបំពេញទស្សនកិច្ចផ្លូវការ និងការរៀបចំទទួលបដិសណ្ឋារកិច្ច**គណៈប្រតិភូជាន់ខ្ពស់នៃសាធារណរដ្ឋសង្គមនិយមវៀតណាម** និង**សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ** អញ្ជើញបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា ដែលបានរួមចំណែកលើកកម្ពស់មុខមាត់ និងមោទនភាពរបស់ព្រឹទ្ធសភា និងជាតិ។

ចំពោះទិសដៅការងារនាពេលខាងមុខ **ឯកឧត្តមអគ្គលេខាធិការ** បានណែនាំទៅអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី និងអគ្គនាយកដ្ឋានពិធីការនិងទំនាក់ទំនងអន្តរជាតិ ធ្វើបច្ចុប្បន្នភាពសមាសភាពក្រុមអ្នកនាំពាក្យព្រឹទ្ធសភា និងក្រុមមិត្តភាពនានា ដែលទាក់ទងនឹងការជ្រើសតាំងប្រធានគណៈកម្មការទី៥ ថ្មីរបស់ព្រឹទ្ធសភា ព្រមទាំងណែនាំឱ្យអគ្គនាយកដ្ឋានពិធីការនិងទំនាក់ទំនងអន្តរជាតិ ពិនិត្យកែសម្រួលសេចក្តីសម្រេចស្តីពី ការបង្កើតក្រុមការងារស្រាវជ្រាវ និងវិភាគព្រឹត្តិការណ៍តំបន់និងអន្តរជាតិនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

ចំពោះកិច្ចការពាក់ព័ន្ធនឹងសហប្រតិបត្តិការអន្តរជាតិ




*ឯកឧត្តម ឡាយ សំកុល អញ្ជើញមានប្រសាសន៍ក្នុងកិច្ចប្រជុំបូកសរុប*

**ឯកឧត្តមអគ្គលេខាធិការ**បានបញ្ជាក់ថា នាពេលខាងមុខ ថ្នាក់ដឹកនាំព្រឹទ្ធសភានឹងអញ្ជើញទៅចូលរួមមហាសន្និបាតអន្តរសភា (IPU) នៅសាធារណរដ្ឋតួកគីយេ ការរៀបចំធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង (APF) និងកិច្ចប្រជុំ «សន្និសីទប្រធានសភានៃអន្តរសភា» ដែលនឹងប្រព្រឹត្តនៅអំឡុងខែសីហា ឬខែកញ្ញា ឆ្នាំ២០២៦ ដោយមានប្រទេសជាង៤៥ ចូលរួម។ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក៏បាននិងកំពុងរៀបចំដំណើរទស្សនកិច្ចរបស់សម្តេចតេជោ **ហ៊ុន សែន** អញ្ជើញទៅបំពេញទស្សនកិច្ចនៅអឺរ៉ុប នាពេលខាងមុខនេះ ផងដែរ។

**ឯកឧត្តមអគ្គលេខាធិការ** បានបន្តជំរុញឱ្យក្រុមការងារបច្ចេកវិទ្យាព័ត៌មានរៀបចំគេហទំព័រព្រឹទ្ធសភាឱ្យកាន់តែមានភាពទាក់ទាញ។ ចំពោះការសាងសង់សាលារៀន១ខ្នង ៥បន្ទប់ នៅសង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដែលជាគំនិតផ្តួចផ្តើមរបស់**ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា**។ តាមរយៈគំនិតផ្តួចផ្តើមនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភានឹងរៀបចំសេចក្តីជូនដំណឹង ដើម្បីមន្ត្រីបុគ្គលិកអាចចូលរួមចំណែកជាវិភាគទាន តាមសទ្ធារៀងៗខ្លួន។

មុននឹងបញ្ចប់ **ឯកឧត្តមអគ្គលេខាធិការ** បានថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ដែលបានខិតខំបំពេញការងារបានល្អប្រសើរនិងសូមបន្តខិតខំយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់សេវាឱ្យបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយជូនព្រឹទ្ធសភា៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន




*ទិដ្ឋភាពក្នុងពិធីប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមករា និងកំណត់ទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២៦*

# ឯកឧត្តម ឡាយ សំកុល អញ្ជើញសំណេះសំណាលជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្ត របស់ប្រទេសបារាំងចុះពិនិត្យព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋ ដោយមិនយកកម្រៃ នៅសង្កាត់បាក់ខែង




ឯកឧត្តម ឡាយ សំកុល អញ្ជើញសំណេះសំណាលជាមួយប្រជាពលរដ្ឋមកពិនិត្យព្យាបាលជំងឺ នៅសង្កាត់បាក់ខែង

នាព្រឹកថ្ងៃពុធ ទី១៨ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា អមដំណើរដោយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លោក **លឹម សុភា** អភិបាលនៃគណៈអភិបាលខណ្ឌជ្រោយចង្វារ និងក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃសមាគមបេសកកម្មមនុស្សធម៌នៅកម្ពុជា(AMH) របស់ប្រទេសបារាំង បានអញ្ជើញសំណេះសំណាលសាកសួរសុខទុក្ខ និងចុះពិនិត្យព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋដោយមិនយកកម្រៃរយៈពេល២ថ្ងៃ នៅភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

ក្នុងឱកាសនោះ **ឯកឧត្តមអគ្គលេខាធិការ** បាននាំនូវការផ្តាំផ្ញើសួរសុខទុក្ខពីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានិង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត**






ឯកឧត្តម ឡាយ សំកុល អញ្ជើញប្រគល់ទេះរុញ និងសម្ភារៈសង្គ្រោះបឋមដល់អាជ្ញាធរសង្កាត់

ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ ឯកឧត្តមបណ្ឌិត **ឆន់ ចន្ទស្សនា** អនុប្រធានទី២ព្រឹទ្ធសភា ប្រកបដោយសេចក្តីនឹករលឹក និងការគិតគូរអំពីសុខទុក្ខរបស់បងប្អូនប្រជាពលរដ្ឋក្នុងខណ្ឌជ្រោយចង្វារ។ ឯកឧត្តមបានថ្លែងកោតសរសើរដល់អាជ្ញាធរសង្កាត់ ខណ្ឌ ដែលបានយកចិត្តទុកដាក់ផ្តល់សេវាជូនបងប្អូនប្រជាពលរដ្ឋយ៉ាងល្អប្រសើរក្នុងរយៈពេលកន្លងទៅ។ ជាពិសេស ឯកឧត្តមបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអាជ្ញាធរមូលដ្ឋាន និងក្រុមគ្រូពេទ្យស្ម័គ្រចិត្តប្រទេសបារាំង ដែលបានយកចិត្តទុកដាក់រៀបចំ និងពិនិត្យព្យាបាលជំងឺជូនបងប្អូនប្រជាពលរដ្ឋ។ ការងារស្ម័គ្រចិត្តនេះ គឺបានឆ្លុះបញ្ចាំងពីស្មារតីសាមគ្គីធម៌ និងមនុស្សធម៌ដ៏ថ្លៃថ្លាបំផុតរបស់ក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់ប្រទេសបារាំង ក៏ដូចជាសហប្រតិបត្តិការ ស្មារតីស្រលាញ់រាប់អាននិងទំនាក់ទំនងល្អរវាងប្រទេសទាំងពីរ។ ជាមួយគ្នានោះ ឯកឧត្តមក៏បានផ្តាំផ្ញើដល់បងប្អូនប្រជាពលរដ្ឋដែលអញ្ជើញមកចូលរួមទាំងអស់ ត្រូវខិតខំយកចិត្តទុកដាក់ក្នុងការថែរក្សាសុខភាពឱ្យបានល្អ និងអនុវត្តរបបអាហារ ព្រមទាំងការប្រើប្រាស់ថ្នាំតាមការណែនាំនិងវេជ្ជបញ្ជារបស់គ្រូពេទ្យឱ្យបានទៀងទាត់។

ក្នុងឱកាសនោះផងដែរ **ឯកឧត្តមអគ្គលេខាធិការ** ក៏បានជម្រាបជូនអំពីសភាពការណ៍ព្រំដែនកម្ពុជា-ថៃ បើទោះបីជាមានសភាពស្ងប់ស្ងាត់ពិតមែន តែយើងមិនត្រូវធ្វេសប្រហែសនោះទេ។

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី ថ្នាក់ដឹកនាំ និងវីរយុទ្ធជនគ្រប់លំដាប់ថ្នាក់នៅតាមព្រំដែន បានប្រកៀកស្មាគ្នាយ៉ាងជិតស្និទ្ធបំផុតក្នុងការផ្តល់យោបល់យុទ្ធសាស្ត្រ ដើម្បីដោះស្រាយបញ្ហានៅតាមព្រំដែន។ សង្គ្រាមនេះធ្វើឱ្យប្រទេសកម្ពុជាជួបការលំបាកក្នុងផ្នែកមនុស្សធម៌ គឺមានប្រជាជនជាង៥សែននាក់បានផ្លាស់ទីលំនៅ និងការបាត់បង់ជីវិតវីរយុទ្ធជនដ៏អង់អាចក្លាហានក្នុងការការពារបូរណភាពទឹកដីកម្ពុជា។ ឯកឧត្តមបានអំពាវនាវដល់ប្រជាពលរដ្ឋឱ្យមានការគាំទ្រនិងជឿទុកចិត្តលើការដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាព្រំដែន និងសូមប្រជាពលរដ្ឋខ្មែរទាំងអស់ រួបរួមសាមគ្គីគ្នាជាធ្លុងមួយ ដើម្បីជាកម្លាំងចិត្តគាំទ្រដល់រាជរដ្ឋាភិបាល និងវីរយុទ្ធជនរបស់យើង ក្នុងការការពារបូរណភាពដែនដី និងជាតិមាតុភូមិ។



*ឯកឧត្តម ឡាយ សំកុល អញ្ជើញថតរូបអនុស្សាវរីយ៍ ជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្ត*



*ឯកឧត្តម ឡាយ សំកុល បាននាំយកបច្ច័យកសាង ប្រគេនព្រះចៅអធិការវត្តសូរិយាពោធិ៍មាស*

**ឯកឧត្តមអគ្គលេខាធិការ** ក៏បានឧបត្ថម្ភថវិកាមួយចំនួនដល់ប្រជាពលរដ្ឋមកពិនិត្យព្យាបាលជំងឺ ផ្តល់រទេះរុញដល់អ្នកជំងឺពិការចំនួន២រូបនិងប្រគល់សម្ភារៈសង្គ្រោះបឋមដល់អាជ្ញាធរសង្កាត់ ព្រមទាំងនាំយកបច្ច័យកសាងប្រគេនព្រះចៅអធិការវត្តសូរិយាពោធិ៍មាស (ហៅវត្តក្តីចាស់) ផងដែរ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

❈នាថ្ងៃព្រហស្បតិ៍ ទី២៩ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម Zaheeruddin Babar Thaheem ឯកអគ្គរដ្ឋទូតប៉ាគីស្ថានប្រចាំកម្ពុជានិងសហការី នៅបន្ទប់ប្រជុំខុទ្ទកាល័យឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា។





❈នាព្រឹកថ្ងៃចន្ទ ទី២ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញទទួលស្វាគមន៍ និងជូនកន្ត្រកផ្កាដល់ឯកឧត្តម **ស៊ីយ៉េដ យូសាហ្វ រ៉ាសា ហ្គីឡានី** ប្រធានព្រឹទ្ធសភា នៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន នៅសណ្ឋាគារ Hyatt Regency Phnom Penh។

❈នាព្រឹកថ្ងៃអង្គារ ទី៣ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភានិងសហការី បានអញ្ជើញជួបប្រជុំជាមួយថ្នាក់ដឹកនាំគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ និងមានការចូលរួមពីតំណាងក្រសួងព្រះបរមរាជវាំង ដើម្បីពិនិត្យពិភាក្សាត្រៀមរៀបចំព្រះរាជពិធីសម្ពោធវិមានសាមគ្គីភាព នៃព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ



❈នារសៀលថ្ងៃពុធ ទី៤ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភានិងជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ (ក.ជ.ប.ព.) លើកទី៦ អាណត្តិទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ប្រធាន ក.ជ.ប.ព. នៅអង្គភាពប្រឆាំងអំពើពុករលួយ។

❈នាថ្ងៃព្រហស្បតិ៍ ទី៥ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងប្រើប្រាស់និងសម្របសម្រួលរៀបចំពិធីនិងកិច្ចប្រជុំនានាក្នុងវិមានសាមគ្គីភាព លើកទី១ ដើម្បីពិភាក្សានិងរៀបចំផែនការគ្រប់គ្រង ប្រើប្រាស់ និងថែទាំការពារសន្តិសុខ និងសណ្តាប់ធ្នាប់នៅបរិវេណវិមានសាមគ្គីភាព នៅបន្ទប់ប្រជុំរបស់ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា។





❈នាថ្ងៃព្រហស្បតិ៍ ទី៥ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញទទួលដំណើរសម្តេចមហាមន្ត្រី **គុយ សុផល** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង និងតំណាងអង្គភាពពាក់ព័ន្ធ ដើម្បីពិនិត្យទីកន្លែងត្រៀមរៀបចំព្រះរាជពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ «វិមានសាមគ្គីភាព» ។

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃសុក្រ ទី៣០ ខែមករា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឈីវ យីសាន** នាយកខុទ្ទកាល័យសម្តេចតេជោប្រធានព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសផ្តល់បាឋកថានិងមតិបូកសរុប ក្នុងវគ្គបណ្តុះបណ្តាល ស្តីពីវិធីសាស្ត្រស្រាវជ្រាវ ការងារ និងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានបញ្ញាសិប្បនិម្មិត ក្នុងការរៀបចំសុន្ទរកថា បទអន្តរាគមន៍ សេចក្តីថ្លែងការណ៍ និងសេចក្តីប្រកាសព័ត៌មាន នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។





❈នាព្រឹកថ្ងៃសៅរ៍ ទី៣១ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ខេង សិទ្ធិគុណា** អគ្គលេខាធិការរងព្រឹទ្ធសភា រួមជាមួយក្រុមការងារពាក់ព័ន្ធ បានអញ្ជើញពិនិត្យទីតាំងសម្រាប់ទទួលដំណើរទស្សនកិច្ចផ្លូវការរបស់ឯកឧត្តមប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន នៅវិមានសាមគ្គីភាពនៃព្រឹទ្ធសភា។

❈នាព្រឹកថ្ងៃសុក្រ ទី៣០ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គនាយក-ដ្ឋានសេវាច្បាប់និងសមូហភាពដែនដីនិងអគ្គនាយកដ្ឋានស្រាវជ្រាវ ប្រចាំខែមករា និងកំណត់ទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២៦ នៅសាលប្រជុំពិសេសខាងក្រោម វិមានព្រឹទ្ធសភា។





❈នាព្រឹកថ្ងៃសុក្រ ទី២០ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **អោភ ប៊ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **ម៉ី ចន្ទសុខា** អគ្គលេខាធិការរង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់-កាលទី៤ នៅសាលប្រជុំពិសេសខាងក្រោម វិមានព្រឹទ្ធសភា។

សូមស្កេន QR Code

ដើម្បីចូលទៅកាន់បណ្តាញសង្គមព្រឹទ្ធសភា

**Senate of Cambodia**

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ

ទូរសព្ទ៖ (855) 23 211 411, 211 422, 211 443

ទូរសារ៖ (855) 23 211 446

E-mail: secretariat@senate.gov.kh